**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# សិទ្ធិទទួលបានការជម្រះក្ដីដោយយុត្តិធម៌ នៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ៖

និស្សិតឈ្មោះ កញ្ញា **ឆេងអ៊ីម អ៊ីងគ័ង**

កញ្ញា **លន គឹមលីន**

ណែនាំដោយ៖

សាស្ត្រាចារ្យជំនួយ **សុខ ចិន្តា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

ក្រុមសិក្សាស្រាវជ្រាវយើងខ្ញុំ ទាំងពីររូបមានឈ្មោះ **ឆេងអ៊ីម អ៊ីងគ័ង** និង **លន គីមលីន** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០១៩-២០២៣។ យើងខ្ញុំបានសរសេរសារណាបញ្ចប់ការសិក្សាដោយជ្រើសរើសយកប្រធានបទស្តីពី "**សិទ្ធិទទួលបានការជម្រះក្តីដោយយុត្តិធម៌នៅកម្ពុជា**"។

**យើងខ្ញុំសូមគោរពលំឱនកាយវាចាចិត្តសម្តែងនូវការៈកិច្ច និងមហាកតញ្ញូដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ**

- លោកឪពុក **ស្រឿន អ៊ីម**
- លោកឪពុក **ព្រំ ម៉ៅ**
- អ្នកម្តាយ **ស៊ាង ផល្លា**

ជាដំបូងនាងខ្ញុំទាំងពីរនាក់ សូមថ្លែងអំណរគុណចំពោះ លោកឪពុក អ្នកម្តាយ ដែលបានបង្កើតរូបកាយកូន និងចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ឧបត្ថម្ភរូបកូនគ្រប់បែបយ៉ាងតាំងពីតូចដល់ធំ ទាំងកម្លាំងកាយ ទាំងកម្លាំងចិត្តមិនគិតពីការនឿយហត់។ លោកទាំងពីរ បានឱ្យកូនសិក្សារៀនសូត្រមានចំណេះដឹងរហូតដល់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រដោយជោគជ័យ។

យើងខ្ញុំទាំងពីរនាក់ក៏សូមថ្លែងអំណរគុណចំពោះ **ឯកឧត្តមបណ្ឌិត លុយ ចន្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច រួមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំងលោក លោកស្រី សាស្ត្រាចារ្យទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការអប់រំបណ្តុះបណ្តាលយ៉ាងយកចិត្តទុកដាក់ និងលើទឹកចិត្តយើងខ្ញុំ និងនិស្សិតនៅក្នុងការសិក្សារៀនសូត្រ ដើម្បីជាគ្រឹះសម្រាប់យើងខ្ញុំទទួលបានពុទ្ធិច្បាស់លាស់។

ជាពិសេសយើងខ្ញុំសូមថ្លែងអំណរគុណចំពោះ **លោកស្រីសាស្ត្រាចារ្យជំនួយ សុខ ចិន្តា** ជាសាស្ត្រាចារ្យដឹកនាំសារណាបញ្ចប់ការសិក្សានេះប្រកបដោយជោគជ័យ ដែលលោកបានយកចិត្តទុកដាក់ក្នុងការណែនាំ ប្រឹងប្រែងពន្យល់ តម្រង់ទិស ផ្តល់ឯកសារពាក់ព័ន្ធ ផ្តល់យោបល់ ឬអនុសាសន៍ល្អៗ និងជួយកែតម្រូវចំណុចខ្វះខាតទាំងឡាយ ដល់រូបនាងខ្ញុំទាំងពីរក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ តាំងពីដើមរហូតដល់ចប់។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរសូមប្រសិទ្ធពរជ័យជូនដល់ *លោកអ្នកមានគុណទាំងពីរ ឯកឧត្តម លោកជំទាវ លោក លោកស្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ* ទាំងអស់ឱ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

## **អារម្ភកថា**

សារណាមួយក្បាលនេះជាគឺជាស្នាដៃទីមួយ និងជាសមិទ្ធផលដែលបានមកពីការខិតខំប្រឹងប្រែងរបស់ពួកយើងទាំងពីរនាក់ដែលបានព្យាយាមក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល ០៤ ឆ្នាំ កន្លងមកធ្វើឱ្យយើងខ្ញុំបានយល់ដឹងកាន់តែច្បាស់ថាវិស័យច្បាប់ គឺដើរតួរយ៉ាងសំខាន់ក្នុង វិស័យផ្សេងៗទៀត ក៏ដូចជាការរៀបចំសណ្តាប់ធ្នាប់សង្គមឱ្យមានរបៀបរៀបរយផងដែរ។ ប៉ុន្តែនៅក្នុងសង្គមជាក់ស្តែងការអនុវត្តច្បាប់នៅតែមានចំណុចខ្វះចន្លោះដោយសារប្រជាពលរដ្ឋមិនបានយល់ច្បាស់ពីសិទ្ធ និងកាតព្វកិច្ចរបស់ខ្លួននៅពេលដែលគាត់បានប្រព្រឹត្តអំពើណាមួយដែលផ្ទុយទៅនឹងច្បាប់ ហើយត្រូវបានឃាត់ខ្លួន។ ម្យ៉ាងវិញទៀត មន្ត្រីអនុវត្តច្បាប់មួយចំនួនបានប្រើសិទ្ធអំណាចលើសការកំណត់របស់ច្បាប់ផងដែរ។ ដោយសំឡឹងឃើញមូលហេតុនេះហើយ ទើបធ្វើឱ្យយើងខ្ញុំទាំងពីរនាក់មានចិត្តចង់សរសេរសារណាក្រោមប្រធានបទថា "**សិទ្ធិទទួលបានការជម្រះក្តីដោយយុត្តិធម៌នៅកម្ពុជា**" ដើម្បីអាចជាជំនួយក្នុងការយល់ដឹងបន្ថែមថា នៅពេលដែលបងប្អូនស្ថិតនៅក្នុងស្ថានភាពជាជនជាប់ចោទថាតើបងប្អូនអាចធ្វើអ្វីបានខ្លះ? ជាពិសេសជួយឱ្យទទួលបាននូវការជម្រះក្តីដោយយុត្តិធម៌នៅកម្ពុជាយើងផងដែរ។

តាមរយៈស្នាដៃស្រាវជ្រាវមួយនេះ យើងខ្ញុំសង្ឃឹមថាសារណាក្រោមប្រធានបទខាងលើនេះ នឹងក្លាយជាវិភាគទានមួយចំណែកក្នុងវិស័យច្បាប់ និងចំពោះអ្នកសិក្សាជំនាន់ក្រោយ អ្នកស្រាវជ្រាវ និងអ្នកដែលបម្រើការងារ ក្នុងវិស័យច្បាប់ទាំងអស់ ដើម្បីទុកជាផលប្រយោជន៍សម្រាប់ជំនួយស្មារតី និងយកទៅប្រើប្រាស់ក្នុងវិស័យការងារដែលពាក់ព័ន្ធផងដែរ។ យើងខ្ញុំទាំងពីរនាក់សប្បាយរីករាយ នឹងទទួលយកនូវការរិះគន់ក្នុងន័យស្ថាបនារបស់លោក លោកស្រី សាស្ត្រាចារ្យ និងគ្រប់ស្រទាប់អ្នកសិក្សាទាំងអស់ដោយទុកមតិ រិះគន់នេះ ដើម្បីស្ថាបនាក្នុងការកែលម្អនូវចំណុចខ្វះខាតដែលកើតមាននៅក្នុងសារណានេះ ហើយយើងខ្ញុំនឹងប្តេជ្ញាចិត្តយ៉ាងមុតមាំថានឹងយកនូវបទពិសោធន៍អំពី ការចុះកម្មសិក្សាលើការអនុវត្តការងារជាក់ស្តែងនេះមកធ្វើការប្រៀបធៀបជាមួយនឹងទ្រឹស្តីដែលមាននៅក្នុងបទដ្ឋានគតិយុត្តនានា ដើម្បីរៀបចំនូវឯកសារសារណាបញ្ចប់ការសិក្សានេះឱ្យកាន់តែមានភាពល្អប្រសើរព្រមទាំងដើម្បីចូលរួមចំណែកក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើកំណែទម្រង់វិស័យច្បាប់និងប្រព័ន្ធយុត្តិធម៌ឱ្យទទួលបានការទុកចិត្តពីប្រជាពលរដ្ឋទៅលើការបម្រើសេវាយុត្តិធម៌ឱ្យបានល្អប្រសើរនិងត្រឹមត្រូវតាមច្បាប់កំណត់។ ជាចុងក្រោយ យើងខ្ញុំសូមជូនពរ លោក លោកស្រី សាស្ត្រាចារ្យ និងសិស្សនិស្សិតដែលកំពុងសិក្សា ក៏ដូចជាបញ្ចប់ការសិក្សាទាំងអស់គ្នាឱ្យជួបតែសំណាងល្អ សុខភាពល្អ និង ទទួលបានជោគជ័យគ្រប់ភារកិច្ច។

# មាតិកា

**ទំព័រ**

**សេចក្ដីផ្ដើម** ........ ១

**១. បុព្វហេតុនៃការស្រាវជ្រាវ** ........ ១

**២. ចំណោទបញ្ហានៃការដោះស្រាយ** ........ ២

**៣. គោលបំណងនៃការស្រាវជ្រាវ** ........ ២

**៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ** ........ ២

**៥. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ** ........ ៣

**៦. សារៈសំខាន់នៃប្រធានបទ** ........ ៣

**៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ** ........ ៣

**ជំពូកទី១ សញ្ញាណគតិយុត្តនៃសិទ្ធិ**

**១.១ និយមន័យនៃសិទ្ធិ** ........ ៤

ក. ដូចម្ដេចដែលហៅថាសិទ្ធិ? ........ ៤

ខ. អ្វីទៅជាសិទ្ធិដែលទទួលបានក្នុងការជម្រះក្ដីដោយយុត្តិធម៌នៅកម្ពុជា? ........ ៤

**១.២. លិខិតបទដ្ឋាននានា ទាក់ទងនឹងសិទ្ធិមនុស្ស** ........ ៥

**១.២.១ លិខិតបទដ្ឋានគតិយុត្តអន្តរជាតិនៃសិទ្ធិមនុស្ស** ........ ៥

ក. សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស ........ ៥

ខ. កតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និង នយោបាយ ........ ៧

**១.២.២. លិខិតបទដ្ឋានគតិយុត្តជាតិនៃសិទ្ធិមនុស្ស** ........ ៩

ក. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ........ ៩

ខ. ក្រមនីតិវិធីព្រហ្មទណ្ឌ ........ ៩

គ. ក្រមនីតិវិធីរដ្ឋប្បវេណី ........ ១១

ឃ.ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី ........ ១១

ង. ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ........ ១២

## ជំពូកទី២

## សិទ្ធិជាមូលដ្ឋាននៃការទទួលបានការជំនុំជម្រះដែលច្បាប់ទទួលស្គាល់


**២.១ សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទដែលជានីតិជន** ........ ១៤
**២.១.១ សិទ្ធិទទួលបានមុនពេលជម្រះក្តី** ........ ១៤
ក. សិទ្ធិសន្មតទុកជាមុនថាគ្មានទោស ........ ១៥
ខ. សិទ្ធិពាក់ព័ន្ធ នឹងការចាប់ខ្លួន និងការឃុំខ្លួន ........ ១៥
គ. សិទ្ធិទទួលដឹងពីបទចោទប្រកាន់ និងសិទ្ធិទទួលបានការការពារខ្លួន ........ ១៦
ឃ. សិទ្ធិទទួលបានជំនួយពីមេធាវីការពារក្តី ........ ១៧
ង.សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ........ ១៨
ច. សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យាពេល ........ ១៩
ឆ. សិទ្ធិទទួលបានការពន្យល់ប្រាប់ពីសិទ្ធិរបស់ជនជាប់ចោទ ........ ២០
ជ. សិទ្ធិដឹងពីថ្ងៃជំនុំជម្រះក្តី ........ ២១
**២.១.២. សិទ្ធិទទួលបានអំឡុងពេលសវនាការ** ........ ២១
ក. សិទ្ធិទទួលបានតុលាការឯករាជ្យ មិនលំអៀង ........ ២១
ខ. សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ........ ២២
គ. សិទ្ធិមានវត្តមាននៅពេលសវនាការ ........ ២៣
ឃ. សិទ្ធិទទួលបានការបកប្រែ និងអ្នកបច្ចេកទេសនៅពេលបើកសវនាការ ........ ២៣
ង. សិទ្ធិបង្ហាញភស្តុតាង សិទ្ធិហៅ និងសាកសួរសាក្សី ........ ២៤
**២.១.៣. សិទ្ធិទទួលបានក្រោយពេលជំនុំជម្រះ** ........ ២៤
ក. សិទ្ធិរួចផុតពីការដាក់ខ្លួនក្នុងការចោទប្រកាន់ ........ ២៤
ខ. សិទ្ធិទទួលបានការលើកលែងការចោទប្រកាន់ និងបន្ធូរបន្ថយទោស ........ ២៥
គ. សិទ្ធិទទួលបានសេរីភាព និងការដោះលែង ........ ២៥
ឃ. សិទ្ធិធ្វើពាក្យបណ្តឹងទាស់ និង សេចក្តីសម្រេចរបស់តុលាការ ........ ២៦
ង. សិទ្ធិទទួលបានសំណងមានប្រសិទ្ធិភាព ........ ២៨
**២.២. សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទដែលជាអនីតិជន** ........ ២៩
ក. និយមន័យ ........ ២៩
ខ. លក្ខខណ្ឌពិសេស និងសិទ្ធិរបស់អនីតិជននៅគ្រប់ដំណាក់កាលជម្រះក្តី ........ ៣០

គ. សិទ្ធិទទួលបានសវនាការជាអសាធារណៈ ....................................................................................................៣៣
**២.៣. សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី** ........................................................................................................................៣៣
ក. សិទ្ធិតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ........................................................................................................៣៤
ខ. សិទ្ធិដាក់ភស្តុតាង ពិនិត្យភស្តុតាង និងសាក្សី ......................................................................................................៣៤
គ. សិទ្ធិដាក់បណ្តឹងជិតជិត ...................................................................................................................................៣៥
ឃ. សិទ្ធិទាមទារសំណងជួសជុលព្យសនកម្ម ...................................................................................................៣៥

## ជំពូកទី៣

## បញ្ហាប្រឈមក្នុងការទទួលបានការជម្រះក្តីដោយយុត្តិធម៌ និងដំណោះស្រាយ

**៣.១ ការរំលោភសិទ្ធិជនជាប់ចោទដែលជានីតិជន និងអនីតិជន** .......................................................................៣៧
ក. ការឃុំខ្លួនបណ្តោះអាសន្នលើសការកំណត់ ...........................................................................................................៣៧
ខ. ការធ្វើទារុណកម្ម ឬបង្ខំឱ្យសារភាព ................................................................................................................៣៨
គ. បញ្ហាការយល់ដឹងពីសិទ្ធិរបស់ជនជាប់ចោទ .......................................................................................................៤០
ឃ. កត្តាជីវភាព .........................................................................................................................................................៤១
ង. កង្វះខាតមេធាវី .................................................................................................................................................៤១
ច. កង្វះខាតប្រព័ន្ធផ្សព្វផ្សាយ ...................................................................................................................................៤២
ឆ. បញ្ហាប្រឈមផ្សេងៗ ...........................................................................................................................................៤៣
**៣.២. ដំណោះស្រាយក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌** ...................................................................៤៣
ក. ការពង្រឹងលើវិស័យយុត្តិធម៌គ្រប់ដំណាក់កាល ..................................................................................................៤៣
ខ. ការទទួលបានការការពារស្របច្បាប់ដោយច្បាប់ជាតិ និង សន្ធិសញ្ញាអន្តរជាតិនៃកម្ពុជា ...............................៤៤
គ. ពង្រីកប្រព័ន្ធផ្សព្វផ្សាយ ......................................................................................................................................៤៤
ឃ. ការទទួលបានជំនួយផ្នែកច្បាប់ពីគណៈមេធាវី ...................................................................................................៤៥
ង.ការរួមចំណែកពីអង្គការក្រៅរដ្ឋាភិបាល ...........................................................................................................៤៦

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

សេចក្តីសន្និដ្ឋាន .........................................................................................................................................................៤៧
អនុសាសន៍ ...............................................................................................................................................................៤៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១.បុព្វហេតុនៃការស្រាវជ្រាវ

កម្ពុជាជាប្រទេសប្រកាន់យករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញា ដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងនោះដែល កម្ពុជាបានចងក្រងច្បាប់បន្ថែម ដើម្បីការពារប្រយោជន៍សាធារណៈ តម្លាភាព និងភាពជានីតិរដ្ឋ នៅក្នុងសង្គមកម្ពុជា ដែលរួមមាន៖ ក្រមព្រហ្មទណ្ឌ ក្រមនិតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់ពិសេសផ្សេងៗផងដែរ។ តួយ៉ាងរដ្ឋធម្មនុញ្ញានៃកម្ពុជាក៏បានទទួលស្គាល់សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិ ដោយគោរពលើគោលការណ៍គោរពសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ ពីព្រោះមនុស្សទាំងអស់កើតមកមានសេរីភាព និងសមភាពក្នុងសេចក្តីថ្លៃថ្នូរ និងសិទ្ធិពីការរំលោភបំពានដោយប្រការណាមួយ។ បុគ្គលគ្រប់រូបមានសិទ្ធិរស់រានមានជីវិតប្រកបមុខរបរ ដែលខ្លួនពេញចិត្តបានដោយសេរី។ ទន្ទឹមនឹងនោះ ច្បាប់បានធានារ៉ាប់រងការការពារពួកគេពីការរំលោភបំពានគ្រប់ករណី ដែលបង្ករឱ្យមានការខូចខាត។ មានន័យថាបុគ្គលគ្រប់រូបទទួលបានយុត្តិធម៌ ដោយសមភាព ដោយគ្មានបុគ្គលណាម្នាក់ត្រូវបានរើសអើង ដោយសារពណ៌សម្បុរវណ្ណៈ ជាតិសាសន៍ ភេទ សាសនា មតិនយោបាយ ឬកម្រិតជីវភាពរបស់បុគ្គល។

ដោយយល់ឃើញពីភាពចាំបាច់ដែលបុគ្គលគួរទទួលបាន ជាពិសេសនៅពេលបុគ្គលណាម្នាក់ត្រូវបានចោទប្រកាន់ក្នុងបទល្មើសណាមួយ រដ្ឋត្រូវស្វែងរកយុត្តិធម៌ និងផ្តន្ទាទោសជនដែលបានបង្ករអំពើអសន្តិសុខ ដើម្បីការពារសន្តិសុខប្រជាពលរដ្ឋរបស់ខ្លួន ក៏ដូចជាសង្គមជាតិទាំងមូល និង សិទ្ធិមនុស្សដែលត្រូវបានការពារដោយនីតិរដ្ឋ។ ពលរដ្ឋមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិទទួលការការពារពីច្បាប់ស្មើៗគ្នា ក្នុងការរកដំណោះស្រាយ ជាក់ស្តែងនៅចំពោះមុខសាលាជម្រះក្តី ដែលមានសមត្ថកិច្ចចំពោះអំពើទាំងឡាយណាដែលរំលោភសិទ្ធិមូលដ្ឋានរបស់ខ្លួន។ ពោលជនដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវបានសន្មតទុកជាមុនថាមានទោសចាំបាច់ទទួលបានសិទ្ធិការពារខ្លួន ។ ការចាប់ខ្លួន ឃុំខ្លួនឬនិរទេសខ្លួន ការធ្វើទារុណកម្ម ឬបង្ខំឱ្យសារភាព ត្រូវបានហាមឃាត់។ ជាក់ស្តែងក្នុងសង្គមយើងបច្ចុប្បន្នមានបញ្ហាចោទគួរឱព្រួយបារម្ភពាក់ព័ន្ធនឹងសិទ្ធិរបស់ជនជាប់ចោទ ដែលត្រូវបានអង្គការសង្គមស៊ីវិលជាច្រើនលើកឡើងថា ប្រជាជនជនកម្ពុជាភាគច្រើនជាជនសាមញ្ញមិនមានចំណេះដឹងគ្រប់គ្រាន់ពាក់ព័ន្ធនឹងនីតិវិធីតុលាការដែលបានបង្កើតឱ្យមានជាផលវិបាកជាច្រើន គឺការបាត់បង់នូវផលប្រយោជន៍លើសិទ្ធិដែលច្បាប់បានផ្តល់ឱ្យពួកគាត់ ។ ជាមួយគ្នានេះផងដែរក៏មានចោទជាបញ្ហាពីមន្ត្រីតុលាការមួយចំនួនមិនគោរពតាមមុខងាររបែរជារំលោភអំណាច និងមានភាពលំអៀងក្នុងចំណាត់ការដែលអំពើទាំងនេះបង្កជាការរំលោភលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជម្រះក្តីដោយយុត្តិធម៌។ ដោយសារបញ្ហាចោទខាងលើនេះ ទើបនាងខ្ញុំនិងដៃគូ សម្រេចជ្រើសរើសយកប្រធាន

បទ *"សិទ្ធិទទួលការជម្រះក្តីដោយយុត្តិធម៌នៅកម្ពុជា"* នេះមកធ្វើការសិក្សា និងបង្ហាញក្នុងករណីនីតិវិធីព្រហ្មទណ្ឌ ដែលស្របនឹងគោលនយោបាយរដ្ឋាភិបាលក្នុងការកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។

## ២. ចំណោទបញ្ហានៃការដោះស្រាយ

តាមការរៀបរាប់ខាងលើបានបង្ហាញឱ្យឃើញថា សិទ្ធិទទួលបានការជម្រះក្តីដោយយុត្តិធម៌នៅតែជាចំណុចមួយដ៏សំខាន់ ដែលជនជាប់ចោទក៏ដូចជាជនរងគ្រោះត្រូវតែទទួលដឹងពីសិទ្ធិរបស់ខ្លួន ដែលមានការការពារដោយច្បាប់ ដើម្បីបញ្ចៀសពីការរំលោភបំពានសិទ្ធិរបស់បុគ្គលទាំងនោះដោយប្រការណាមួយ។ ដូចនេះដើម្បីជាចង្កៀងបំភ្លឺផ្លូវក្នុងដំណើរការស្វែងរកដំណោះស្រាយនូវសិទ្ធិទទួលបានការជម្រះក្តីដោយយុត្តិធម៌នៅកម្ពុជា ក្នុងនាមជាអ្នកអានគួរគប្បីយល់ដឹងពីចំណោទបញ្ហាដែលបានចោទឡើងថាៈ

**តើសិទ្ធិនោះត្រូវបានគោរព និងការពារដោយច្បាប់អ្វីខ្លះនៅកម្ពុជា?**

**តើជនជាប់ចោទអាចទទួលបានសិទ្ធិអ្វីខ្លះ ដើម្បីទទួលបានការជម្រះក្តីដោយយុត្តិធម៌ ក្នុងពេលអនុវត្តសិទ្ធិ, តើមានបញ្ហាប្រឈមអ្វីខ្លះ?**

## ៣. គោលបំណងនៃការស្រាវជ្រាវ

ដោយមើលឃើញពីចំណុចខ្វះចន្លោះក្នុងការអនុវត្តច្បាប់ដែលបង្ករឡើងដោយមន្ត្រីអនុវត្តច្បាប់មួយចំនួនប្រើសិទ្ធិអំណាចហើយបានរំលោភបំពានទៅលើសិទ្ធិរបស់ជនជាប់ចោទនៅក្នុងដំណាក់កាលដំបូងៗ មុនបញ្ជូនខ្លួនទៅតុលាការ ក៏ដូចជាមើលឃើញពីការយល់ដឹងអំពីច្បាប់ឬពីសិទ្ធរបស់ប្រជាពលរដ្ឋនៅមានកម្រិត ទើបធ្វើឱ្យគាត់ភ័យខ្លាចមិនហ៊ានតបត ជាហេតុនាំឱ្យទទួលនូវភាពអយុត្តិធម៌។ ដូច្នេះហើយបានជាយើងខ្ញុំនឹងលើកយកប្រធានបទដែលស្តីពី **"សិទ្ធិទទួលបានការជម្រះក្តីដោយយុត្តិធម៌នៅកម្ពុជា"** មកធ្វើការសិក្សា បកស្រាយដោយលើកឡើងពីច្បាប់ជាតិ រួមទាំងច្បាប់អន្តរជាតិខ្លះៗ មានសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និង កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ ដើម្បីជាជំនួយសម្រាប់អ្នកអាន ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចាប់ផ្តើមពីការជ្រើសរើសប្រធានបទស្រាវជ្រាវរកឯកសារដែរពាក់ព័ន្ធ រហូតដល់ការសរសេរសារណានេះឡើង គឺក្នុងគោលបំណងធ្វើការរៀបរាប់ឱ្យកាន់តែលម្អិត និងស៊ីជម្រៅពាក់ព័ន្ធនឹងប្រធានបទមួយនេះ។ ជាពិសេសសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ។ ចំពោះការស្រាវជ្រាវទៅលើប្រធានបទមួយនេះបានផ្អែកទៅលើបញ្ញត្តិច្បាប់ជាតិ ស្តីពីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧ ច្បាប់ស្តីពីយុត្តិធម៌នៃអនីតិជន ២០១៦ និងការរួមចំណែកនូវច្បាប់អន្តរជាតិ ស្តីពីសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ១៩៤៨ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ១៩៦៦ និងច្បាប់ផ្សេងៗទៀតដែលជាប់ពាក់ព័ន្ធទៅនឹងការជំនុំជម្រះក្តីដោយយុត្តិធម៌។ ក្នុងនោះដែរ ក៏មានការចូលរួមពីសំណាក់សាស្ត្រាចារ្យ លោកគ្រូ

អ្នកគ្រូ ក្នុងការជួយជ្រោមជ្រែង ផ្តល់គំនិត មតិយោបល់ និងចង្អុលបង្ហាញទិសដៅដល់ការសិស្សក្នុងការស្រាវជ្រាវឱ្យចំគោលដៅ។ ក្នុងនោះដែរ ការសិក្សាទៅលើប្រធានបទមួយនេះបានធ្វើឱ្យខ្ញុំផ្ទាល់ ក៏ដូចជាមិត្តរួមក្រុមមានការយល់ដឹងកាន់តែច្បាស់ពាក់ព័ន្ធនិងក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ផ្សេងៗទៀតរហូតដល់បញ្ចប់។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវរបស់យើងខ្ញុំបានប្រើវិធីសាស្ត្រមួយចំនួនដូចជា៖

- បានធ្វើការសិក្សា និងអង្កេតការសវនាការដោយផ្ទាល់នៅសាលាដំបូងរាជធានីភ្នំពេញ លើប្រធានបទ "សិទ្ធិទទួលបានការជម្រះក្តីដោយយុត្តិធម៌" ជាមួយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា។
- បានធ្វើការសិក្សា និងអនុវត្តជាក់ស្តែងលើសវនាការប្រឌិត ក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីស្វែងយល់ពីតថភាពពិតជាមួយអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា។
- ធ្វើការស្រាវជ្រាវឯកសារ នៅតាមបណ្ណាល័យ គេហទំព័រ ទស្សនាវដ្តី ប្រព័ន្ធអ៊ីនធឺណេត សៀវភៅនានាតួយ៉ាងសៀវភៅមេរៀនរបស់សាស្ត្រាចារ្យ និងឯកសារមួយចំនួន។ល។

## ៦.សារសំខាន់នៃប្រធានបទ

កន្លងមកយើងតែងតែឃើញសៀវភៅសរសេរពីប្រធានបទជាច្រើន ពោលប្រធានបទ **"សិទ្ធិទទួលបានការជម្រះក្តីដោយយុត្តិធម៌នៅកម្ពុជា"** កម្រមានអ្នកលើកមកស្រាវជ្រាវ ដោយសារតែការលំបាកនូវការកំណត់នូវសិទ្ធិដែលច្បាប់បានផ្តល់ឱ្យ។ ដោយមើលឃើញភាពកម្រនូវអត្ថបទខាងលើ យើងខ្ញុំក៏សម្រេចលើកប្រធានបទខាងលើយកមកសរសេរនិងតាក់តែងឡើង ក្នុងន័យឱ្យសិស្សានុសិស្ស និស្សិត ដើម្បីទុកជាឯកសារយោងឬអត្ថបទស្រាវជ្រាវ។ ជាពិសេស សិស្ស និស្សិតគួរតែបានដឹងពីសិទ្ធិសំខាន់ៗរបស់បុគ្គលដែលជា ជនជាប់ចោទ ឬជនរងគ្រោះ គ្រប់ដំណាក់កាលនីតិវិធីដែលបុគ្គល គួរទទួលបាន ដើម្បីទទួលបានយុត្តិធម៌។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបបញ្ហាទៅនឹងបញ្ហាគតិយុតខាងលើ យើងខ្ញុំធ្វើការរៀបចំរចនាសម្ព័ន្ធនៃការស្រាវជ្រាវប្រធានបទនេះ ដែលផ្តោតទៅលើ ៣ជំពូកធំៗ ដូចជា៖

**ជំពូកទី ១ សញ្ញាណគតិយុត្តនៃសិទ្ធិ**

**ជំពូកទី ២ សិទ្ធិជាមូលដ្ឋាននៃការទទួលបានការជំនុំជម្រះដែលច្បាប់ទទួលស្គាល់**

**ជំពូកទី ៣ បញ្ហាប្រឈមក្នុងការទទួលបានការជម្រះក្តីដោយយុត្តិធម៌ និងដំណោះស្រាយ**

# ជំពូកទី១

# សញ្ញាណគតិយុត្តនៃសិទ្ធិ

# ជំពូកទី១

# សញ្ញាណគតិយុត្តនៃសិទ្ធិ

## ១.១ និយមន័យនៃសិទ្ធិ

### ក. ដូចម្តេចដែលហៅថាសិទ្ធិ?

សិទ្ធិ គឺជាបុព្វសិទ្ធិដែលច្បាប់ទទួលស្គាល់ចំពោះបុគ្គល ដើម្បីប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ខ្លួនព្រមទាំងទទួលបានការការពារដោយច្បាប់។[1] សិទ្ធិ គឺជាអំណាចដែលប្រគល់ឱ្យបុគ្គលអាចធ្វើអ្វីៗបាន តែស្ថិតក្រោមព្រំដែននៃច្បាប់។ សិទ្ធិ អំណាចទទួលស្គាល់តាមមធ្យោបាយច្បាប់ដែលអាចទទួលការពារ ឬ ទាមទារផលប្រយោជន៍ណាមួយ។

ម្យ៉ាងទៀតសិទ្ធិគឺជាអាវុធសម្រាប់ការពារមនុស្ស នៅពេលមានការរំលោភបំពានណាមួយកើតឡើង។ [2] ប្រជាពលរដ្ឋមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីកិច្ច ដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ និន្នាការ នយោបាយ ដើមកំណើត ។[3]

អំណាចពិសេសរបស់មនុស្ស ដែលធម្មជាតិផ្តល់ឱ្យតាំងពីកំណើត សម្រាប់ឱ្យមនុស្សការពារខ្លួនពីការរំលោភបំពាន និងការការពារដែលច្បាប់បានកំណត់ ដែលមនុស្សម្នាក់មានសិទ្ធិពេញលេញក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន ក្នុងការរស់នៅប្រចាំថ្ងៃ ប៉ុន្តែការប្រើសិទ្ធិ សេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់អ្នកដទៃឡើយ និងគោរពតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់។ មានន័យថា រដ្ឋផ្តល់សិទ្ធិយ៉ាងពេញលេញសម្រាប់បុគ្គល ក្នុងការរស់រានមានជីវិត និងធានាការពារសិទ្ធិ ពីការរំលោភបំពានសិទ្ធិរបស់បុគ្គលភាព។ ដូចនេះ យើងអាចនិយាយបានថា ព្រំដែននៃសិទ្ធិ គឺដើម្បីការពារសិទ្ធិរបស់មនុស្សជាតិ។

### ខ. អ្វីទៅជាសិទ្ធិដែលទទួលបានក្នុងការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា?

សិទ្ធិដែលទទួលបានការជម្រះក្តីដោយយុត្តិធម៌នៅកម្ពុជា គឺជាសិទ្ធិមនុស្សដែលជាសសរស្តម្ភស្នូលនៃប្រព័ន្ធយុត្តិធម៌។ សិទ្ធិនេះអនុវត្តទាំងនៅក្នុងដំណើរការនីតិវិធីរដ្ឋប្បវេណី និងនីតិវិធីព្រហ្មទណ្ឌ។ ចំពោះដំណើរការនីតិវិធីព្រហ្មទណ្ឌ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺជាបណ្តុំនៃសិទ្ធិបុគ្គលផ្សេងៗច្រើនដែលហៅថា "**សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌**" ហើយវាផ្តល់សិទ្ធិដល់មនុស្សគ្រប់រូបដែលរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌទទួលបាននូវការប្រព្រឹត្តដោយយុត្តិធម៌ និងស្មើភាពគ្នា ខណៈដែលរដ្ឋជាអ្នកកំណត់នូវពិរុទ្ធភាព

---

[1] សាស្ត្រាចារ្យ ង៉ឹន ធឿន, *នីតិសិទ្ធិមនុស្ស*, សាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១១, ទំព័រ ១

[2] ដកស្រាយពីឯកសារបង្រៀនរបស់លោកស្រីសាស្ត្រាចារ្យ ម៉ឹង វ៉ាន់ឌី ,*និយមន័យនៃសិទ្ធិ*, ទំព័រទី២

[3] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣, មាត្រា៣១

ឬភាពគ្មានទោសរបស់ពួកគេ [4] "**យុត្តិធម៌**" ក៏ដូចជា "**សិទ្ធិទទួលបានការជម្រះក្ដីដោយយុត្តិធម៌**" គឺមានលក្ខណៈស្មុគស្មាញខ្លាំង ដោយសារតែវាមានអត្ថន័យច្រើន និងខុសៗគ្នាទៅតាមទស្សនៈផ្សេងៗគ្នានៃច្បាប់ក្រមសីលធម៌ នយោបាយ សេដ្ឋកិច្ច និងសង្គមវិទ្យា។ សិទ្ធផ្សេងៗមួយចំនួនរបស់បុគ្គលម្នាក់ៗ ដែលហៅកាត់ថា "**សិទ្ធិទទួលបានការជម្រះក្ដីដោយយុត្តិធម៌**" ជាអាទិ៍ ដែលរួមបញ្ចូលនូវគ្រប់ដំណើរការនីតិវិធីដែលរួមមានសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីរៀបចំការពារក្ដីសិទ្ធិទទួលបានសេចក្ដីសម្រេចជាសាធារណៈ និងមានសំអាងហេតុ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់។

ជំពូកនេះនឹងពន្យល់បន្ថែមពីការអនុវត្តនៅកម្ពុជា និងច្បាប់ដែលពាក់ព័ន្ធនឹងសិទ្ធិទទួលបានការជម្រះក្ដីដោយយុត្តិធម៌ ជាពិសេសរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្រមនីតិវិធីព្រហ្មទណ្ឌ ឬច្បាប់ស្ដីពីយុត្តិធម៌អនីតិជននៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងនោះ សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលពាក់ព័ន្ធនឹងសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស កតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏បានលើកឡើងទាក់ទងនឹងប្រធានបទនេះផងដែរ។

## ១.២. លិខិតបទដ្ឋាននានា ទាក់ទងនឹងសិទ្ធិមនុស្ស

ការបង្កើតឱ្យមានលិខិតបទដ្ឋានជាតិ និងអន្តរជាតិដើម្បីការពារប្រជាពលរដ្ឋ ពិតជាសំខាន់ក្នុងការអនុវត្តច្បាប់។ រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានចងក្រងប្រព័ន្ធច្បាប់ និងអនុម័តលិខិតុបករណ៍ជាច្រើនប្រភេទ ដើម្បីការពារផលប្រយោជន៍សាធារណៈ ក៏ដូចសន្តិសុខជាតិ។ ដើម្បីឆ្លើយតបទៅតាមជំពូកខាងលើ លិខិតបទដ្ឋានទាក់ទិននឹងសិទ្ធិមនុស្សសំខាន់ៗ ដែលត្រូវយកមកបកស្រាយដូចជា លិខិតបទដ្ឋានគតិយុត្តអន្តរជាតិរួមមានៈ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស កតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏ដូចជាការរួមចំណែកពីច្បាប់ជាតិមានដូចជាៈ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី និងច្បាប់ស្ដីពីយុត្តិធម៌អនីតិជន។

### ១.២.១ លិខិតបទដ្ឋានគតិយុត្តអន្តរជាតិនៃសិទ្ធិមនុស្ស

#### ក. សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស

សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្សនេះ ត្រូវបានអនុម័ត និងប្រកាសដោយសេចក្ដីសម្រេចនៃមហាសន្និបាតអង្គការសហប្រជាជាតិលេខ ២១៧ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។ សេចក្ដីប្រកាសនេះជាសេចក្ដីប្រកាសមុនគេ និងមានលក្ខណៈគ្រឹះ ដែលផ្ដល់នូវគំលែគតិយុត្តដែលឱ្យប្រទេសទាំងអស់គោរពតាម ហើយអ្វី

[4] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, "*សិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌*," n.d., https://sithi.org/km/fair-trial-rights.

ដែលពិសេសនោះ គឺសេចក្ដីប្រកាសនេះមានឧត្តមគតិរួម ដែលប្រជាពលរដ្ឋគ្រប់ប្រទេស និងប្រជាជាតិទាំងអស់ត្រូវធ្វើឱ្យបានសម្រេច ដើម្បីឱ្យបុគ្គលគ្រប់រូប និងអង្គការទាំងអស់ខិតខំប្រឹងប្រែងធានាឱ្យមានការទទួលស្គាល់ និងការអនុវត្តជាសកល។ ចំពោះគោលដៅនៃការបង្កើតសេចក្ដីប្រកាសនេះ មួយផ្នែកធំ គឺសំដៅទៅលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌តាមរយៈសេចក្ដីប្រកាសនេះ បានផ្ដល់នូវសិទ្ធិជាច្រើនមានដូចជា ការហាមឃាត់មិនឱ្យធ្វើទារុណកម្ម ឬការប្រព្រឹត្តអំពើ ឃោរឃៅ ឬការផ្ដន្ទាទោសឱ្យជនណាម្នាក់បាត់បង់តំលៃជាមនុស្សនោះឡើយ។ យ៉ាងណាមិញ ច្បាប់នៃប្រទេសនីមួយៗត្រូវសរសេរឱ្យច្បាស់ថា ប្រជាជនទាំងអស់គ្នាអាចទាមទារសិទ្ធិជាមនុស្ស របស់ពួកគេតាមរយៈច្បាប់ ហើយគ្មាននរណាម្នាក់ត្រូវបានបដិសេធចោលនោះឡើយ។ ម្យ៉ាងទៀត ជនគ្រប់រូបអាចសុំការជួយពីអ្នកជំនាញដែលមានចំណេះផ្នែកច្បាប់ នៅពេលដែលសិទ្ធិតាមផ្លូវច្បាប់របស់ពួកគាត់មិនត្រូវបានគោរព។[5] ជាក់ស្ដែង គឺសំដៅទៅលើសិទ្ធិទទួលបានការប្រឹក្សា ឬជំនួយផ្នែកច្បាប់ មានមេធាវីក្នុងការការពារតាមផ្លូវតុលាការ។ លើសពីនេះទៅទៀត ជនគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិទទួលការការពារពីច្បាប់ស្មើៗគ្នាដោយគ្មានការរើសអើង។[6] ពោលគឺ មិនគិតពីជនជាតិ ឋានៈ សាសនា ពណ៌សម្បុរ មាន ឬក្រ ប្រុសឬស្រី អ្នកមានអំណាច ឬអ្នកទន់ខ្សោយដែលជាប្រជាជនសាមញ្ញនោះឡើយ ហើយក៏គ្មាន ជនណាម្នាក់ត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬនិរទេសខ្លួនតាមអំពើចិត្តឡើយ ។[7] ការឃុំខ្លួន ឬការឃាត់ខ្លួនគឺ ជាការបំបិទសិទ្ធិ និងសេរីភាពក្នុងការដើរហើរ ដែលវាជាបញ្ហាមួយគួរឱ្យព្រួយបារម្ភនឹងអាចបណ្ដាល ឱ្យមានភាពអសន្តិសុខ ប្រសិនបើមានការឃាត់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្ត។ ក្នុងនោះផងដែរ តាមរយៈសេចក្ដីប្រកាសនេះ និងដោយសមធម៌ ដើម្បីសម្រេចលើសិទ្ធិ និងកាតព្វកិច្ច និងភាពសមហេតុផលនៃការចោទប្រកាន់ទាំងឡាយខាងបទល្មើសព្រហ្មទណ្ឌមកលើខ្លួន។[8] ពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌយោងតាមមាត្រា ១១ នៃសេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស ចែងថាជនណាដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវសន្មតថាជា ជនគ្មានទោសរហូតដល់ពិរុទ្ធ ត្រូវបានរកឃើញនៅក្នុងសវនាការជាសាធារណៈ ដែលមានការធានាចាំបាច់ដើម្បីឱ្យជននោះអាចការពារខ្លួន។ ការសន្មតទុកជាមុនថាគ្មានទោស គឺជាគោលការណ៍នៃសិទ្ធិយ៉ាងសំខាន់ក្នុងការគោរពសិទ្ធិមនុស្សដោយផ្ដល់នូវភាពស្អាតស្អំ យុត្តិធម៌ និងរក្សានូវកេរ្តិ៍ឈ្មោះដល់ជននោះ។ សរុបមក សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស គឺជាគោលការណ៍គ្រឹះដែលបណ្ដាលឱ្យមាននូវកតិកាសញ្ញាអន្តរជាតិមួយ

[5] សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨, ខួបលើកទី៦០, បោះពុម្ពផ្សាយដោយការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ការិយាល័យប្រចាំ នៅព្រះរាជាណាចក្រកម្ពុជា។

[6] សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨, មាត្រា៧

[7] សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨, មាត្រា៥

[8] សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨, មាត្រា១០

ទៀត ត្រូវបានប្រសូត្រឡើង គឺកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក្នុងគោលបំណង បញ្ជាក់ឱ្យកាន់តែច្បាស់អំពីសិទ្ធមនុស្សក្នុងការទទួលបានការជម្រះក្តីដោយយុត្តិធម៌ដូចដែលប្រធានបទ យើងខ្ញុំបានលើកឡើងខាងលើ។ យើងខ្ញុំ នឹងលើកយកមកចង្អុលបង្ហាញជូននូវចំណុចសំខាន់ៗ តែប៉ុណ្ណោះ ចំពោះកតិកាសញ្ញាស្តីពីសិទ្ធពលរដ្ឋ និងសិទ្ធិនយោបាយ ដើម្បីឱ្យប្រិយមិត្តអ្នកអានបានយល់នូវប្រធានបទខាងលើកាន់តែច្បាស់យើងខ្ញុំសូមបកស្រាយតាមលំដាប់ដូចតទៅនេះ៖

### ខ. កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅឆ្នាំ១៩៩២។ លិខិតូបករណ៍នេះ ក៏បានធ្វើការលើកឡើងអំពីសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ផងដែរ។ កាតព្វកិច្ចរដ្ឋជាភាគីនៃកតិកាសញ្ញានេះ ត្រូវតែធានាថាគ្មាននរណាត្រូវបានរំលោភបំពាននូវសិទ្ធិរបស់ខ្លួន ហើយរដ្ឋជាភាគីត្រូវតែ ធានាថាជនដែលប្តឹងឱ្យមានការដោះស្រាយពីការរំលោភបែបនេះ មានសិទ្ធិឱ្យអាជ្ញាធរមានសមត្ថកិច្ចខាងយុត្តិធម៌ ខាងរដ្ឋបាល ឬនីតិបញ្ញត្តិ អាជ្ញាធរមានសមត្ថកិច្ចដទៃទៀត សម្រេចឱ្យខ្លួនដោយយោងតាមច្បាប់របស់រដ្ឋ ដើម្បីបង្កើតលទ្ធភាពនៃការប្តឹងទៅតុលាការផងដែរ។ គោលបំណងដែលលើកយកកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មកពន្យល់បន្ថែមពីលើសេចក្តីប្រកាសជាសកលស្តីពីមនុស្ស ដោយហេតុថាសេចក្តីប្រកាសជាគ្រោងឆ្អឹងលិខិតូករណ៍ស្តីពីសិទ្ធិ ហើយកតិកាសញ្ញាជាអ្នកបំពេញបន្ថែម អត្ថន័យឱ្យបានក្បោះក្បាយ ក្នុងវិធានការពារសិទ្ធិពលរដ្ឋ មានន័យថា[9] ជនគ្រប់រូប ត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជំរះក្តីដោយតុលាការឯករាជ្យ មិនលំអៀង ដែលបង្កើតឡើងដោយច្បាប់ ក្នុងរឿងក្តីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួន ក្នុងវិស័យព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីយកិច្ចក្នុងវិស័យរដ្ឋប្បវេណី។ ចំណែកផ្នែកសារព័ត៌មាន និងសាធារណៈជន អាចមិនឱ្យចូលរួមសវនាការដើម្បីការពារផលប្រយោជន៍នៃទំនៀមទំលាប់ល្អ សណ្តាប់ធ្នាប់សាធារណៈ ឬសន្តិសុខជាតិក្នុងសង្គមប្រជាធិបតេយ្យ ឬនៅពេលផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគី តម្រូវឱ្យធ្វើដូច្នេះ ឬក្នុងកម្រិតដែលចាំបាច់បំផុតតាមការយល់ឃើញរបស់តុលាការ ក្នុងស្ថានភាពពិសេសដែលថាការធ្វើជាសាធារណៈនឹងនាំឱ្យខូចដល់ផលប្រយោជន៍យុត្តិធម៌។ ចំណុចសំខាន់ក្នុងច្បាប់នេះ ក្នុងការសម្រេចសេចក្តី ចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នាយ៉ាងពេញលេញដូចខាងក្រោម ត្រូវទទួលបានព័ត៌មានភ្លាមៗ និងដោយលម្អិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន នឹងជាភាសាមួយដែលជននោះចេះអាចយល់បាន។ ការផ្តល់ពេលវេលាគ្រប់គ្រាន់ និងសម្ភារបរិក្ខាគ្រប់គ្រាន់

[9] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨, មាត្រា១៤

សម្រាប់រៀបចំការការពារខ្លួន និងការឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង។ ពេលវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយផ្នែកច្បាប់ តាមការជ្រើសរើសរបស់ខ្លួន និងត្រូវបានប្រាប់ឱ្យដឹងអំពីសិទ្ធិនេះ ប្រសិនបើខ្លួនគ្មានជំនួយផ្នែកច្បាប់ ហើយត្រូវទទួលបានជំនួយការ ច្បាប់សម្រាប់ខ្លួនក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើ ដោយឥតបង់ថ្លៃនៅគ្រប់ករណីបែបនេះ បើជនជាប់ចោទគ្មានមធ្យោបាយគ្រប់គ្រាន់ ដើម្បីចំណាយទៅលើជំនួយការច្បាប់ទេ ។

ក្នុងនោះ ក៏បានរំលេចឡើងទាក់ទងជាមួយនឹងផ្នែកព្រហ្មទណ្ឌ ដើម្បីឱ្យជនដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌត្រូវទទួលបាននូវការសន្មតទុកជាមុន ថាគ្មានទោស រហូតដល់ពិរុទ្ធរបស់ខ្លួនត្រូវបានរកឃើញនៅក្នុងការកំណត់របស់ច្បាប់។ យ៉ាងណាមិញ ក្នុងកតិកាសញ្ញានេះក៏បានដកស្រង់យកចំណុចខ្លះៗ ដែលជានីតិវិធីក្នុងការអនុវត្តចំពោះ អនីតិជនដែល មិនទាន់ដល់នីតិភាពទទួលខុសត្រូវព្រហ្មទណ្ឌតាមច្បាប់កំណត់នូវវិធានការអប់រំមួយចំនួន ដើម្បីអាចកែខៃស្ថានការណ៍ដែលយ៉ាប់យឺនឱ្យបានល្អឡើងវិញ។ ជនជាប់ចោទជា អនីតិជន ត្រូវដាក់ផ្សេងពីនីតិជន ហើយការជំនុំជម្រះត្រូវធ្វើឡើងឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន[10]។ កតិកាសញ្ញានេះ បានផ្តល់ការគាំទ្រឱ្យមនុស្សគ្រប់ជាតិសាសន៍ទទួលបាននូវការជម្រះក្តីប្រកបដោយភាពយុត្តិធម៌ ព្រមទាំងគ្មានការរើសអើងដោយប្រការណាមួយឡើយ។ ត្រឡប់មកវិញ ការចេញសាលក្រម អំពីសំណុំរឿងព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ត្រូវប្រកាសជាសាធារណៈ លើកលែងតែមានការប៉ះពាល់ដល់ផលប្រយោជន៍អនីតិជន តម្រូវផ្សេងពីនេះ ឬរឿងក្តី ទំនាស់គ្រួសារ ឬអាណាព្យាបាលរបស់អនីតិជន ។

វិធានអនុវត្តចំពោះយុវជន-យុវនារីដែលមិនទាន់មាននីតិភាពតាមច្បាប់កំណត់ ត្រូវគិតដល់អាយុ និងអត្ថប្រយោជន៍នៃការអប់រំរបស់ពួកគេឡើងវិញ ជនគ្រប់រូបដែលជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌត្រូវមានសិទ្ធិសុំឱ្យសាលាក្តីជាន់ខ្ពស់ ពិនិត្យទៅលើការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោសឡើងវិញស្របតាមច្បាប់ បញ្ញត្តិនេះត្រូវបានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧ នៅពេលជនណាម្នាក់ ត្រូវបានប្រកាសឱ្យជាប់ពិរុទ្ធពីបទព្រហ្មទណ្ឌជាស្ថាពរ ហើយក្រោយមកការប្រកាសឱ្យជាប់ពិរុទ្ធនេះ ត្រូវបានបដិសេធ ឬត្រូវបានលើកលែងទោស ដោយហេតុថា អង្គហេតុថ្មី ឬបានរកឃើញថ្មី ដែលបញ្ជាក់យ៉ាងច្បាស់ថា មានការខុសឆ្គងពីសំណាក់មន្ត្រីអនុវត្តច្បាប់ ឬតុលាការ ជនដែលទទួលរងគ្រោះដោយសារការដាក់ទោសនេះ ត្រូវទទួលសំណងស្របតាមច្បាប់ លើកលែងតែមានការកំណត់ បង្ហាញថាការមិនលាតត្រដាងអាថ៌កំបាំងនៃការពិតទាន់ពេល បណ្តាលមកពីជននោះទាំងស្រុង ឬមួយផ្នែក ។

[10] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨, មាត្រា១០ (ខ)

### ១.២.២. លិខិតបទដ្ឋានគតិយុត្តជាតិនៃសិទ្ធិមនុស្ស

#### ក. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ តាមឋានានុក្រមនៃបទដ្ឋានគតិយុត្ត រដ្ឋធម្មនុញ្ញ ជាច្បាប់កំពូលដែលច្បាប់ផ្សេងទៀតត្រូវអនុលោមតាម ពោលគឺយករដ្ឋធម្មនុញ្ញធ្វើជាច្បាប់គ្រឹះ ឬជាមូលដ្ឋាននៅក្នុងការបង្កើតឱ្យមានច្បាប់ដ៏ទៃៗទៀត។ យោងតាម មាត្រា៥១ និងជំពូកទី១១ នៃរដ្ឋធម្មនុញ្ញក៏បានចែងយ៉ាងច្បាស់អំពីការបែងចែកអំណាចទាំងបី ដែលមាន អំណាចតុលាការជាអំណាចឯករាជ្យ និងជាអ្នកអនុវត្តច្បាប់។ ការបែងចែកអំណាចគឺជាគោលការណ៍សំខាន់ ដើម្បីពង្រឹងនូវភាពជានីតិរដ្ឋ និង ការគោរពសិទ្ធិមនុស្សជាពិសេសសិទ្ធិក្នុងការការពារខ្លួនតាមផ្លូវតុលាការ ដើម្បីធានាបាននូវភាពយុត្តិធម៌ជូនប្រជាជនពាក់ព័ន្ធនឹងបណ្តឹងព្រហ្មទណ្ឌ។ មូលដ្ឋាននៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំដៅទៅលើការគោរពនូវសិទ្ធិមនុស្សឱ្យទទួលបាននូវភាពស្មើគ្នាចំពោះមុខច្បាប់។[11] គ្មានជនណាម្នាក់ត្រូវបានរំលោភបំពានលើរូបរាងកាយឡើយ ការចាប់ខ្លួន ឬឃាត់ខ្លួន ត្រូវតែធ្វើឡើងដោយស្របច្បាប់ ការបង្ខំឱ្យសារភាពដោយគំរាមកំហែង ឬដោយប្រើទារុណកម្ម គឺមិនត្រូវទុកជាភស្តុតាងដើម្បីបង្ហាញពីពិរុទ្ធភាពឡើយ។[12] លើសពីនេះទៅទៀត ហាមមិនឱ្យធ្វើទារុណកម្ម ឬធ្វើបាបលើរូបរាងកាយចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារឡើយ ជនគ្រប់រូប ត្រូវចាត់ទុកថាជាជនគ្មានទោស រហូតដល់តុលាការសម្រេចជាស្ថាពរ ថាជននោះមានពិរុទ្ធភាព។ម្យ៉ាងទៀត តុលាការត្រូវប្រើគោលការណ៍វិមតិសង្ស័យ ដែលត្រូវបានជាប្រយោជន៍របស់ជនជាប់ចោទ រហូតទាល់តែមានភស្តុតាងជាក់លាក់ និងស៊ីចង្វាក់គ្នាដែលគ្មានចំណុចណាមួយខ្វះចន្លោះ ចំពោះអំពើដែលជននោះបានប្រព្រឹត្ត។ ជារួមគ្មានចំណុចសង្ស័យតូចណាមួយអំពីភាពគ្មានពិរុទ្ធភាពរបស់ជននោះទេ ប្រសិនបើតុលាការនៅតែមានការសង្ស័យទៅលើពិរុទ្ធភាពរបស់ជនជាប់ចោទនោះ តុលាការត្រូវសម្រេចជាប្រយោជន៍ទៅជនជាប់ចោទ ដោយដោះលែងឱ្យជននោះមានសេរីភាព។[13]

#### ខ. ក្រមនីតិវិធីព្រហ្មទណ្ឌ

ក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានប្រកាសឱ្យប្រើនៅ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ស្របនឹងប្រធានបទនេះមានមាត្រាមួយចំនួនដែលចែងសង្កត់ធ្ងន់ពាក់ព័ន្ធ នឹងសិទ្ធិរបស់ជនជាប់ចោទទៅតាមនីតិវិធីនីមួយៗ ក៏ដូចជាមុខងាររបស់មន្ត្រីតុលាការក្នុងការធានានូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ក្រមនីតិវិធីជាច្បាប់

[11] ដូចលេខ ៣

[12] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣, មាត្រា ៣៨

[13] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៣៥០ កថាខណ្ឌ៣

យ៉ាងសំខាន់ក្នុងការពារសិទ្ធិជនជាប់ចោទ និងជនរងគ្រោះដែល ផ្តល់នូវការជំនុំជម្រះមួយប្រកបដោយភាពយុត្តិធម៌ពោលគឺ ភាពយុត្តិធម៌មិនមែនទើបតែមានពេលជំនុំជម្រះនោះទេ ប៉ុន្តែគឺវាមានទំនាក់ទំនងគ្នាយ៉ាងជិតស្និតពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀតចាប់តាំងពីពេលចាប់ខ្លួន ឃាត់ខ្លួន និងឃុំខ្លួននៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ រហូតដល់ពេលជំនុំជម្រះក្តីនៅក្នុងពេលសវនាការ។

ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌមានទំនាក់ទំនងគ្នា ក្នុងការកំណត់ពីបទល្មើស ឬសិទ្ធិអំណាចរបស់មន្ត្រីតុលាការក្នុងការអនុវត្តច្បាប់។ នីតិវិធី ជាគោលការណ៍អនុវត្តជាក់ស្តែងក្នុងការកំណត់បទល្មើសព្រហ្មទណ្ឌ។ ក្នុងនោះដែរ នគរបាលយុត្តិធម៌ ត្រូវបានចាត់ទុកជាបុគ្គលសាធារណៈដែលបម្រើឱ្យផលប្រយោជន៍សាធារណៈ មានកាតព្វកិច្ចទទួលពាក្យបណ្តឹងទាមទារ រួមសហការណ៍ក្នុងការពិនិត្យលើបទល្មើសទាំងឡាយ (បទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ)។ ការចូលរួមពិនិត្យក្នុងការស៊ើបអង្កេតជាក់ស្តែង និងការស៊ើបអង្កេតបឋមក្នុងការកំណត់ភស្តុតាង និងឃាត់ខ្លួនជនសង្ស័យតាមនីតិវិធីច្បាប់។ ចំពោះដំណើរការជំនុំជម្រះក្តី បន្តពីនគរបាលយុត្តិធម៌ ត្រូវផ្តល់អំណាចទៅឱ្យព្រះរាជអាជ្ញា។

ព្រះរាជអាជ្ញា ជាម្ចាស់បណ្តឹងអាជ្ញាក្នុងសំណុំរឿងព្រហ្មទណ្ឌ។ គាត់ជាបុគ្គលម្នាក់ដើរតួក្នុងការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះ និងផ្តល់ភាពត្រឹមត្រូវលើការចោទប្រកាន់បុគ្គលណាម្នាក់ថាបានចូលរួមក្នុងការប្រព្រឹត្តបទល្មើស។ ការកំណត់សិទ្ធិ និងកាតព្វកិច្ចតាមមុខងារយុត្តិធម៌ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីឱ្យដំណាក់កាលស្វែងរកយុត្តិធម៌អាចឈានដល់ការទទួលបានជំនុំជម្រះក្តីស្របតាមតម្លាភាព ត្រូវបានផ្តល់ដោយច្បាប់ក៏ដូចជាបានចែងក្នុង ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា។ ក្នុងដំណាក់កាលនេះ បើព្រះរាជអាជ្ញារកឃើញថាជនត្រូវចោទមិនជាប់សង្ស័យក្នុងអំពើជាបទល្មើស ឬមានវិមតិសង្ស័យជាផលប្រយោជន៍របស់ជនជាប់ចោទ ដែលតម្រូវឱ្យដោះលែងជននោះឱ្យមានសេរីភាព ពីការឃុំឃាំង។ ក្រឡេកមកមើលដំណាក់កាលចៅក្រមស៊ើបសួរវិញ ក្រោយពីការបញ្ចប់ការពិនិត្យវិនិច្ឆ័យរបស់ព្រះរាជអាជ្ញា ឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរក្នុងការបើកការស៊ើបសួរ និងស្វែងរកភស្តុតាង ដាក់បន្ទុក ឬដោះបន្ទុក។ ចំណែកឯ ចៅក្រមជំនុំជម្រះត្រូវតែកាត់សេចក្តីដោយភាពយុត្តិធម៌ មិនលំអៀង និងអព្យាក្រឹត្យ។ មានតែចៅក្រមជំនុំជម្រះម្នាក់គត់ ដែលមានសិទ្ធិ និងអំណាចចេញសាលក្រម ឬសាលដីកា។ ជាមួយគ្នានេះ ក៏មានច្បាប់មួយចំនួនទៀតដែលជួយបំពេញបន្ថែម ធ្វើយ៉ាងណាឱ្យគ្រប់ការជំនុំជម្រះអាចទទួលបាននូវភាពយុត្តិធម៌ និងធ្វើឱ្យប្រទេសកម្ពុជាក្លាយជានីតិរដ្ឋយ៉ាងពិតប្រាកដ។ ហេតុនេះ វាជាការចាំបាច់ណាស់ដែលត្រូវសិក្សា និងយល់ដឹងអំពីតួនាទី ឬមុខងាររបស់មន្ត្រីតុលាការទាំង ៤ ដំណាក់កាល ពោលគឺចាប់តាំងពីមន្ត្រីនគរបាលយុត្តិធម៌ រហូតដល់ចៅក្រមជំនុំជម្រះពីព្រោះពួកគាត់គឺជាអ្នកធានា ក្នុងការស្វែងរកការពិត។

### គ. ក្រមនីតិវិធីរដ្ឋប្បវេណី

ក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបានអនុម័តដោយរដ្ឋសភានៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៦។ ក្នុងនោះក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសកម្ពុជាជាច្បាប់ទូទៅដែលបទបញ្ញត្តិអំពីនីតិវិធីរដ្ឋប្បវេណី សម្រាប់អនុវត្តនៅព្រះរាជាណាចក្រកម្ពុជា។ បណ្តឹងរដ្ឋប្បវេណីមានគោលបំណង "**ការពារសិទ្ធិឯកជន**"។ នៅក្នុងនីតិរដ្ឋ ភាគីមានសិទ្ធិប្តឹងទៅតុលាការ និងទាមទារការការពារដោយការជំនុំជម្រះ នៅពេលដែលសិទ្ធិរបស់ខ្លួន ត្រូវបានបំពានដោយភាគីម្ខាងទៀត។[14] មានន័យថាជនគ្រប់រូបត្រូវបានធានានូវសិទ្ធិពឹងពាក់តុលាការចំពោះវិវាទរដ្ឋប្បវេណី។ ពោលគឺតុលាការត្រូវប្រឹងប្រែង ដើម្បីរ៉ាប់រងថាបណ្តឹងរដ្ឋប្បវេណីឱ្យប្រព្រឹត្តទៅប្រកបដោយភាពយុត្តិធម៌ និងដោះស្រាយយ៉ាងឆាប់រហ័ស ដោយភាពសុចរិត និងស្មោះត្រង់។ ក្នុងនោះដែរ នីតិវិធីដែលសំខាន់ជាងគេបំផុតនៅក្នុងក្រមនេះ គឺសិទ្ធិទាមទារឱ្យតុលាការបើកការសាកសួរ ប្រកបដោយប្រសិទ្ធិភាព ដោយមិនលំអៀងទៅភាគីណាម្នាក់។ តុលាការត្រូវកំណត់ពេលវេលាមួយសមរម្យ ដែលភាគីទាំងសងខាងអាចបង្ហាញខ្លួន ក្នុងពេលសវនាការ និងគោរពតាមគោលការចំពោះមុខស្មើភាពគ្នា។ ការកោះហៅភាគី គឺជាការធានានូវឱកាសក្នុងការបញ្ចេញមតិយោបល់របស់ខ្លួន ពាក់ព័ន្ធទៅនឹងសំណុំរឿង ដែលត្រូវសម្រេចសេចក្តីដោយតុលាការនៅក្នុងបណ្តឹងរដ្ឋប្បវេណី និងការឆ្លើយតបទៅនឹងមតិយោបល់របស់ភាគីម្ខាងទៀត។

ប៉ុន្តែ ក្នុងករណីពិសេសមួយចំនួន ការសម្រេចសេចក្តីអាចត្រូវបានធ្វើឡើងមុនពេល ដោយមូលហេតុសុចរិតភាពរបស់ភាគី ដើម្បីបង្ការពីផលអវិជ្ជមានដែលនាំឱ្យខូចប្រយោជន៍ ដោយសារការសម្រេចសេចក្តីបែបនេះបាន។[15] សិទ្ធិទាមទារក្នុងសាកសួរ បានត្រូវតែធ្វើឡើងដោយការកោះហៅភាគី ទាំងសងខាងឱ្យមកបង្ហាញខ្លួនតាមកាលបរិច្ឆេទតែមួយដែលបានកំណត់ ដើម្បីឱ្យភាគីផ្តល់នូវសក្ខីកម្មការពារផលប្រយោជន៍របស់ខ្លួននៅចំពោះមុខតុលាការ។ ហេតុនេះហើយបានជាមានបញ្ញត្តិចែងថា ជាគោលការណ៍ តុលាការត្រូវវិនិច្ឆ័យ ដោយគោរពតាមគោលការណ៍ចំពោះមុខ ពោលគឺត្រូវការហៅភាគីសងខាងថ្លែងពីអំណះអំណាងរបស់ខ្លួន និងជជែកតតាំងគ្នាទៅវិញទៅមក។[16]

### ឃ. ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

ច្បាប់នេះត្រូវបានបង្កើតឡើង ដើម្បីធានាអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ការផ្សព្វផ្សាយឱ្យប្រជាជនបានដឹងអំពីសិទ្ធិរបស់ខ្លួន តាមរយៈអ្នកជំនាញមានវិជ្ជាជីវៈមេធាវីដែលជាបុគ្គលឯកជន និងឯករាជ្យ

[14] ក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៦, មាត្រា២

[15] ក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៦, មាត្រា៣២៣ (១)

[16] ក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៦, មាត្រា៣(២)

ចូលរួមចំណែកយ៉ាងសកម្មដើម្បីផ្តល់ប្រឹក្សា និងការពារសិទ្ធិរបស់ជនជាប់ចោទដែលជាកូនក្តីរបស់ខ្លួន។ ពោល គឺមេធាវីដើរតួយ៉ាងសំខាន់ក្នុងការការពារ និងធានាថាសិទ្ធិរបស់កូនក្តីរបស់ខ្លួនមិនត្រូវបានរំលោភបំពាន។

វិជ្ជាជីវៈមេធាវី គឺជាវិជ្ជាជីវៈ ឯករាជ្យ និងសេរីដែលចូលរួមបម្រើវិស័យយុត្តិធម៌។[17] ដោយយោង តាមច្បាប់នេះតម្រូវឱ្យមេធាវីទាំងអស់ មានកាតព្វកិច្ចជួយការពារជនក្រីក្រតាមបែបបទនៃបទបញ្ជាផ្ទៃក្នុង ហើយជួយការពារអតិថិជនរបស់ខ្លួន។ [18] មេធាវីត្រូវតែរក្សាការសម្ងាត់របស់កូនក្តីខ្លួនជាដាច់ខាត និងការពារកូនក្តីតាមសតិសម្បជញ្ញៈរបស់ខ្លួន និងដោយមានការយល់ព្រមពីកូនក្តី នូវអ្វីដែលខ្លួនត្រូវលើកឡើងដើម្បីការការពារផលប្រយោជន៍របស់អនីតិជនផង និងផលប្រយោជន៍របស់ភាគីផង។[19] មេធាវីអាចតំណាងកូនក្តី តាមរយៈការយល់ព្រមពីកូនក្តី ឬជួយការពារកូនក្តីនៅគ្រប់សាលាជម្រះក្តី និងគ្រប់ដំណាក់កាលនៃនីតិវិធី។ [20]

លើសពីនេះទៅទៀត គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក៏បានបង្កើតក្រមសីលធម៌ វិជ្ជាជីវៈមេធាវីដើម្បីឱ្យវិជ្ជាជីវៈមេធាវី កាន់តែទទួលបានការទុកចិត្តពីកូនក្តី និងប្រជាជន។ ជាក់ស្តែង ប្រសិនបើមេធាវីត្រូវបានជ្រើសរើសជាអ្នកការពារកូនក្តីក្នុងសំណុំរឿងណាមួយ គឺត្រូវការពាររហូតដល់បញ្ចប់នីតិវិធីសវនាការលុះត្រាតែមានការបដិសេធពីកូនក្តីផ្ទាល់ ដោយមិនត្រូវការជំនួយមេធាវី ឬដោយសារមូលហេតុចាំបាច់។ ប៉ុន្តែក្នុងលក្ខខណ្ឌដែលជនជាប់ចោទជាអនីតិជន ត្រូវមានវត្តមានមេធាវីជាដាច់ខាត។

ក្នុងករណីមេធាវីមានមូលហេតុផ្ទាល់ខ្លួន ដែលមិនអាចការពារក្តីបន្តទៀតបាន នោះគាត់ត្រូវជូនដំណឹងដល់កូនក្តីជាបន្ទាន់ ដើម្បីកុំឱ្យប៉ះពាល់ដល់ប្រយោជន៍កូនក្តី ។ ប្រសិនបើមេធាវីការពារក្តីមានកូនក្តីច្រើននាក់ ក្នុងសំណុំរឿងតែមួយ មេធាវីត្រូវគិតពីផលប្រយោជន៍រួម មិនត្រូវគិតតែពីផលប្រយោជន៍របស់កូនក្តីណាម្នាក់ ឬក៏ណាមួយឡើយ ។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌក៏បានលើបន្ថែមទៀត ពាក់ព័ន្ធសិទ្ធិ និងកាតព្វកិច្ចមេធាវីការពារក្តី ដោយអនុញ្ញាតឱ្យមេធាវីការពារក្តីរបស់ខ្លួន ដោយគ្មានការជ្រៀតជ្រែក ឬងការគំរាមកំហែងពីតតិយជន ដែលមិនជាប់ពាក់ព័ន្ធនឹងរឿងក្តីឡើយ។

### ង. ច្បាប់ស្តីពីយុត្តិធម៌អនីតិជន

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦។ ច្បាប់នេះបង្កើតឡើង ដើម្បីការពារសិទ្ធិអនីតិជនតាមរយៈវិធាន យន្តការ និងនីតិវិធីទាំងឡាយដែលត្រូវគោរព និង អនុវត្ត

[17] ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥, មាត្រា១

[18] ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥, មាត្រា២៩

[19] ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥, មាត្រា៥០

[20] ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥, មាត្រា២

ដោយហ្មត់ចត់ ព្រមទាំងវិធាននៃការកំណត់ទោស ក្នុងករណីអនីតិជនប្រព្រឹត្តបទល្មើស។ អនីតិជនសំដៅដល់ជនដែលមានអាយុតិចជាង ១៨ (ដប់ប្រាំបី) ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស។[21] ការការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់អនីតិជនដែលប្រព្រឹត្តបទល្មើស និងគាំទ្រដល់ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មអនីតិជនទៅក្នុងសង្គម និងសហគមន៍ ហើយធានាការពារផលប្រយោជន៍។[22] អនីតិជនក៏បានទទួលនូវសិទ្ធិក្នុងការជំនុំជម្រះក្តីដោយយុត្តធម៌ដូចជានីតិជនដែរ ប្រសិនបើនៅពេលដែលមានអនីតិជនជាប់សង្ស័យ ឬត្រូវចោទប្រកាន់ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើស ត្រូវទទួលបានសិទ្ធជាមូលដ្ឋានក្នុងនីតិវិធីច្បាប់ដូចជា សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកសិទ្ធិ ទទួលបានការឱ្យដំណឹងអំពីបទចោទប្រកាន់ សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់ សិទ្ធិទទួលបានជំនួយពីមេធាវី សិទ្ធិបង្ហាញភស្តុតាង សិទ្ធិស្នើសុំឱ្យកោះហៅសាក្សី និងសួរសាក្សី សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ សិទ្ធិស្នើសុំឱ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ សិទ្ធិផ្សេងៗទៀតដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន។[23] អនីតិជនដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌមិនត្រូវសន្មតថាមានទោសឡើយ។ ប៉ុន្តែតុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ។ អនីតិជន ក៏ទទួលបានជំនួយសេវាផ្នែកសង្គមកិច្ច គឺភ្នាក់ងារនេះដែលត្រូវជួបអនីតិជននៅគ្រប់ដំណាក់កាលនៃនីតិវិធី ជាពិសេសនៅដំណាក់កាលដំបូងរបស់មន្ត្រីនគរបាលយុត្តិធម៌ និងនៅក្នុងពន្ធនាគារដើម្បីប្រមូលព័ត៌មានវាយតម្លៃ និងផ្តល់សេវាបន្ទាន់ដល់អនីតិជន[24] ហើយនៅគ្រប់ដំណាក់កាលនៃនីតិវិធីច្បាប់អនីតិជនត្រូវបានទទួលការយកចិត្តទុកដាក់ពីសំណាក់មន្ត្រីអនុវត្តច្បាប់ ។

[21] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦, មាត្រា៤

[22] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦, មាត្រា១

[23] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦, មាត្រា៦

[24] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦, មាត្រា១១

# ជំពូកទី២

# សិទ្ធិជាមូលដ្ឋាននៃការទទួលបានការជំនុំជម្រះដែលច្បាប់ទទួលស្គាល់

# ជំពូកទី២

# សិទ្ធិជាមូលដ្ឋាននៃការទទួលបានការជំនុំជម្រះដែលច្បាប់ទទួលស្គាល់

## ២.១ សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទដែលជានីតិជន

សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទដែលជានីតិជន សំដៅលើសិទ្ធិដែលច្បាប់បានប្រគល់ឱ្យបុគ្គលគ្រប់រូបនូវការធានា ដោយគ្មានទោសណាមួយត្រូវយកមកអនុវត្តបានឡើយ ប្រសិនបើទោសនោះមិនត្រូវបានប្រកាសដោយតុលាការ។[25] រាល់ជនជាប់ចោទទាំងអស់ ដែលប្រឈមមុខនឹងសវនាការមានសិទ្ធិជាមូលដ្ឋានដែលគ្មានជនណាម្នាក់អាចបំពានបានឡើយ។

ដោយហេតុថា សិទ្ធិទទួលបានការជម្រះក្តីដោយយុត្តិធម៌ ត្រូវបានតាមដានគ្រប់ដំណាក់កាលចាប់តាំងពីពេលចាប់ខ្លួនរហូតដល់ពេលចេញសាលក្រមសម្រេចសេចក្តីចុងក្រោយ ការវិភាគទិដ្ឋភាពនីមួយៗនៃសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌នៅកម្ពុជា ក្នុងចំណុចនេះត្រូវបានបែងចែកជា ៣ ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌ៖ សិទ្ធិទទួលបានមុនពេលជម្រះក្តី សិទ្ធិទទួលបានអំឡុងពេលជំនុំជម្រះក្តី និងសិទ្ធិទទួលបានក្រោយពេលជំនុំជម្រះក្តី។ គ្រប់ដំណាក់កាលទាំងអស់ ត្រូវធានាថាមិនត្រូវរំលោភបំពានសិទ្ធិ ប្រសិនបើមានការរំលោភបំពាននៅក្នុងដំណាក់កាលណាមួយអាចនាំឱ្យប៉ះពាល់ដល់ដំណាក់កាលមួយផ្សេងទៀត។

### ២.១.១ សិទ្ធិទទួលបានមុនពេលជម្រះក្តី

សិទ្ធិទទួលបានមុនពេលជំនុំជម្រះក្តី ត្រូវធានាឱ្យបាននូវតម្លាភាពដែលបុគ្គលគ្រប់រូបទទួលបានក្នុងគ្រប់ដំណាក់កាល រួមមានក្នុងដំណាក់កាល៖ សមត្ថកិច្ចមន្ត្រីយុត្តិធម៌ ដំណាក់កាលអយ្យការ ដំណាក់កាលចៅក្រមស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ។ ជនជាប់ចោទ ឬជនត្រូវចោទមានសិទ្ធិការពារខ្លួនតាមបញ្ញត្តិច្បាប់។[26] ដោយគ្មានជនណាម្នាក់ត្រូវបានចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តបានឡើយ លើកលែងតែមានហេតុផល និងភស្តុតាងត្រឹមត្រូវ ដែលស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់។

ដូចនេះ យើងគួរប្បីយល់ដឹងពីសិទ្ធិសំខាន់ៗ របស់បុគ្គលទាំងអស់មុនពេលសវនាការរួមមាន សិទ្ធិទទួលបានការសន្និតជាមុនថាគ្មានទោស រហូតទាល់តែត្រូវរកឃើញថាមានពិរុទ្ធ សិទ្ធិទទួលបានដំណឹងពីបទចោទប្រកាន់ សិទ្ធិដឹងពីមូលហេតុនៃការចាប់ខ្លួន ការឃុំខ្លួន ជាអាទិ៍។

---

[25] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩, មាត្រា៦

[26] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣,មាត្រា៣៨ (៧), សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨, មាត្រា ៧

**ក.សិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោស**

ជនជាប់ចោទណាក៏ដោយ ត្រូវចាត់ទុកជាមនុស្សអត់ទោស គ្មានបុគ្គលណាម្នាក់ ត្រូវបានដាក់ទោសតាមអំពើចិត្តចំពោះអំពើដែលខ្លួនមិនបានប្រព្រឹត្តនោះឡើយ ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ[27]។ អំពើចោទប្រកាន់ថាជាបទល្មើសណាមួយ ត្រូវតែបង្ហាញឱ្យឃើញពីពិរុទ្ធភាពដោយតុលាការ។

ដូចគ្នាផងដែរ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយបានចែងផងដែរថា ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌត្រូវបានសន្មតជាមុនថា ជាជនគ្មានទោសរហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់តាមច្បាប់។ [28] មានន័យថា ចៅក្រមពុំអាចធ្វើការ វិនិច្ឆ័យរឿងក្តីមុនសម្រេចសេចក្តី ចំណែកឯមន្ត្រីសាធារណៈមិនត្រូវធ្វើសេចក្តីថ្លែងការណ៍ បង្ហាញពីភាពមានពិរុទ្ធរបស់ជនជាប់ចោទណាម្នាក់ មុនពេលសវនាការជំនុំជម្រះក្តីត្រូវបានបញ្ចប់ជាស្ថាពរឡើយ។

បទប្បញ្ញត្តិដែលហាមឃាត់ "សូចនាករខាងក្រៅនៃពិរុទ្ធភាព" រួមបញ្ចូលៈ សិទ្ធិជនជាប់ចោទស្លៀកពាក់ស៊ីវិលធម្មតា និងមិនត្រូវបានដាក់ច្រវ៉ាក់ ឬខ្នោះក្នុងពេលជំនុំជម្រះក្តី។ ជនជាប់ចោទគ្រប់រូបមានសិទ្ធិ ត្រូវបាននាំខ្លួនទៅកាន់តុលាការ ក្នុងរូបភាព និងកិត្តិយសជាជនគ្មានទោស។ នៅពេលដែលជនជាប់ចោទ ត្រូវបានបង្ខំឱ្យចូលរួមក្នុងសវនាការ ក្នុងឯកសណ្ឋានជាអ្នកទោស ឬជាប់ខ្នោះ ឬច្រវ៉ាក់នោះ អាចនាំឱ្យមានការយល់ថាជនជាប់ចោទមានពិរុទ្ធភាព ឬជាឧក្រិដ្ឋជនដ៏គ្រោះថ្នាក់ និងអាចជះឥទ្ធិពលដោយចេតនា ឬអចេតនា ទៅលើការវិនិច្ឆ័យរបស់ចៅក្រមជំនុំជម្រះ និងលទ្ធភាពនៃរឿងក្តី។

**ខ. សិទ្ធិពាក់ព័ន្ធនឹងការចាប់ខ្លួន និងការឃុំខ្លួន**

គ្មានជនណាម្នាក់ ត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬនិរទេសខ្លួន ដោយបំពានឡើយ [29] មានន័យថាបុគ្គលគ្រប់ជាតិសាសន៍ ត្រូវទទួលបានការការពារ និងគោរពសេចក្តីថ្លៃថ្នូររបស់បុគ្គលដោយច្បាប់។ ក្នុងលក្ខខណ្ឌនៃការចាប់ខ្លួនជនសង្ស័យ មន្ត្រីនគរបាលត្រូវប្រាប់អំពីមូលហេតុនៃការចាប់ខ្លួនជាចាំបាច់ ដោយហេតុថា ជនសង្ស័យគួរទទួលបានសិទ្ធិប្រាស្រ័យទាក់ទងសាច់ញាតិ និងស្វែររកជំនួយពីមេធាវីការពារក្តីរបស់ខ្លួន។ នៅពេលដែលមានការឃាត់ខ្លួនបុគ្គលណាម្នាក់ នគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនទៅព្រះរាជអាជ្ញា ព្រមទាំងត្រូវបញ្ជូនគ្រប់ភស្តុតាងទាំងអស់ដែលនាំឱ្យមានការឃាត់ខ្លួននោះផងដែរ។ [30]

[27] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣, មាត្រា៣៨

[28] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦, មាត្រា១៤(២)

[29] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨, មាត្រា៩

[30] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា៩៦

គ្រប់ករណីទាំងអស់ក្នុងរយៈពេល ៤៨ ម៉ោង ក្រោយពីការចាប់ខ្លួននគរបាលត្រូវប្រាប់ដល់ជនសង្ស័យភ្លាមៗនូវសិទ្ធិរបស់គាត់ក្នុងការមានមេធាវី រឺបុគ្គលណាម្នាក់ដែលខ្លួនជ្រើសរើស លើកលែងតែជនទាក់ទិនក្នុងរឿងជាមួយគ្នា រយៈពេល ២៤ ម៉ោង។ ក្នុងករណីជនសង្ស័យមានបញ្ហាសុខភាពណាមួយ អាចមានសិទ្ធិស្នើរសុំជំនួយពីគ្រូពេទ្យ ប្រសិនបើជាជនបរទេសអាចមានអ្នកបកប្រែពេលធ្វើកំណត់ហេតុ ដើម្បីជួយសម្រួលដល់ជនជាប់ចោទ។ រាល់ជនសង្ស័យទាំងអស់ត្រូវបានគេប្រាប់អំពីសិទ្ធិនោះភ្លាម បន្ទាប់ពីឃុំខ្លួន និងចាប់ខ្លួន។ ជនសង្ស័យដែលត្រូវបានចាប់ខ្លួន ឬឃុំខ្លួនទាំងអស់ ត្រូវបានទទួលនូវមធ្យោបាយសមស្រប សម្រាប់អនុវត្តនូវសិទ្ធិនេះ ដូច្នេះវាគឺជាភារកិច្ចទទួលខុសត្រូវរបស់នគរបាលទទួលបន្ទុកចាប់ខ្លួន និងឃុំខ្លួន យ៉ាងហោចណាស់ផ្តល់នូវតារាងបញ្ជីឈ្មោះមេធាវី និងប្រើប្រាស់ទូរស័ព្ទ ដើម្បីផ្តល់លទ្ធភាពឱ្យជនសង្ស័យអាចទំនាក់ទំនងមេធាវី។ [31] ជនជាប់ឃុំឃាំងត្រូវមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការពិគ្រោះយោបល់គ្នាជាមួយទីប្រឹក្សាច្បាប់របស់ខ្លួន។

សម្រាប់ករណីបទល្មើសជាក់ស្តែង ការឃាត់ខ្លួនជនសង្ស័យត្រូវធ្វើឡើងតាមនីតិវិធីច្បាប់ដែលបានបញ្ញត្តិ និងគោរពតាមថិរវេលានៃការឃាត់ខ្លួន ប្រសិនបើការឃាត់ខ្លួនពុំធ្វើតាមលក្ខខណ្ឌ ដែលបានចែងនោះទេការឃាត់ខ្លួន និងត្រូវទុកជាមោឃៈ។

**គ. សិទ្ធិទទួលដឹងពីបទចោទប្រកាន់ និងសិទ្ធិទទួលបានការការពារខ្លួន**

ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។ [32] ជនដែលត្រូវបានចាប់ខ្លួន មានសិទ្ធិទាមទារឱ្យគេប្រាប់ខ្លួន ឱ្យដឹងភ្លាមៗនូវហេតុផល និងប្រភេទបទល្មើសដែលចោទមកលើខ្លួន។ [33] ដើម្បីស្វែងរកវិធីសាស្ត្រ ឬយុទ្ធសាស្ត្រ សម្រាប់ការពារខ្លួនដោយបានជំនួយពីមេធាវីការពារក្តី។ ពោល ជនជាប់ចោទអាចប្រាស្រ័យទាក់ទងដោយសេរីជាមួយមេធាវីរបស់ខ្លួន នៅក្នុងពន្ធនាគារ ឬនៅក្នុងមណ្ឌលឃុំខ្លួន។ រាល់ការសន្ទនារបស់ជនសង្ស័យ និងមេធាវីការពារត្រូវទុកជាការសម្ងាត់ ដោយគ្មានតតិយជនណាម្នាក់អាចថត ឬស្តាប់បានឡើយ។[34] ប៉ុន្តែក្រៅពីនេះ មិនតម្រូវឱ្យមានមេធាវីទេ គឺអាស្រ័យលើសិទ្ធិរបស់ជនជាប់ចោទគាត់អាចពឹងពាក់មេធាវី ដើម្បីការពារក្តីឱ្យគាត់ក៏បាន ឬក៏មិនមានការពឹងពាក់មេធាវីក៏បាន។ លើសពីនេះទៅទៀត នៅដំណាក់កាលជំនុំជម្រះចាំបាច់ណាស់ចៅក្រមត្រូវតែពន្យល់ប្រាប់អំពីរឿងក្តីបទល្មើសដែលត្រូវចោទ និងសិទ្ធិដែលជនជាប់ចោទមាន។

[31] ច្បាប់ព្រហ្មទណ្ឌអន្តរកាល, មាត្រា ១០, ១៣, ១៧(១)

[32] រដ្ឋធម្មនុញ្ញនៃព្រះរាជណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣, មាត្រា៣៨

[33] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦, មាត្រា៩(២)

[34] ក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា១៤៩

ដោយប្រធានសវនាការប្រាប់ដល់ជនជាប់ចោទឱ្យបានដឹងអំពី អំពើដែលគេចោទប្រកាន់មកលើរូបខ្លួន។[35] ហេតុនេះ ការដឹងអំពីបទល្មើសដែលខ្លួន ត្រូវបានចោទប្រកាន់នេះ មានសារៈសំខាន់ណាស់ ដើម្បីវិភាគពាក់ព័ន្ធនឹងសកម្មភាពដែលខ្លួនបានធ្វើ និងមូលហេតុនៃការចោទប្រកាន់ និងធានាថាជនជាប់ចោទ អាចយល់ពីមូលហេតុដែលខ្លួនត្រូវបានកាត់ទោស។ ស្របពេលនោះដែរ ជនជាប់ចោទអាចតបត ទៅនឹងការឃុំខ្លួនណាមួយ ដែលអាចកើតមាននៅក្នុងរយៈពេលមួយឆាប់រហ័សតាមដែលអាចធ្វើបាន និងក៏ជាឱកាសដែលឱ្យជនជាប់ចោទ ការពារខ្លួនដោយប្រឆាំង និងការចោទប្រកាន់ ដែលគ្មានមូលដ្ឋានច្បាស់លាស់។ [36]

សរុបមក ជនជាប់ចោទមានសិទ្ធិយល់ដឹងពីបទល្មើស ដែលពួកគេត្រូវបានចោទប្រកាន់[37] ពោល គឺបទល្មើសព្រហ្មទណ្ឌដែលគេត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត និងអង្គហេតុដែលនាំឱ្យមាន ការចោទប្រកាន់នោះផងដែរ ហើយជនសង្ស័យក៏ត្រូវតែទទួលបានព័ត៌មាននេះ ក្នុងភាសាមួយដែលគេអាចយល់បាន។ [38]

### ឃ. សិទ្ធិទទួលបានជំនួយពីមេធាវីការពារក្តី

ជនដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ មានសិទ្ធិទទួលបានជំនួយពីមេធាវី។ ជំនួយការពារក្តីពីមេធាវី ដើម្បីធានាថា៖

- ជនជាប់ចោទទទួលបានកិច្ចការពារខាងច្បាប់ល្អបំផុត ពីអ្នកជំនាញដែលមានវិជ្ជាជីវៈ។

- ជនជាប់ចោទទទួលបានជំនួយពីបុគ្គលម្នាក់ ដែលមានសមត្ថភាពពន្យល់ និងការពារផលប្រយោជន៍របស់ខ្លួននៅក្នុងតុលាការ។

- ជនជាប់ចោទគ្រប់រូបមានភាពស្មើគ្នាចំពោះមុខច្បាប់ ហើយភាពយុត្តិធម៌ មិនត្រូវបានផ្តល់ដោយមានភាពរើសអើង។ រដ្ឋធម្មនុញ្ញបានផ្តល់ឱ្យប្រជាពលរដ្ឋគ្រប់រូប នូវសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។ ជំនួយពីមេធាវីត្រូវតែមានដាច់ខាត ក្នុងករណីបទឧក្រិដ្ឋ ឬ ជនជាប់ចោទជាអនីតិជន។[39] ម៉្យាងវិញទៀត តុលាការនឹងចាត់តាំងមេធាវីម្នាក់ បើជនជាប់ចោទ ពុំទាន់បានជ្រើសរើសមេធាវីដោយខ្លួនឯង។ តួយ៉ាង ជនជាប់ចោទអាចជ្រើសរើសការការពារខ្លួនឯងដោយពុំចាំបាច់ទទួលជំនួយពីមេធាវី។ ប្រសិនបើការអនុវត្តសិទ្ធិទទួលបានជំនួយពីមេធាវី

---

[35] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា៣២៥

[36] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, សៀវភៅមគ្គុទេសក៍ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការសង្កេតការណ៍សវនាការ ,ភ្នំពេញ, មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ២០១២, ទំព័រ ១៨។

[37] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា៩៧ និងមាត្រា២៣៥
និង កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦, មាត្រា១៤(៣)(ក)(ច)

[38] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា ៣៣០ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦, មាត្រា១៤(៣)(ច)

[39] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា៣០១

របស់ជនជាប់ចោទ ត្រូវបានរំលោភដោយអំណាចតុលាការ ជននោះប្រាកដជាពុំទទួលបានការជំនុំជម្រះមួយ ដែលស្របទៅតាមគោលការណ៍ជំនុំជម្រះដោយយុត្តិធម៌ឡើយ។ ក្នុងករណីនេះ នៅពេលដែលជនជាប់ចោទ ប្រឈមមុខនឹងការផ្តន្ទាទោសពីបទព្រហ្មទណ្ឌណាមួយ នោះជនជាប់ចោទនឹងពុំមានយុត្តិធម៌ទេ ហើយសិទ្ធិ របស់ជនជាប់ចោទក៏ត្រូវបានរំលោភបំពានផងដែរ។

នៅខណៈដែលជំនួយពីមេធាវី ពុំមានលក្ខណៈដាច់ខាតនៅក្នុងករណីបទមជ្ឈិម នៅតែមានការជម្រុញឱ្យ គោរពគោលការណ៍ស្មើភាពគ្នា ពោលគឺភាគីទាំងអស់នៃរឿងក្តីព្រហ្មទណ្ឌ ត្រូវបានប្រព្រឹត្តដោយស្មើភាពគ្នា ក្នុង បំណងធានាថាភាគីទាំងអស់មានឋានៈស្មើគ្នានៅក្នុងនីតិវិធី ដើម្បីបង្ហាញពីអំណះអំណាងនៅក្នុងអំឡុងពេល សវនាការទាំងមូល។

**ង. សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង**

បុគ្គលគ្រប់រូប ដែលរងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ មានសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាព ពីពិរុទ្ធភាព ឬការផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង (ឬសិទ្ធិមិនឆ្លើយដាក់បន្ទុកលើខ្លួនឯង)។ សិទ្ធិនេះ អនុវត្តមុន ដំណាក់កាលជំនុំជម្រះ និងនៅពេលជំនុំជម្រះ[40] មានន័យថា ជនជាប់ចោទ មិនត្រូវបានបង្ខិតបង្ខំឱ្យសារភាព ឬ បង្ខំឱ្យផ្តល់ភស្តុតាងប្រឆាំងនឹងខ្លួនឯងឡើយ ក្នុងការអនុវត្ត គឺត្រូវធ្វើឡើងដោយគ្មានការបង្ខិតបង្ខំ មិនថាដោយ ផ្ទាល់ ឬដោយប្រយោល តាមរយៈ ផ្លូវកាយ ឬផ្លូវចិត្ត។ តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៨ [41] បានចែងថា ច្បាប់ការពារមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។ ការទទួលសារភាព ដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយ ឬផ្លូវចិត្ត មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ។

ការសារភាព ឬចម្លើយណាមួយត្រូវទទួលតាមរយៈការបង្ខិតបង្ខំ ការធ្វើទារុណកម្ម ឬទម្រង់ផ្សេងៗទៀត នៃការធ្វើបាប នោះត្រូវបានដកចេញពីភស្តុតាងដែលបង្ហាញនៅពេលសវនាការ ឬចាត់ទុកជាមោឃៈ។ [42] ដូចនេះ គ្មានជនណាម្នាក់អាចត្រូវបានបង្ខំ ឱ្យផ្តល់សក្ខីកម្ម ភស្តុតាង ដែលអាចប្រើប្រាស់យកទៅកាត់ទោស ពួកគេវិញឡើយ។ ជនជាប់ចោទគ្មានភារកិច្ចណាមួយ ដើម្បីបង្ហាញថាខ្លួនមានទោសនោះទេ។ ទៀតសោធន៍ ការ

---

[40] អង្គការលើកលែងទោសអន្តរជាតិ, "*សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានជម្រះក្តីដោយយុត្តិធម៌*" (ឆ្នាំ២០១៤) ទំព័រ១២៩

[41] អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែម ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៥៩, មាត្រា ,មាត្រា ៤០ (២)(v) សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨, មាត្រា៥ អនុសញ្ញាប្រឆាំងទារុណកម្ម និងប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទោកបន្ទាប ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤, មាត្រា១ និង មាត្រា៤

[42] ម.ស.ម.ក "*ព្រឹត្តិបត្រព័ត៌មានស្តីពីសិទ្ធិទទួលបានការជម្រះក្តីដោយយុត្តិធម៌៖សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង*" លេខ១១ (ឆ្នាំ ២០២០),កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧, មាត្រា៧

បង្ខំឱ្យសារភាពជាមធ្យោបាយមួយ ដែលឆាប់រហ័សបំផុតក្នុងការស្វែងរកការពិត ប៉ុន្តែមនុស្សភាគច្រើននៅពេលដែលទទួលរងការឈឺចាប់ ការប្រើប្រាស់អំពើហិង្សាលើរូបរាងកាយ ឬការបំភ័យ សម្លុតថានឹងប្រើប្រាស់ទារុណកម្មលើជនជាប់ចោទ ដែលនាំឱ្យមានការសារភាពពីពិរុទ្ធ ជាអំពើដែលផ្ទុយនឹងបទដ្ឋានគតិយុត្តនៃច្បាប់ និងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ផងដែរ។

ពោលគឺ រាល់ការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នាយ៉ាងពេញលេញដោយមិនត្រូវបានបង្ខិតបង្ខំ ឬសារភាពថាមានពិរុទ្ធ ។[43] ជនជាប់ចោទអាច ត្រូវបានសួរចម្លើយបានតែនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ។[44] ប៉ុន្តែប្រសិនបើមេធាវី មិនចូលបង្ហាញខ្លួនទៅតាមថ្ងៃ និងតាមម៉ោងដែលបានកំណត់ទេ ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទ ដោយគ្មានវត្តមានរបស់មេធាវី ។[45] និទ្ទេសស្តីអំពីអវត្តមាននេះ ត្រូវចុះនៅក្នុង កំណត់ហេតុសួរចម្លើយជនត្រូវចោទ ក៏ដូចជាប្រភេទនៃភស្តុតាងដទៃទៀតដែរ ត្រូវដាក់ជូនតុលាការធ្វើការថ្លឹងថ្លែង។[46]

នៅក្នុងប្រទេសកម្ពុជា ចម្លើយសារភាពប្រឆាំងនឹងសក្ខីកម្ម របស់ជនជាប់ចោទមិនអាចយកជាមូលដ្ឋានសម្រាប់ការកាត់ទោសទេ លើកលែងតែមានភស្តុតាងបញ្ជាក់បន្ថែមដទៃទៀត។ ទោះបីជា ក្រមចាស់ផ្តល់តំលៃគតិយុត្តខ្លាំងក្នុងការយកចម្លើយសារភាពរបស់ជនជាប់ចោទជាភស្តុតាងគតិយុត្ត ក្នុងការរកឃើញនូវពិរុទ្ធភាពរបស់ជនជាប់ចោទ។ ប៉ុន្តែដោយសារការវិវត្តន៍នៃសង្គម និងការយល់ដឹងអំពីគុណវិបត្តិនៃការយកចម្លើយសារភាពធ្វើជាភស្តុតាងដ៏មានសុពលភាពក្នុងការកាត់សេចក្តីនោះបណ្តាលឱ្យមាន ការប្រើអំពើទារុណកម្មអំពីសំណាក់មន្ត្រីនគរបាល ឬក៏មានការគំរាមកំហែងបង្ខំឱ្យជននោះទទួលសារភាពទាំងខ្លួនមិនមែនជាអ្នកប្រព្រឹត្ត។ ហេតុដូចនេះ សិទ្ធិជាមូលដ្ឋាន គឺចាំបាច់ណាស់ ដែលទាមទារឱ្យមានការគោរព និងប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួន។

**ច. សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យាពេល**

សិទ្ធិទទួលបានការជំនុំជម្រះ ដោយគ្មានពន្យាពេលជាការធានារបស់ច្បាប់ចំពោះជនជាប់ចោទ ដែលត្រូវបានឃុំខ្លួនក្នុងអំឡុងពេលសវនាការ មិនត្រូវបានដកហូតសេរីភាពយូរហួសពីភាពចាំបាច់ឡើយ ក្នុងន័យការពារជនជាប់ចោទពីការបន្តឃុំខ្លួន ដោយគ្មានការជំនុំជម្រះ និងមិនមានភាពចាំបាច់។ សិទ្ធិនេះមានសារសំខាន់ណាស់ សម្រាប់ការពារជនជាប់ចោទ ពីការបន្តការឃុំខ្លួនដោយគ្មានការជំនុំជម្រះស្ថិតក្នុងស្ថានភាពមួយ

---

[43] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣, មាត្រា ៣៨ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៦, មាត្រា១៤៣ (៧)

[44] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា១៤៥

[45] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា១៤៥ (៤)

[46] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា៣២១

មិនច្បាស់លាស់ ទាក់ទងនឹងជោគវាសនារបស់ខ្លួន ក្នុងរយៈពេលមួយអូសបន្លាយ ក្នុងបទល្មើសមួយដែលខ្លួនមិនបានប្រព្រឹត្ត។ ការអូសបន្លាយពេលវេលាសវនាការ បណ្តាលឱ្យជនជាប់ចោទបាត់បង់ឱកាសទទួលបានយុត្តិធម៌នាំឱ្យបាត់បង់ ឬបំផ្លាញភស្តុតាង និងសាក្សី។ អ្វីដែលគួរឱ្យកត់សម្គាល់ ការពន្យាពេលកាន់តែយូរ ការផ្តល់សក្ខីភាពត្រូវបានអន់ថយតាមរយៈកាល។

តាមរយៈកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(៣)(គ) បានចែងយ៉ាងច្បាស់អំពីសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យាពេល។ លើសពីនេះ សិទ្ធិនេះក៏មានចែងនៅក្នុងច្បាប់ជាតិនៅ មាត្រា ៣១ និងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះ បុគ្គលគ្រប់រូបដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌណាមួយ មានសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានពន្យាពេល។

នៅក្នុងពេលមានការចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើស ជាគោលការណ៍ការដោះលែងជនជាប់ចោទនៅពេលរងចាំសវនាការ គួរតែត្រូវបានចាត់ទុកជាជម្រើសទីមួយ ហើយការឃុំខ្លួនបណ្តោះអាសន្នមិនត្រូវបានចាត់ទុកជាវិធានទូទៅនោះទេ[47] ដែលគោលការណ៍ជនជាប់ចោទត្រូវមានសេរីភាព។ ក្នុងករណីពិសេស ជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្តោះអាសន្នក្នុងលក្ខខណ្ឌដែលបានចែងដោយច្បាប់។[48] ការកំណត់ នូវមូលហេតុនៃការបង្គាប់ឱ្យមានការឃុំខ្លួនបណ្តោះអាសន្ន និងថេរវេលាកំណត់សម្រាប់បញ្ញត្តិការឃុំខ្លួន ដោយច្បាប់កម្ពុជាត្រូវបានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។[49]

### ឆ. សិទ្ធិទទួលបានការពន្យល់ប្រាប់ពីសិទ្ធិរបស់ជនជាប់ចោទ

គ្រប់បុគ្គលទាំងអស់ត្រូវទទួលបានការពន្យល់ពីសិទ្ធិមុនពេលសវនាការ និងអំឡុងពេលសវនាការដែលរួមមានដូចជា៖ សិទ្ធិស្នើសុំមេធាវីការពារក្តី សិទ្ធិទទួលដឹងពីការចោទប្រកាន់ សិទ្ធិរក្សាភាពស្ងៀមស្ងាត់ សិទ្ធិស្នើសុំអ្នកបច្ចេកទេស សិទ្ធិស្នើសុំពិនិត្យភស្តុតាង ឬកោះហៅសាក្សី ក្នុងករណីចាំបាច់ដែលបានសង្ស័យពីសមាសភាពសាក្សី និងមានការក្លែងបន្លំភស្តុតាង និងសិទ្ធិទទួលបានអ្នកបកប្រែ ក្នុងករណីជនជាប់ចោទជាជនបរទេស។ ទោះក្នុងកាលៈទេសៈណាក៏ដោយ ជនជាប់ចោទត្រូវតែទទួលបានការពន្យល់ពាក់ព័ន្ធនឹងសិទ្ធិរបស់ខ្លួន ដើម្បីទទួលបាននូវតម្លាភាព និងយុត្តិធម៌។ អំឡុងពេលសវនាការ នាងខ្ញុំសង្កេតឃើញថា សិទ្ធិទទួលបានការពន្យល់ប្រាប់ពីសិទ្ធិរបស់ជនជាប់ចោទ ត្រូវបានគោរពដោយតុលាការនៅប្រទេសកម្ពុជា។

---

[47] មជ្ឈមណ្ឌលសិទ្ធិមនុស្ស, *របាយការណ៍ប្រចាំឆមាសលើកទី៣៖ សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌នៅកម្ពុជាការវិវឌ្ឍក្នុងរយៈពេលមួយឆ្នាំ*, មករា ២០១២ និង កតិកាសញ្ញាអន្តជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៦, មាត្រា ៩(៣)

[48] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា២០៣

[49] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា២០៥, មាត្រា២០៨ និងមាត្រា២១៤

### ជ. សិទ្ធិដឹងពីថ្ងៃជំនុំជម្រះក្តី

នៅក្នុងនីតិវិធីគ្រប់ដំណាក់កាល ត្រូវធានាបាននូវការផ្តល់ដំណឹងដល់ជនជាប់ចោទ ឬជនត្រូវចោទពីថ្ងៃសវនាការជាដាច់ខាត។ មន្ត្រីតុលាការ ត្រូវជូនដំណឹងដល់ជនជាប់ចោទ តាមមធ្យោបាយណាមួយ តាមរយៈគ្រួសារ មេធាវីការពារក្តី អាសយដ្ឋានចុងក្រោយរបស់អ្នកស្គាល់ជនជាប់ចោទ ឬជូនដំណឹងតាមរយៈមន្ត្រីពន្ធនាគារ ចំពោះជនដែលជាប់ក្នុងឃុំ ឬពន្ធនាគារ ដើម្បីប្រាកដថាជនជាប់ចោទបានទទួលដំណឹងពីថ្ងៃសវនាការ។ ក្នុងករណីដែររកឃើញថា មិនបានជូនដំណឹងអំពីថ្ងៃសវនាការ ជនជាប់ចោទមានសិទ្ធិធ្វើបណ្តឹងទាមទារឱ្យតុលាការបើកដំណើរការសវនាការសារជាថ្មីម្តងទៀត ដើម្បីការពារផលប្រយោជន៍របស់ជនជាប់ចោទ និងដើម្បីការពារការកាត់ក្តីដោយអយុត្តិធម៌ ដែលរំលោភដល់សិទ្ធិការពារខ្លួនរបស់ជនជាប់ចោទ។

ការជម្រះក្តីដោយយុត្តិធម៌ត្រូវធានាបាននូវការផ្តល់ជូនដំណឹង ដើម្បីជៀសវាងការកាត់ក្តីដោយលំអៀង ឬដោយអវត្តមានរបស់ភាគីណាម្នាក់អាចធ្វើឱ្យមានការរំលោភបំពានសិទ្ធិបានវត្តមានរបស់ជនជាប់ចោទក្នុងដំណើរការនីតិវិធី។[50]

### ២.១.២. សិទ្ធិទទួលបានអំឡុងពេលសវនាការ

ពេលសវនាការសិទ្ធិសំខាន់ៗ ដែលជនជាប់ចោទត្រូវទទួលបាននោះមានដូចជា សិទ្ធិទទួលបានតុលាការឯករាជ្យ មិនលំអៀង សិទ្ធិទទួលបានសវនាការជាសាធារណៈ សិទ្ធិមានវត្តមានក្នុងពេលសវនាការ សិទ្ធិទទួលបានការពន្យល់បន្ថែមពីសិទ្ធិ និងសិទ្ធទទួលបានអ្នកបច្ចេកទេស ឬអ្នកបកប្រែ។

### ក.សិទ្ធិទទួលបានតុលាការឯករាជ្យ មិនលំអៀង

គ្រប់សាលាជម្រះក្តី ចៅក្រម ត្រូវតែមិនលំអៀង និងមានឯករាជ្យភាព។[51] តុលាការ ដែលរងឥទ្ធិពល និងស្ថិតក្រោមអំណាចពីប្រភពខាងក្រៅ គឺមិនអាចអនុវត្តមុខងាររបស់ខ្លួន ដើម្បីធានានូវសវនាការដោយយុត្តិធម៌បានទេ។ គ្រប់សាលាជម្រះក្តី ចៅក្រម ត្រូវតែមានឯករាជ្យពី អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិនៃរដ្ឋាភិបាល ភាគីដែលពាក់ព័ន្ធនឹងនីតិវិធី និងយន្តការផ្សេងៗទៀតរបស់រដ្ឋ។ ការធ្វើបែបនេះ គឺដើម្បីធានាថា គ្មានអ្នកណាអាចប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ ដើម្បីផលប្រយោជន៍បុគ្គល ឬប្រយោជន៍នយោបាយបានឡើយ។ ចៅក្រម មិនត្រូវទទួលផលប្រយោជន៍ ពីភាគីណាមួយ ដែលជាប់ពាក់ព័ន្ធនឹងសំណុំរឿងដែលខ្លួនកំពុងជំនុំជម្រះ ដោយមិនត្រូវមានបុរេនិច្ឆ័យ បង្ហាញពីភាពលំអៀងទៅរកភាគីណាមួយ។[52] បើសិនមានការទោទន់ទៅរកភាគីណាម្នាក់

---

[50] សូមមើលបន្ថែម ២.១.២ (គ) សិទ្ធិមានវត្តមាននៅពេលសវនាការ

[51] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣, មាត្រា១២៨ (ថ្មី)

[52] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨, មាត្រា១០

នោះភាគីដែលជាប់ពាក់ព័ន្ធនឹងសំណុំរឿងនោះអាចប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់គាត់។ ព្រមជាមួយគ្នានោះ ចៅក្រមធានាឱ្យមានសវនាការជាសាធារណៈ និងសមធម៌ ដែលជម្រះក្តីដោយតុលាការឯករាជ្យ និងមិនលំអៀង។

**ខ.សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ**

ការជំនុំជម្រះជាសាធារណៈ ធានាថារដ្ឋបាលប្រព័ន្ធយុត្តិធម៌មានតម្លាភាព និងអំណាចតុលាការមានទំនួលខុសត្រូវចំពោះសាធារណជននូវគ្រប់សេចក្តីសម្រេចរួមជាមួយសាលក្រមដែលខ្លួនបានសម្រេច។ សម្រាប់ភាគីដែលពាក់ព័ន្ធវិញ ការបើកឱ្យសាធារណជនពិនិត្យពិច័យនោះអនុញ្ញាតឱ្យមាន ការត្រួតពិនិត្យចំពោះការសម្រេចសេចក្តីតាមអំពើចិត្ត និងដោយរំលោភអំណាចនានាទៅលើនីតិវិធីរួមទាំង ការប្រព្រឹត្តមិនស្មើភាពគ្នាទៅលើភាគីពាក់ព័ន្ធ ការជ្រៀតជ្រែក និងឥទ្ធិពលពីភាគីខាងក្រៅ។ នៅពេលប្រព័ន្ធច្បាប់កំពុងដំណើរការ ស្របតាមគោលការណ៍ច្បាប់ និងសីលធម៌នោះ សវនាការជាសាធារណៈកើតឡើងដោយមានសមាសភាពមួយចំនួន ជាទូទៅសវនាការគួរតែបើកទូលាយ សម្រាប់សាធារណជន និងប្រព្រឹត្តទៅដោយផ្ទាល់មាត់។ ព័ត៌មាន ពីទីកន្លែង និងពេលវេលានៃសវនាការគួរតែត្រូវបានបង្ហាញជាសាធារណៈ និងគួរតែមានសម្ភាររូបវ័ន្ត គ្រប់គ្រាន់ជួយសម្រួលដល់ការចូលរួមរបស់សាធារណជន។ សាលក្រម ត្រូវតែប្រកាសនៅពេលសវនាការជាសាធារណៈ[53] លើកលែងតែផលប្រយោជន៍អនីតិជន ឬអាណាព្យាបាលរបស់កុមារ ការចេញសាលក្រមទាំងអស់អំពីរឿងព្រហ្មទណ្ឌ ឬ រដ្ឋប្បវេណី ត្រូវប្រកាសជាសាធារណៈ។[54] តុលាការអាចបង្គាប់ ឱ្យការពិភាក្សាដេញដោល ប្រព្រឹត្តទៅជាសម្ងាត់ ប្រសិនបើតុលាការពិចារណាទៅលើអង្គសេចក្តី យល់ឃើញថា សាធារណភាពបង្កឱ្យមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬដល់ទំនៀមទម្លាប់។[55] គួរកត់សម្គាល់ផងដែរថា ក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានផ្តល់និយមន័យ ឬសេចក្តីណែនាំអំពីអ្វីទៅជា "គ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់ សាធារណៈ ឬទំនៀមទម្លាប់" ឡើយ។

សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ទោះបីជា ត្រូវបានចាត់ទុកថាមិនទាន់បានគោរពចាប់ តាំងពីឆ្នាំ២០១៦ តែមានភាពល្អប្រសើរឡើងគួរឱ្យកត់សម្គាល់ក្នុងអំឡុងពេលធ្វើរបាយការណ៍ ដោយសារតែតុលាការបានបិទផ្សាយកម្មវិធីសវនាការនៅលើក្តារខៀនព័ត៌មានខាងក្រៅបន្ទប់សវនាការ មានចំនួន ៨០% នៃសំណុំរឿងទាំងអស់ដែលបានសង្កេត បើធៀបនឹងរបាយការណ៍ឆ្នាំមុនមានតែសំណុំរឿងចំនួន ១៥% ប៉ុណ្ណោះដែលមានបិទផ្សាយកម្មវិធីសវនាការ។ [56]

---

[53] ក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា៣១៧

[54] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦, មាត្រា១៤

[55] ក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា៣១៦

[56] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "*ការសង្កេតសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ*" ចេញផ្សាយថ្ងៃទី១២ មិថុនា ២០២៣, ទំព័រ៣

### គ. សិទ្ធិមានវត្តមាននៅពេលសវនាការ

ជនជាប់ចោទត្រូវចូលបង្ហាញខ្លួននៅពេលសវនាការដែលជាប់ពាក់ព័ន្ធនឹងខ្លួនដោយផ្ទាល់។[57] វត្តមាននៅពេលសវនាការផ្ទាល់របស់ជនជាប់ចោទមានសារៈសំខាន់ណាស់ ដោយសិទ្ធិនេះអនុញ្ញាតឱ្យជនជាប់ចោទដឹងអំពីសំណុំរឿងរបស់ខ្លួន និងតតាំងលើករណីដែលប្រឆាំងនឹងខ្លួន។ ម្យ៉ាងទៀត ជននោះបានស្តាប់ និងជំទាស់ទៅនឹងការចោទប្រកាន់ ព្រមទាំងការពារតទល់នឹងបទចោទប្រកាន់ប្រឆាំងនឹងខ្លួន។ ដើម្បីធានាថាសិទ្ធិនេះ ត្រូវបានគោរព អាជ្ញាធរមានសមត្ថកិច្ច ត្រូវប្រាកដថាជនជាប់ចោទមានវត្តមាននៅក្នុងពេលសវនាការ រួមជាមួយមេធាវីរបស់ខ្លួន ត្រូវផ្តល់ការជូនដំណឹងអំពីពេលវេលា កាលបរិច្ឆេទ និងទីកន្លែងសវនាការដល់ជនជាប់ចោទ។ លើកលែងតែការប៉ុនប៉ងទាំងឡាយណា ដើម្បីរាំងជនជាប់ចោទមិនឱ្យមានវត្តមាននៅសវនាការ ឬស្របទៅនឹងលក្ខខណ្ឌតម្រូវនៃសវនាការកំបាំងមុខ។ [58]

[59] ក្នុងនោះតុលាការត្រូវផ្តល់ពេលវេលាមួយសមស្របដល់ជនជាប់ចោទ ដើម្បីមានវត្តមាននៅតុលាការអាស្រ័យតាមទីកន្លែងដែលជននោះរស់នៅ។ ជនជាប់ចោទមានរយៈពេល ១៥ថ្ងៃ ដើម្បីបង្ហាញខ្លួនប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់តុលាការជាន់ទាបរយៈពេល ២០ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែង មួយផ្សេងទៀតក្នុងដែនដីជាតិរយៈពេល ០២ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយ ជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា និងរយៈពេល ៣ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងដទៃផ្សេងទៀត។ គ្មានចន្លោះពេលអប្បបរមារវាងការបញ្ជូនដីកាកោះ និងកាលបរិច្ឆេទបង្ហាញខ្លួននៅមុខតុលាការឡើយ ប្រសិនបើជននោះកំពុងជាប់ឃុំឃាំង។

### ឃ. សិទ្ធិទទួលបានការបកប្រែ និងអ្នកបច្ចេកទេសនៅពេលបើកសវនាការ

ជនជាប់ចោទអាចមានសិទ្ធិ ស្នើសុំអ្នកបកប្រែ ឬអ្នកបច្ចេកទេស ក្នុងពេលសវនាការ ដោយឥតគិតថ្លៃឈ្នួល ក្នុងករណី ជនជាប់ចោទមិនយល់ ឬមិនចេះភាសាផ្លូវការ ដែលប្រើប្រាស់នៅក្នុងសវនាការ។ មានន័យថាភាគីមានសិទ្ធិ ទទួលបានជំនួយអ្នកបកប្រែផ្ទាល់មាត់ ដែលមានសមត្ថភាព ហើយការបកប្រែត្រូវបំពេញតាមលក្ខខណ្ឌតម្រូវការនៃភាពយុត្តិធម៌។ សិទ្ធិមានអ្នកបកប្រែនេះ ភាគច្រើនសំដៅលើជនបរទេស ឬ ជាជនដែលមិនចេះអក្សរ។ ហេតុនេះហើយ ទើបតម្រូវឱ្យមានអ្នកបកប្រែភាសាសម្រាប់ជួយដោយឥតគិតថ្លៃ ប្រសិនបើសាមីជននោះមិនចេះស្តាប់ភាសាដែលប្រើក្នុងការកាត់ក្តីនោះ។ ដូចនេះ នៅក្នុងសវនាការត្រូវតែរកអ្នកបកប្រែជូនភាគីនៅ

---

[57] ក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា៣០០

[58] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦, មាត្រា១៤ (៣) (ឃ) ក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា៣៦០

[59] ក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា៤៥៧ និងមាត្រា ៤៦៦

ក្នុងរឿងក្តីដែលមិនចេះភាសា ឬជាជន គ ថ្លង់។ ចំពោះជនជាប់ចោទ ឬសាក្សីជាមនុស្ស គ ថ្លង់ ប៉ុន្តែចេះសរសេរអក្សរនោះ ក្រឡាបញ្ជីត្រូវសរសេរសំណួរ និងការកត់សម្គាល់ផ្សេងៗទៅឱ្យជនជាប់ចោទ ឬសាក្សី គ ថ្លង់ នោះដើម្បីធ្វើការឆ្លើយមកវិញដោយលាយលក្ខណ៍អក្សរ។ បើជន គ ថ្លង់ នោះមិនចេះសរសេរអក្សរ ចៅក្រមត្រូវតែងតាំងដោយឯកឯងនូវជនណាម្នាក់ ដែលចេះភាសាកាយវិកាសម្រាប់ធ្វើការឆ្លើយឆ្លងជាមួយមនុស្ស គ ថ្លង់ដោយកាយវិការ។ [60] ដូច្នេះ យើងឃើញថានៅប្រទេសកម្ពុជា មានការយកចិត្តទុកដាក់យ៉ាងហ្មត់ចត់ផងដែរនូវសិទ្ធិមានអ្នកបកប្រែភាសាសម្រាប់ផ្តល់ជូនភាគី ឬក៏សម្រាប់ជនជាប់ចោទដូចជាតាមរយៈលិខិតូបករណ៍ សិទ្ធិមនុស្សអន្តរជាតិដែលបានរៀបរាប់ខាងលើប្រកាសយ៉ាងទូលំទូលាយក្នុងការស្គាល់នូវ លិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិ ទាំងអស់នេះ។

**ង. សិទ្ធិបង្ហាញភស្តុតាង សិទ្ធិហៅ និងសាកសួរសាក្សី**

រាល់សេចក្តីសម្រេចរបស់តុលាការត្រូវតែផ្អែកលើភស្តុតាង ដែលបានបង្ហាញនៅអំឡុងពេលជំនុំជម្រះ។ ហេតុដូច្នេះ ភាគីត្រូវបានផ្តល់ឱ្យនូវឱកាសដើម្បីបង្ហាញភស្តុតាង និងហៅសាក្សីក្នុងការគាំទ្រដល់សំណុំរឿងរបស់ខ្លួន និងដេញដោលសួរសាក្សី ដែលបានហៅមកដោយភាគីម្ខាងទៀតដើម្បីតទល់នឹងភស្តុតាងដែលដាក់ដោយភាគីនោះ។ [61] ក្នុងនោះជនជាប់ចោទអាចទាមទារឱ្យមានការចូលរួមរបស់សាក្សី និងអ្នកជំនាញដើម្បីធ្វើសក្ខីកម្មគាំទ្រខ្លួន។ ភាគីអាចរួមមានសិទ្ធិសួរ ឆ្លើយ ឬសុំឱ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឱ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរចម្លើយក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីរបស់ព្រះរាជអាជ្ញា។ [62]

សិទ្ធិបង្ហាញភស្តុតាងរួមមាន សិទ្ធិកោះហៅ និងសាកសួរសាក្សី ផ្តល់ឱ្យភាគីជនជាប់ចោទនូវអំណាចស្របច្បាប់ក្នុងការបង្ហាញភស្តុតាងពាក់ព័ន្ធ ក៏ដូចជាការហៅ និងសាកសួរសាក្សីដូចព្រះរាជអាជ្ញាដែរ នៅអំឡុងពេលជំនុំជម្រះ ដើម្បីបន្ថែមភស្តុតាងដោះបន្ទុក ពីការដាក់បន្ទុករបស់ព្រះរាជអាជ្ញាក្នុងដំណើររឿងក្តីព្រហ្មទណ្ឌ។

### ២.១.៣. សិទ្ធិទទួលបានក្រោយពេលជំនុំជម្រះ

**ក. សិទ្ធិរួចផុតពីការដាក់ខ្លួនក្នុងការចោទប្រកាន់**

ជនជាប់ចោទ គួរត្រូវបានរួចផុតពីការចោទប្រកាន់ តាមគោលការណ៍សន្មតទុកជាមុនថាគ្មានទោស។ ការចោទប្រកាន់ ត្រូវបានរលត់ដោយសារមូលហេតុនៃមោឃៈភាពនៃបណ្តឹង ការរលត់នៃបណ្តឹងអាជ្ញា ការតម្កល់រឿងទុកឥតចាត់ការ អាជ្ញាអស់ជំនុំ ឬមានវិមតិសង្ស័យ។ មានន័យថា ជនជាប់ចោទក្រោយពីរកឃើញថាពុំមាន

---

[60] ក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា៣៣១

[61] កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦, មាត្រា១៤(៣)(ង), រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា៣៨, ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៦

[62] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦, មាត្រា១៤ (៣) (ង)

ជាប់ពិរុទ្ធ ឬពុំជាប់សង្ស័យក្នុងបទល្មើស ដូចការចោទប្រកាន់របស់ព្រះរាជអាជ្ញា មានសិទ្ធិរួចផុតពីការចោទប្រកាន់ និងមានសិទ្ធិសេរីភាពឡើងវិញ។

## ខ. សិទ្ធិទទួលបានការលើកលែងការចោទប្រកាន់ និងការសុំបន្ធូរបន្ថយទោស

ជនជាប់ចោទអាចស្នើសុំឱ្យតុលាការលើកលែងទោសមកលើខ្លួន ក្នុងករណីដែលជនជាប់ចោទបានបង្ហាញភស្តុតាងនឹងមិនត្រូវរកឃើញថាមានបទល្មើស ដែលចោទប្រកាន់ដោយព្រះរាជអាជ្ញា។ ក្នុងលក្ខខណ្ឌនេះ តុលាការត្រូវលើកលែងការចោទប្រកាន់ ដោយដោះលែងឱ្យមានសេរីភាពឡើងវិញក្រោយ ពេលប្រកាសសាលក្រម ឬសាលដីកា។

ក្រោយពេលជំនុំជម្រះក្តីជនជាប់ចោទក្រោយពីរកឃើញថាខ្លួនពិតជាបានប្រព្រឹត្តបទល្មើស អាចស្នើសុំតុលាការ បន្ធូបន្ថយទោសរបស់ខ្លួន សម្រាប់ទុកឱកាសឱ្យជននោះធ្វើការស្តារនីតិសម្បទាដើម្បីងាកមករស់នៅក្នុងសង្គម ប្រកបការងារ និងក្លាយជាបុគ្គលល្អនៅក្នុងសង្គមឡើងវិញ។ សិទ្ធិស្នើសុំបន្ធូបន្ថយទោស ផ្សាភ្ជាប់ជាមួយនឹងសិទ្ធិសំណូមពរចុងក្រោយមុនប្រកាសសាលក្រម។ ជនជាប់ចោទអាចស្នើសុំបន្ធូបន្ថយទោសបានបើជននោះបានភ្ញាក់ខ្លួនដឹងកំហុសជាមួយនឹងការកែប្រែគំនិតមាយាទឱ្យក្លាយជាពលរដ្ឋសុចរិត និងធ្វើសមាហរណកម្មចូលរួមរស់ក្នុងសង្គមវិញ។ [63]

ឧទាហរណ៍៖ លោក ក ត្រូវបានប្រកាសពីពិរុទ្ធភាព តាមអំណាចសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ ពីបទរក្សាទុក និងប្រើប្រាស់នូវសារធាតុញៀន ដោយផ្តន្ទាទោសរយៈពេល ៥ ឆ្នាំ។ ប៉ុន្តែលោក ក បានស្នើសុំតុលាការបន្ធូបន្ថយទោស ដោយសារតែលោកបានចូលរួមសហការណ៍ឱ្យមានការចាប់ជនដទៃទៀត និងដឹងពីកំហុស។ [64]

## គ. សិទ្ធិទទួលបានសេរីភាព និងការដោះលែង

សិទ្ធិទទួលបានសេរីភាព និងការដោះលែងក្រោយពេលដែលតុលាការបានរកឃើញថា ជនជាប់ចោទពុំមានពិរុទ្ធ ពោលក្នុងករណីមាន ការលុបចោលការបញ្ជាឃុំខ្លួននោះ ទណ្ឌិតអាចត្រូវដោះលែងឱ្យនៅក្រៅឃុំ និងមានសេរីភាព។ [65] ជនជាប់ចោទ អាចដាក់ពាក្យសុំដោះលែងឱ្យនៅក្រៅឃុំបានគ្រប់ពេលវេលា អាចធ្វើឡើងដោយជនជាប់ចោទផ្ទាល់នៅពេលសវនាការ ឬតាមលិខិតជូនដំណឹងដែលធ្វើជូនទៅក្រឡាបញ្ជី ឬតាមរយៈ

---

[63] ព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងលើកលែងទោស, មាត្រា៥ វាក្យ.១

[64] ច្បាប់ស្តីពីវិសោធកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៥, មាត្រា៣២

[65] ក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា៥២៨

មេធាវីការពារជនជាប់ចោទ។ [66] ក្រោយទទួលបានពាក្យបណ្ដឹងជាលាយលក្ខណ៍អក្សរ និងសុំផ្ទាល់មាត់ តុលាការ ត្រូវសម្រេចសេចក្ដីនៅក្នុងរយៈពេលមួយយ៉ាងខ្លីបំផុត និងយ៉ាងយូរបំផុតក្នុងរយៈពេល ១០ថ្ងៃ។

មេធាវីការពារក្ដី ត្រូវមានមូលហេតុដែលគាំទ្រការស្នើសុំឱ្យដោះលែងដោយ ផ្អែកតាមលក្ខណៈសុចរិតភាពរបស់ជនជាប់ចោទ ឬដោយសារបញ្ហាសុខភាព មិនស៊ីគ្នានឹងការឃុំខ្លួន។

### ឃ. សិទ្ធិធ្វើពាក្យបណ្ដឹងទាស់ និងសេចក្ដីសម្រេចរបស់តុលាការ

#### ឃ.១.សិទ្ធិធ្វើបណ្ដឹងទាស់

បុគ្គលដែលអាចមានសិទ្ធិធ្វើបណ្ដឹងទាស់ ករណីពិរុទ្ធជនជានីតិជន អាចប្ដឹងបានដោយខ្លួនឯង ឬពឹងអ្នកតំណាងឱ្យប្ដឹងជំនួស អ្នកតំណាងស្របច្បាប់ដែលជាមេធាវីការពារក្ដី ពោលគឺច្បាប់នៅក្នុងប្រទេសកម្ពុជា បានកំណត់វ័យនីតិភាពគិតចាប់ ពីអាយុ ១៨ ឆ្នាំឡើង ព្រោះថាអាយុនេះអាចមានការគិតពិចារណាបានត្រឹមត្រូវទៅលើសកម្មភាពរបស់ខ្លួន។ ចំពោះពិរុទ្ធជនជាអនីតិជន មានអាយុ ១៤ ឆ្នាំ ដល់ ១៨ ឆ្នាំ ពួកគាត់មិនអាចប្ដឹងដោយខ្លួនឯងបានទេ ព្រោះគាត់ពុំទាន់មានសមត្ថភាពតាមផ្លូវច្បាប់នៅឡើយ។ អនីតិជនត្រូវមានជំនួយពីអ្នកតំណាងស្របច្បាប់ អាចជាឪពុកម្ដាយ អាណាព្យាបាល ឬមេធាវីដែលមានការផ្ទេរសិទ្ធិពីឪពុកម្ដាយ ឬអាណាព្យាបាល។

សិទ្ធិធ្វើបណ្ដឹងទាស់ ជាគោលការណ៍តាមផ្លូវច្បាប់នៅពេលដែលតុលាការបើកសវនាការជំនុំជម្រះលើពិរុទ្ធជន ឬជនជាប់ចោទណាម្នាក់ដោយកំបាំងមុខ គឺបុគ្គលអាចប្ដឹងបន្តទៅតុលាការ ដើម្បីធ្វើការជំនុំជម្រះឡើងវិញបាន។ បណ្ដឹងទាស់ ឬបណ្ដឹងជំទាស់ គឺជាពាក្យសុំបដិសេធសេចក្ដីសម្រេច ឬសាលក្រមដែលត្រូវបើកឱ្យ គូភាគីក្នុងរឿងក្ដី ដែលបានអវត្តមាននៅពេលជំនុំជម្រះ អាចស្នើសុំឱ្យមានការជំនុំជម្រះឡើងវិញចំពោះមុខខ្លួន។ ពាក្យបណ្ដឹងទាស់ ប្ដឹងអំពីសេចក្ដីសម្រេចកំបាំងមុខរបស់សាលាជម្រះក្ដី។ កាលណាបណ្ដឹងជំទាស់ត្រូវបានធ្វើឡើងនោះ សាលក្រម ឬសាលដីកាដែលបានសម្រេចត្រូវចាត់ទុកជាអត់បានការ ហើយតុលាការដដែលនោះនឹងបើកសវនាការជំនុំជម្រះសារជាថ្មីឡើងវិញ។

បណ្ដឹងទាស់អាចធ្វើឡើងបានបន្ទាប់ពីទទួលបានសាលក្រម សាលដីកា ក្នុងរយៈពេល ១៥ថ្ងៃ ក្រោយពីភាគីទទួលបានដំណឹងពីសេចក្ដីសម្រេច។ [67] បណ្ដឹងទាស់ អាចធ្វើឡើងជាលាយលក្ខណ៍អក្សរដាក់នៅការិយាល័យក្រឡាបញ្ជីនៃតុលាការ ដែលបានប្រកាសសាលក្រម ឬសាលដីកានៅ ចំពោះមុខព្រះរាជអាជ្ញា

---

[66] ក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា ៣០៧

[67] ក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា៣៦៥, ៣៦៨, ៤០៩, ៤១២

អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬនៅចំពោះមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។[68] ជនជាប់ចោទមានសិទ្ធិប្តឹងជំទាស់ទៅនឹងសាលក្រមកំបាំងមុខ ព្រោះថាសវនាការមួយ ដែលបានប្រព្រឹត្តទៅដោយអវត្តមានជនជាប់ចោទ ផ្ទុយមកវិញវាគឺជាការរំលោភបំពានលើសិទ្ធិជនជាប់ចោទ ព្រោះមិនបានទទួលនូវការជូនដំណឹងពីបទចោទ។

ជនជាប់ចោទ អាចប្តឹងទាស់ និងសាលក្រមកំបាំងមុខនេះបានក្នុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រម ត្រូវប្រគល់ឱ្យពិរុទ្ធជនដោយផ្ទាល់ដៃ។ បណ្តឹងទាស់ស្របច្បាប់រយៈពេល ១៥ថ្ងៃ នេះគឺជាការផ្អាកការអនុវត្តសាលក្រម។ ក្រោយតុលាការទទួលពាក្យប្តឹងទាស់ សំណុំរឿងរបស់ជនជាប់ចោទនឹងត្រូវយកទៅជំនុំជម្រះឡើងវិញ នៅចំពោះមុខតុលាការ។ មាត្រា ៣៧១ ចែងថាសំណុំរឿងត្រូវបានលើកយកមកជំនុំជម្រះនៅមុខតុលាការដដែរ។ ប្រសិនបើ មិនអាចជូនដំណឹងដោយផ្ទាល់មាត់អំពីសេចក្តីប្រកាសនៃសាលក្រម នេះអាចយកទៅបិទនៅនឹងលំនៅដ្ឋានដែលគេស្គាល់ចុងក្រោយបង្អស់របស់ជនល្មើស ឬបិទផ្លូវឃុំសង្កាត់ ឬផ្សាយតាមវិទ្យុជាតិ ឬបោះពុម្ពផ្សាយតាមសារព័ត៌មានផ្លូវការ ប្រសិនបើជនជាប់ចោទដឹងអំពីសាលក្រម គាត់អាចប្តឹងទាស់នៅពេលណាក៏បានឱ្យតែស្ថិតក្នុងកំឡុងពេលអាជ្ញាយុកាលនៃទោស។

**ឃ.២. សិទ្ធិប្តឹងឧទ្ធរណ៍**

ភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ លើពាក្យតវ៉ាសុំឱ្យកែប្រែសេចក្តីសម្រេច ឬសាលក្រម របស់តុលាការជាន់ទាបខេត្ត-ក្រុង ឬតុលាការយោធា។ សេចក្តីសម្រេចទាំងឡាយ របស់អយ្យការអមសាលាដំបូងរាជធានី ខេត្ត-ក្រុង ត្រូវបើកសវនាការនៅតុលាការជាន់ខ្ពស់ដែលហៅថា "សាលាឧទ្ធរណ៍"។ សាលាឧទ្ធរណ៍ និងពិនិត្យឡើងវិញទៅលើអង្គហេតុ និងអង្គច្បាប់ បើសិនជាភាគីណាមួយ មិនពេញចិត្តនឹងសាលក្រម ឬសេចក្តីសម្រេចរបស់តុលាការជាន់ទាបនោះ ភាគីនោះអាចស្នើសុំ ប្តឹងទៅសាលាឧទ្ធរណ៍បាន។ ចំពោះបណ្តឹងឧទ្ធរណ៍ ត្រូវធ្វើឡើងក្នុងរយៈពេល ០២ខែ ចាប់ពីថ្ងៃ ដែលប្រកាសសាលក្រមរបស់សាលាដំបូងរាជធានី-ខេត្ត និងប្តឹងឡើងដោយ ព្រះរាជអាជ្ញានៃសាលាដំបូងហើយបណ្តឹងនឹងធ្វើឡើងដោយអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍លើ សេចក្តីសម្រេចដែលមានរយៈពេល ០៣ ខែ។[69] ក្រុមប្រឹក្សាជំនុំជម្រះ នឹងធ្វើការស៊ើបអង្កេតបន្ថែម ដើម្បីជួយរកដំណោះស្រាយ អំពីការខ្វះចន្លោះលើអង្គហេតុដែលរកឃើញ ដោយតុលាការជាន់ទាប។ ប៉ុន្តែសាលាឧទ្ធរណ៍មិនអាចបើកសវនាការលើបញ្ហា និងបទចោទដែលមិនបានប្តឹងឧទ្ធរណ៍បានទេ។

[68] ក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា៣៦៦, ៤១០

[69] ក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា៣៨១

**ឃ.៣. បណ្តឹងសាទុក្ខ**

បណ្តឹងសាទុក្ខ គឺជាបណ្តឹងតវ៉ា ឬបដិសេធសេចក្តីសម្រេចសាលដីការបស់សាលាឧទ្ធរណ៍ ពោលគឺនៅពេលដែលភាគីកើតទុក្ខមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ [70] ភាគីមានសិទ្ធិប្តឹងទៅតុលាការកំពូលដែលមានទីតាំងស្ថិតនៅទីក្រុងភ្នំពេញ ដែលហៅថា តុលាការជាន់ខ្ពស់។ តុលាការកំពូល មានសមត្ថកិច្ចដោះស្រាយចុងក្រោយ បំផុតចំពោះការអនុវត្តសាលដីការបស់សាលាឧទ្ធរណ៍រហូតដល់មានប្រកាសសាលដីការបស់តុលាការកំពូលក្រោយពីទទួលបានពាក្យបណ្តឹងសាទុក្ខ ដែលមិនសុខចិត្ត និងសាលដីការបស់សាលាឧទ្ធរណ៍។ ភាគីអាចធ្វើបណ្តឹងសាទុក្ខបានក្នុងរយៈពេល ០១ ខែ។ [71] ពិរុទ្ធជន អាចធ្វើបណ្តឹងសាទុក្ខ បើសិនក្នុងករណីដែលភាគីប្តឹងសាទុក្ខ បានបង្ហាញបញ្ហាណាមួយនៅក្នុងបណ្តឹងសាទុក្ខនោះ តុលាការកំពូលត្រូវជំនុំជម្រះទៅលើបញ្ហាដែលបានប្តឹងតែប៉ុណ្ណោះ។ តុលាការកំពូល ត្រូវសម្រេចចេញសាលដីការបស់ខ្លួនទាំងបញ្ហាអង្គហេតុ និងអង្គច្បាប់។

**ង. សិទ្ធិទទួលបានសំណងមានប្រសិទ្ធិភាព**

រដ្ឋភាគី ត្រូវផ្តល់សំណងមានប្រសិទ្ធភាពចំពោះការបំពាននឹងបញ្ញត្តិ។ [72] សំណងជំងឺចិត្តចំពោះការរំលោភបំពានសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលបណ្តាលមកពីភាពចន្លោះប្រហោង ឬកង្វះខាតផ្នែកយុត្តិធម៌ ត្រូវបានធានា។ ការគាំទ្រចំពោះការផ្តល់សំណងជាក់លាក់ដល់បុគ្គលដែលទទួលរងពីការផ្តន្ទាទោសខុស។ [73] បន្ថែមពីលើដំណោះស្រាយជាក់លាក់ ដែលតម្រូវឱ្យមាននៅក្នុងវិចារណកថាទូទៅលេខ៣១ របស់គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ចែងពីទម្រង់ជាក់លាក់នៃសំណងជំងឺចិត្តសមស្របស្តីពី "ការសងមកវិញ ការស្តារយុរនីតិសម្បទា និងវិធានការបំពេញចិត្ត ដូចជាការសុំទោសជាសាធារណៈ ការរំលឹកជាសាធារណៈ ការធានាពីការមិនប្រព្រឹត្តម្តងទៀត និងការផ្លាស់ប្តូរច្បាប់ ឬការអនុវត្តដែលពាក់ព័ន្ធ ដូចជាផ្តល់យុត្តិធម៌ដល់ចារី នៃបទរំលោភសិទ្ធិមនុស្ស" [74]។

សំណងពីការរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺជាការបារម្ភបំផុតនៅកម្ពុជា។ គ្មានបទបញ្ញត្តិច្បាប់ច្បាស់លាស់ណាមួយដែលដាក់ទោសដល់ការមិនបានធានាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ មាត្រា៣៩ នៃរដ្ឋធម្មនុញ្ញកម្ពុជាបានចែងយ៉ាង ទូលាយថា ជនរងគ្រោះមានសិទ្ធិប្តឹងទារសំណងជួស

[70] ក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា៤១៧

[71] ក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា៤២០

[72] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦, មាត្រា ២(៣)

[73] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦, មាត្រា ៤(៦)

[74] អត្ថាធិប្បាយទូទៅរបស់មជ្ឈមណ្ឌលសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយលេខ៣១ ដូចកំណត់សម្គាល់ខាងលើ

ផុលការខូចខាត ដែលបណ្ដាលមកពីអំពើបំពានច្បាប់របស់អង្គការ រដ្ឋ និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ក្រមនីតិវិធីព្រហ្មទណ្ឌមានបទបញ្ញត្តិមួយចំនួនចែងពីសំណង ក៏ប៉ុន្តែសម្រាប់តែការខូចខាតផ្នែករដ្ឋប្បវេណី ឬជនរងគ្រោះពីបទល្មើសព្រហ្មទណ្ឌប៉ុណ្ណោះ។ នេះហាក់បីដូចជា ក្រមនីតិវិធីព្រហ្មទណ្ឌផ្ដល់ទម្រង់សំណងតែមួយប៉ុណ្ណោះ ជាការរួចខ្លួនជនជាប់ចោទ ប្រសិនបើសាលាឧទ្ធរណ៍រកឃើញថា ជនជាប់ចោទគ្មានទោស[75]។ ហេតុនេះ ការទទួលបានសំណងមានប្រសិទ្ធភាពសម្រាប់ការបំពានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺស្ទើរតែមិនអាចធ្វើទៅរួចក្នុងលក្ខខណ្ឌដែលមានបញ្ញត្តិ និងយន្តការដែលមិនច្បាស់លាស់ក្នុងការធានាការទទួលស្គាល់ពេញលេញនៃសិទ្ធិជាមូលដ្ឋានទាំងនោះ។

សំណុំរឿង លោក JOAQUIN CIRIA ត្រូវបានផ្ដន្ទាទោសពន្ធនាគារ San Francisco អស់រយៈពេល ៣២ ឆ្នាំ ក្រោយរកឃើញថាមិនមានជាប់ពិរុទ្ធអ្វីទាំងអស់ ក្នុងបទល្មើសឃាតកម្ម។ ដោយគិតពីឆ្នាំ១៩៩០ ដល់ឆ្នាំ២០២២ រដ្ឋបានសងសំណងជាទឹកប្រាក់ចំនួន **១,៦ លាន ដុល្លារសហរដ្ឋអាមេរិក** ជូនលោកដើម្បីជាសំណងការដាក់ពន្ធនាគារដោយគ្មានកំហុស តាមច្បាប់កាលីហ្វញ៉ា ។[76]

តាមរយៈសំណុំរឿងខាងលើ បង្ហាញពីការទទួលខុសត្រូវ និងសងសំណងប្រសិទ្ធភាពដែលជនជាប់ចោទគួរទទួលបាន ក្រោយរកឃើញថា បុគ្គលនោះមិនមានជាពិរុទ្ធភាព។ ដូចនេះ សំណងប្រសិទ្ធភាពនៅប្រទេសកម្ពុជាគួរតែ មើលបន្ថែមពីលើសំណងខាងលើ យ៉ាងណាមិញទោះបីជាច្បាប់ពុំមានកំណត់ច្បាស់លាស់ពាក់ព័ន្ធនឹងសំណងជនជាប់ចោទ។

## ២.២. សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទដែលជាអនីតិជន

### ក. និយមន័យ

អនីតិជន សំដៅទៅលើជនដែលមានអាយុក្រោម ១៨ ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស។[77] អនីតិជនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើស ត្រូវទទួលបានសិទ្ធិជំនុំជម្រះក្ដីដោយយុត្តិធម៌ទាំងអស់ដែលអនុវត្តចំពោះនីតិជន ក៏ដូចជាការការពារបន្ថែមទៀត ស្របទៅតាមអាយុ ការដឹងខុសត្រូវ និងការលូតលាស់ផ្នែកបញ្ញាស្មារតី។ គោលបំណងចម្បងនៃយុត្តិធម៌អនីតិជន គឺដើម្បីស្ដារនីតិសម្បទាន និងធ្វើសមាហរណកម្មជនល្មើសដែលជាអនីតិជនឱ្យក្លាយជាមនុស្សល្អក្នុងការស្ថាប័នក្នុងសង្គមឡើងវិញ។

---

[75] ក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា ៥០៥

[76] CNN “He spent three decades in prison for a murder he didn't commit. Now at 61, this San Francisco man will be free” https://edition.cnn.com/2022/04/19/us/joaquin-ciria-soma-murder-exonerated/index.html, By Alisha Ebrahimji

[77] ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦, មាត្រា ៤ និងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ *"នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ"*, មាត្រា ៣៨

សិទ្ធិជាមូលដ្ឋានរបស់អនីតិជនក្នុងនីតិវិធី ដែលអនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានដូចតទៅ៖ [78] សិទ្ធិទទួលបានឯកជនភាពរបស់កុមារ នៅក្នុងគ្រប់ដំណាក់កាលនៃនីតិវិធី សិទ្ធិទទួលបានជំនួយមេធាវីគ្រប់ករណីរឿងក្តីព្រហ្មទណ្ឌ សិទ្ធិទទួលបានសវនាការជាអសាធារណៈ សិទ្ធិទទួលបានការប្រាស្រ័យទាក់ទងជាមួយសាច់ញាតិ សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ សិទ្ធិស្នើសុំឱ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ សិទ្ធិទំនាក់ទំនងជាមួយស្ថានទូតឬស្ថានកុងស៊ុល (ក្នុងករណីអនីតិជនជាជនបរទេស) និងសិទ្ធិផ្សេងៗទៀត ដែលមានចែងក្នុងបទដ្ឋានគតិយុត្តជាធរមាន [79] សិទ្ធិខាងលើនឹងត្រូវយកមកលម្អិតនៅចំណុច **(ខ)** និង **(គ)**។ ការការពារសិទ្ធិជាមូលដ្ឋានរបស់អនីតិជនត្រូវគោរពដោយរដ្ឋ[80]៖ រដ្ឋភាគី ទទួលស្គាល់ថា កុមារដែលជាជនជាប់សង្ស័យ ជាប់ចោទ ឬដែលគេស្គាល់ថាបានល្មើសនឹងច្បាប់ព្រហ្មទណ្ឌមានសិទ្ធិ ទទួលបានការគិតគូរយ៉ាងសមស្របទៅនឹងការលើកស្ទួយ ការយល់ដឹង អំពីសេចក្តីថ្លៃថ្នូររបស់កុមារ និងតម្លៃរបស់ខ្លួន។ ការគិតបែបនេះ ជាការពង្រឹងកុមារឱ្យចេះគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន។[81]

### ខ. លក្ខខណ្ឌពិសេស និងសិទ្ធិរបស់អនីតិជននៅគ្រប់ដំណាក់កាលជម្រះក្តី

លក្ខខណ្ឌពិសេសជាលក្ខខណ្ឌគួរលើកមកពិចារណា ពីសិទ្ធិរបស់អនីតិជននៅគ្រប់ដំណាក់កាលជម្រះក្តី ដែលបានចែងយ៉ាងលម្អិត នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់សារធាតុ ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ ក្នុងនោះដែរ យើងនឹងធ្វើការផ្តោតសំខាន់បន្ថែមទៀតទៅលើការកំណត់នីតិភាពក្នុងសំណុំរឿងព្រហ្មទណ្ឌ និងការកំណត់ពេលវេលានៃការឃុំខ្លួន។ ក្នុងករណីមានការឃាត់ខ្លួនអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងតាមគ្រប់មធ្យោបាយដល់ឪពុកម្តាយ ដល់អ្នកតំណាងស្របច្បាប់ ឬដល់អ្នកទទួលភារកិច្ចលើអនីតិជននោះ។[82]

#### ខ.១. ការកំណត់នីតិភាពក្នុងសំណុំរឿងព្រហ្មទណ្ឌ

##### ខ.១.១. អាយុក្រោម ១៤ឆ្នាំ

---

[78] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦, មាត្រា ៦

[79] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦, មាត្រា ៥១

[80] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ កញ្ញា ឆ្នាំ១៩៩៣, មាត្រា ៣១ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦, មាត្រា ១៤(៤)

[81] អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែម ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៥៩, មាត្រា៤០(១)

[82] ក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា១០០

អនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ដែលបានសង្ស័យថាប្រព្រឹត្តបទល្មើស គឺពុំត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ដូច្នេះសមត្ថកិច្ចពុំមានអំណាចចាប់ខ្លួនបានឡើយ។

ក្នុងករណីអនីតិជនមានអាយុក្រោម ១៤ឆ្នាំ គិតមកត្រឹមថ្ងៃដែលសង្ស័យថាបាន ចូលរួមប្រព្រឹត្តបទល្មើស នោះព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងត្រូវប្រគល់អនីតិជនទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់វិញភ្លាម[83]។ បន្ថែមពីនោះ អនីតិជន មិនត្រូវបានឃុំខ្លួន ឬចាប់ខ្លួនបញ្ជូនទៅតុលាការនោះទេ តែត្រូវប្រើវិធានបញ្ជូនទៅអាណាព្យាបាល និងព្រមានដោយផ្ទាល់ ឬជាលាយលក្ខណ៍អក្សរ ប៉ុន្តែត្រូវជូនដំណឹងទៅព្រះរាជអាជ្ញា។ [84] ក្នុងករណី តុលាការរកឃើញថាអនីតិជនជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ដោយត្រូវប្រកាសថារួចផុតពីការចោទប្រកាន់ និងដោះលែងឱ្យមានសេរីភាព។[85]

### ខ.១.២. អាយុពី ១៤ឆ្នាំ ដល់ ក្រោម១៨ឆ្នាំ

ដោយឡែក អនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ត្រឹមអាយុ ១៨ឆ្នាំ ដែលបានប្រព្រឹត្តបទលហុ ពុំមានការទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ ដោយមន្ត្រីនគរបាលមានសមត្ថកិច្ចគ្រាន់តែយកអនីតិជនជននោះទៅធ្វើការណែនាំ ព្រមានដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ។[86] ប៉ុន្តែ អនីតិជនអាចត្រូវបានចាប់ខ្លួនបានតែក្នុងបទល្មើសមជ្ឈិម ឬបទឧក្រិដ្ឋជាក់ស្តែងតែប៉ុណ្ណោះ។ ចំពោះអនីតិជន ដែលមានអាយុ ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ដែលប្រព្រឹត្តបទឧក្រិដ្ឋ មិនអាចត្រូវបានគេឃាត់លើសពីរយៈពេល ៤៨ ម៉ោងឡើយ ក្នុងបទមជ្ឈិម មិនអាចត្រូវលើសពីរយៈពេល ៣៦ ម៉ោង។[87]

ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ ១៦ឆ្នាំ ការចាប់ខ្លួនអាចធ្វើទៅបានតែក្នុងករណីប្រព្រឹត្តបទមជ្ឈិមដោយចេតនា ប៉ុន្តែការចាប់ខ្លួនខាងលើ ត្រូវជូនជាដំណឹងទៅដល់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី-ខេត្ត។[88] បន្ថែមពីនេះ ការឃាត់ខ្លួនអនីតិជនដែលបានប្រព្រឹត្តបទឧក្រិដ្ឋ មិនអាចត្រូវបានគេឃាត់លើសពីរយៈពេល ៣៦ ម៉ោងឡើយ [89] និងបទមជ្ឈិម មិនអាចលើសពីរយៈពេល ២៤ ម៉ោង។

---

[83] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦, មាត្រា២៧ កថាខណ្ឌ១

[84] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦, មាត្រា ១៣ និងមាត្រា ១៤ ក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា ២១២

[85] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦, មាត្រា ៤៩ កថាខណ្ឌ១

[86] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦, មាត្រា ១៣

[87] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា ៩៦ កថាខណ្ឌ៣

[88] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦, មាត្រា ១៥

[89] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា ២១៤

ប្រសិនបើផុតរយៈពេលនៃការឃាត់ខ្លួនដែលច្បាប់បានអនុញ្ញាតនេះ បុគ្គលដែលត្រូវបានគេឃាត់ខ្លួនអាចត្រូវបានគេដោះលែងឱ្យមានសេរីភាពឡើងវិញ ឬបញ្ជូនខ្លួនទៅព្រះរាជអាជ្ញា ។

គ្រប់បុគ្គលដែលបំពេញមុខងារណាមួយពាក់ព័ន្ធនឹងអនីតិជន ត្រូវធានាឱ្យមានការគោរពគោលការណ៍មិនត្រូវប្រើទារុណកម្ម ទណ្ឌកម្ម ឬប្រព្រឹត្តផ្សេងៗទៀត តាមគ្រប់រូបភាពទៅលើរូបរាង កាយ និងផ្លូវចិត្តរបស់អនីតិជន។[90]

### ខ.២. ការឃុំខ្លួនជាបណ្តោះអាសន្ន

ការឃុំខ្លួនជាបណ្តោះអាសន្នលើជនជាប់ចោទ ជាអនីតិជនមានអាយុចាប់ពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ចំពោះបទមជ្ឈិមមិនអាចឃុំខ្លួនបណ្តោះអាសន្នលើសពី ៤ខែ បានទេ ហើយថិរវេលានេះ មិនត្រូវលើសពីពាក់កណ្តាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ។ ចំណែក ជនជាប់ចោទជាអនីតិជនមានអាយុចាប់ពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ចំពោះបទឧក្រិដ្ឋមិនអាចឃុំខ្លួនលើសពី ៦ ខែបានទេ។[91]

ជនជាប់ចោទ ជាអនីតិជនមានអាយុចាប់ពី ១៤ឆ្នាំ រហូតដល់ក្រោម ១៦ឆ្នាំ ការឃុំខ្លួនបណ្តោះអាសន្នចំពោះបទមជ្ឈិម មិនអាចឃុំខ្លួនលើសពី ២ខែទេ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នខាងលើនេះ មិនត្រូវលើសពីពាក់កណ្តាលនៃអប្បបរមានៃទោសដែលច្បាប់កំណត់ឡើយ។ ចំពោះបទឧក្រិដ្ឋមិនអាចឃុំខ្លួនលើសពី ៤ខែបានទេ។ បន្ថែមពីនេះ ការឃុំខ្លួនបណ្តោះអាសន្នត្រូវគិតបញ្ចូលទាំងស្រុងទៅក្នុងថិរវេលានៃទោសដាក់ពន្ធនាគារដែលត្រូវទទួល។[92] ការឃុំខ្លួនបណ្តោះអាសន្នរងចាំសវនាការ គឺជាជម្រើសចុងក្រោយសម្រាប់អនីតិជន ដោយយោងទៅតាមគោលការណ៍នៃការសន្មតជាមុនថាគ្មានទោស និងដើម្បីលើកកម្ពស់ការប្រើប្រាស់នូវប្រភេទទោសផ្សេងៗទៀត ក៏ដូចជាទោសការងារសហគមន៍។[93]

ដូចគ្នានេះការប្រើប្រាស់នូវ ការដាក់ឱ្យស្ថិតក្រោមត្រួតពិនិត្យតាមផ្លូវតុលាការ[94] ឬការព្យួរទោស ឬការដោះលែងដោយមានលក្ខខណ្ឌគួរត្រូវបានប្រើប្រាស់ជំនួសឱ្យការដាក់ទោសពន្ធនាគារមកលើអនីតិជន។ ឧទាហរណ៍ អនីតិជន ក្នុងបទលួច ការឃុំខ្លួនបណ្តោះអាសន្ន បើលើសពី ១ខែ កន្លះ (មិនឱ្យលើពីអប្បរមានៃទោស ដែលច្បាប់បានកំណត់សម្រាប់អនីតិជន)។[95]

---

[90] ច្បាប់ស្តីពីយុត្តិធម៌អនីតិជនចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦, មាត្រា ៥ និង មាត្រា ៦

[91] ក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧, មាត្រា ២១៣

[92] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩, មាត្រា ៥១

[93] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩, មាត្រា ១៦២

[94] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦, មាត្រា ៤០

[95] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦, មាត្រា២១៤ កថាខណ្ឌ៣

ការឃុំខ្លួនបណ្តោះអាសន្នត្រូវបានលើកឡើងថា មិនគួរមានការឃុំខ្លួនជនជាប់ចោទដែលជាអនីតិជនឡើយ ដោយសារតែសភាពចង្អៀតណែន បានបង្កការលំបាកចំពោះកុមារច្រើនដែលជាប់ឃុំ។ ក្នុងនោះដែររាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា កំពុងតែពន្លឿនការដោះស្រាយសំណុំរឿងការឃុំខ្លួនអនីតិជន ហើយការឃុំឃាំងអនីតិជន គឺសុទ្ធសឹងតែជាករណីចាំបាច់។ តាមការឃ្លាំមើលរបស់ អង្គការលីកាដូ *បានឱ្យដឹងថាពន្ធនាគារចំនួន ១៩ កន្លែង មានអនីតិជនចំនួន ៥២ ភាគរយ ពួកគេត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ន ដើម្បីរង់ចាំសវនាការ* [96] *ដែលមានចំនួនរហូតដល់ទៅមួយពាន់នាក់ (១.៦៥៨ នាក់) ដែលគិតត្រឹមខែមេសា ឆ្នាំ ២០២៣។*

**គ. សិទ្ធិទទួលបានសវនាការជាអសាធារណៈ**

ដូចបានរៀបរាប់នៅក្នុងចំណុច (ខ) ខាងលើការកំណត់រយៈពេលសវនាការពិតជាសំខាន់ ដែលមិនអាចពន្យាបាន ដោយសារការពន្យាពេលអាចនាំឱ្យមានការប៉ះពាល់ដល់បុរេនិច្ឆ័យរបស់ជនជាប់ចោទដែលជាអនីតិជន។ ការពិភាក្សាដេញដោល និងប្រកាសសាលក្រមត្រូវធ្វើឡើងក្នុងសវនការជាអសាធារណៈ ក្នុងនោះមានតែបុគ្គលដែលមានសិទ្ធិ កាតព្វកិច្ច ឬផលប្រយោជន៍ដែលពាក់ព័ន្ធនឹងរឿងក្តីប៉ុណ្ណោះ ដែលមានសិទ្ធិចូលរួមក្នុងសវនាការ។ អ្នកតំណាងដែលច្បាប់បានកំណត់ ឬ ទំនុកបម្រុងអនីតិជន ត្រូវចូលរួមក្នុងសវនាការលើកលែងតែមានសំណូមពរ ពីអនីតិជនផ្ទុយពីនេះ ឬ តុលាការយល់ឃើញថាការចូលរួមរបស់បុគ្គលទាំងនោះមិនបម្រើឧត្តមប្រយោជន៍របស់អនីតិជន។[97]

នៅពេលជំនុំជម្រះក្នុងបទមជ្ឈិម និងឧក្រិដ្ឋ ដាច់ខាតចាំបាច់ត្រូវមានមេធាវីនៅក្នុងសវនាការ។ [98] ក្នុងករណីអនីតិជន មិនមានមេធាវី ឬមិនបានជ្រើសរើសមេធាវី ប្រធានតុលាការ ត្រូវចាត់តាំងមេធាវីមិនយកកម្រៃនៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ តុលាការត្រូវផ្តល់ពេលវេលាសមស្រប និងលិខិតចម្លងសំណុំរឿងទៅឱ្យមេធាវីសម្រាប់រៀបចំការពារ។ សោហ៊ុយសម្រាប់ធ្វើដំណើរការចម្លងសំណុំរឿងជាបន្ទុកមេធាវី ដែលត្រូវជ្រើសរើស ការពារក្តីឱ្យអនីតិជន។

## ២.៣. សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ដើមបណ្តឹងរដ្ឋប្បវេណី ឬម្ចាស់បណ្តឹងព្រហ្មទណ្ឌ ជារូបវន្តបុគ្គលក្នុងសំណុំរឿងទាមទារឱ្យជនជាប់ចោទសងសំណងព្យសនកម្មក្នុងអំពើអនីត្យានុកូល។ សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានផ្តល់ឱ្យដូចជនជាប់

[96] អង្គការមណ្ឌលពត៌មានស្ត្រីកម្ពុជា *"អត្ថបទស្រាវជ្រាវ៖ហេតុអ្វីLICADHOចាត់ទុកការឃុំខ្លួនបណ្តោះអាសន្នលើអនីតិជនជារឿងមិនចាំបាច់?"* ចូលមើលថ្ងៃទី២ មិថុនា ២០២៣

[97] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦, មាត្រា ៤៧

[98] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦, មាត្រា ៥០

ចោទដែរ រួមមាន៖ សិទ្ធិតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សិទ្ធិដាក់ភស្តុតាង ពិនិត្យភស្តុតាង និងសាក្សី សិទ្ធិធ្វើបណ្តឹងជិតជិត សិទ្ធិទាមទារសំណងជួសជុលពន្យសនកម្ម។

**ក. សិទ្ធិតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

ជនរងគ្រោះនៃបទល្មើស អាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាននៅចំពោះមុខតុលាការ ប្រសិនបើខ្លួនពុំទាន់បានតាំងខ្លួននៅឡើយនៅមុខចៅក្រមស៊ើបសួរ។[99] ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាវិធានមួយដែលអនុញ្ញាតឱ្យជនរងគ្រោះ ឬភាគីដែលមានសិទ្ធិអាចធ្វើការទាមទារសំណង នៅក្នុងនីវិធីស៊ើបសួរ។ ប៉ុន្តែ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនអាចទទួលបានទេ ក្រោយពីសេចក្តីសន្និដ្ឋានសុំរបស់ព្រះរាជអាជ្ញាលើអង្គសេចក្តី។[100] ដោយសារតែ ព្រះរាជអាជ្ញាជាម្ចាស់បណ្តឹងអាជ្ញាដែលដើរតួជំនួសជនរងគ្រោះនៅក្នុងការប្តឹងទាមទាររកយុត្តិធម៌នៅក្នុងលំហូរនីតិវិធី។ យោងតាមមាត្រា ៣១៤ បានលើកឡើង ការតំណាងរបស់របស់ជនរងគ្រោះ ក្នុងនោះដែរ ដើមបណ្តឹងរដ្ឋប្បេណីក៏អាចត្រូវបានអមដោយមេធាវីដែលខ្លួនបានជ្រើសរើស ដើម្បីតំណាងនៅក្នុងនីតិវិធីទាមទារស្នើសុំប្តឹង និងទាមទារសំណងជុសជុលព្យសនកម្មលើអំពីអនីត្យានុកូលរបស់ជនល្មើសទៅកាន់តុលាការដែលបានកំណត់នៅក្នុងមាត្រានេះ ដើមបណ្តឹងរដ្ឋប្បវេណីក៏អាចត្រូវបានតំណាងដោយមេធាវីសហព័ទ្ធ ឬញាតិលោហិតផ្ទាល់ដែរ។ អ្នកតំណាងដែលមិនមែនជាមេធាវី ត្រូវតែមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ។[101]

**ខ. សិទ្ធិដាក់ភស្តុតាង ពិនិត្យភស្តុតាង និងសាក្សី**

ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកតំណាងស្របច្បាប់ មានសិទ្ធិស្នើសុំដាក់បញ្ចូលភស្តុតាង ឬសិទ្ធិស្នើសុំពិនិត្យភស្តុតាងបានដោយផ្អែកតាមការស្នើសុំ។ ការស្នើសុំពិនិត្យភស្តុតាង អាចធ្វើឡើងនៅក្នុងពេលសវនាការដើម្បីឱ្យតុលាកធ្វើកោសល្យវិច័យភស្តុតាង ដោះបន្ទុករបស់ជនជាប់ចោទ ក្នុងលក្ខខណ្ឌសង្ស័យថាមានការក្លែងបន្លំស្ថានភាពនៃភស្តុតាង។ ក្នុងនោះផងដែរ ដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំដាក់បញ្ចូលភស្តុតាងបន្ថែម ដើម្បីបង្ហាញថាខ្លួន ពិតជារងអំពើដោយសារតែសកម្មភាពរបស់ជនជាប់ចោទពិតមែន។ មានន័យថា គាត់អាចស្នើឱ្យតុលាការពិនិត្យភស្តុតាង ឬពិនិត្យទៅលើសមត្ថភាពរបស់សាក្សី។

[99] ក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ *"របៀបប្តឹងទៅតុលាការ"*, មាត្រា ២៩១ (៣)

[100] ក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៣១១

[101] ក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ២៩១ កថាខណ្ឌ៤ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី គឺជាបុគ្គលគ្រប់រូបដោយអនុវត្តតាមច្បាប់ដែលត្រូវតែជួសជុលព្យសនកម្មដែលបណ្តាលឱ្យមានដល់ជនរងគ្រោះនៃបទល្មើស ។

ក្នុងនោះដែរ ការបន្ថែមសាក្សីដើម្បីជាគ្រឹះនៃការទាមទារ ការសាកសួរសាក្សីភាគីជនជាប់ចោទ ត្រូវបានផ្តល់ឱ្យដូចគ្នា តាមនីតិវិធីច្បាប់ចំពោះដើមបណ្តឹងរដ្ឋប្បវេណី បើទោះបីជាមានព្រះរាជអាជ្ញាជាម្ចាស់បណ្តឹងព្រហ្មទណ្ឌក៏ដោយ។

ឧទាហរណ៍៖ បទល្មើស រំលោភទំនុកចិត្ត និងបទឆបោក។ ក្នុងនោះភស្តុតាងប្រសិទ្ធភាពអាចជាលិខិតលាយលក្ខណ៍អក្សរដោយភ្ជាប់មកជាមួយនឹងស្នាមមេដៃ ឬហត្ថលេខារបស់ជនជាប់ចោទ។

**គ. សិទ្ធិដាក់បណ្តឹងជិតជិត**

ក្នុងករណីចៅក្រមដែលទទួលបន្ទុករឿងក្តី ធ្វើការសម្រេចសេចក្តីដោយមានភាពលំអៀង និងមិនអាចផ្តល់យុត្តិធម៌ នោះភាគីណាមួយនៃរឿងក្តីអាចដាក់ពាក្យបណ្តឹងជិតចិត្តចៅក្រម ដើម្បីធ្វើការប្តូរចៅក្រមចេញពីការទទួលបន្ទុករឿងក្តីបាន កាលបើមានមូលហេតុត្រឹមត្រូវតាមច្បាប់កំណត់ ដូចខាងក្រោម៖[102]

១. កាលណាចៅក្រមមានទំនាក់ទំនងជាមួយភាគីនៃរឿងក្តី

២. កាលណាចៅក្រម ឬ សហព័ទ្ធរបស់ចៅក្រម ឬអតីតសហព័ទ្ធរបស់ចៅក្រមជាភាគីណាមួយក្នុងរឿងក្តី ឬញាតិលោហិតក្នុងថ្នាក់ទី ៦ ឬ ញាតិពន្ធក្នុងថ្នាក់ទី ៣ ឬ អតីតញាតិពន្ធក្នុងថ្នាក់ទី ៣ របស់ភាគីណាមួយ។

៣. ក្នុងករណី ចៅក្រមទទួលបន្ទុក បានទទួលផលប្រយោជន៍ពីសំណុំរឿង

៤.ចៅក្រមដែលទទួលបន្ទុករឿងក្តី ធ្លាប់ ឬ កំពុងមានវិវាទនៅតុលាការ ជាមួយភាគីណាមួយ

៥. ចៅក្រមធ្លាប់បានធ្វើជាសាក្សី ឬ អ្នកជំនាញក្នុងរឿងក្តី

៦. ចៅក្រម ធ្លាប់ជាអ្នកតំណាង ឬជាអ្នកជំនួយឱ្យភាគីចំពោះរឿងក្តី

ផ្អែកតាមមូលហេតុខាងលើនេះ តុលាការត្រូវសម្រេចសេចក្តីអំពីការដកហូតនោះ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

សរុបមកប្រសិន បើគូភាគីនៃវិវាទយល់ឃើញថាចៅក្រម ឬក្រឡាបញ្ជីជំនុំជម្រះក្តីរបស់ខ្លួនមានភាពលំអៀង វិនិច្ឆ័យដោយអយុត្តិធម៌ នោះភាគីអាចដាក់ពាក្យបណ្តឹងប្តឹងជិតចិត្តចៅក្រម ឬក្រឡាបញ្ជីដែលទទួលបន្ទុកសំណុំរឿងនោះនៅតុលាការដែលចៅក្រមស្ថិតនៅ។

**ឃ. សិទ្ធិទាមទារសំណងជួសជុលព្យសនកម្ម**

គោលបំណងនៃបណ្តឹងរដ្ឋប្បវេណី គឺដើម្បីទាមទារសំណងជំងឺចិត្តពីជនជាប់ចោទ។ ដើម្បីទទួលបានការជួសជុលថ្លៃខូចខាត សំណងជំងឺចិត្ត ឬដំណោះស្រាយកែតម្រូវផ្សេងៗ ដើមបណ្តឹងត្រូវបង្ហាញថា សកម្មភាព

---

[102] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៥៥៦

របស់ជនជាប់ចោទបានបណ្តាលឱ្យមានការបាត់បង់ ឬខូចខាត។ ជាធម្មតា ជនជាប់ចោទដែលត្រូវបានកាត់ទោស ត្រូវសងការខូចខាតរដ្ឋប្បវេណី ដែលបណ្តាលមកពីសកម្មភាពល្មើសរបស់ខ្លួន ។ ជនរងគ្រោះអាចស្នើសុំទាមទារសំណងផ្នែកសម្ភារ នៅពេលដែលជនជាប់ចោទបានប្រព្រឹត្តបទល្មើស បណ្តាលឱ្យមានការប៉ះពាល់ដល់ទ្រព្យសម្បត្តិ និងការខូចខាតជាច្រើនក្រោមអំពើរបស់ជនល្មើស។ សំណងជំងឺចិត្ត និងសំណងលើរូបរាងកាយក៏ត្រូវបានរាប់បញ្ចូលជាមូលហេតុនៃការទាមទារ ការជួសជុលព្យសនកម្មខាងផ្លូវចិត្ត មានដូចជា វិបល្លាសស្មារតី ឬជំងឺផ្លូវចិត្ត ឬសតិអារម្មណ៍លើផ្លូវចិត្តរបស់ជនរងគ្រោះដូចជាជំងឺបាក់ស្បាត ជាអាទិ៍។[103]

ករណី៖ ការទាមទារសំណងរបស់ ជនរងគ្រោះឈ្មោះ ឈឹម សុធា ក្នុងសំណុំរឿង០០១ អ.វ.ត.ក បានរៀបរាប់លម្អិតពីផលវិបាកចំពោះស្ថានភាពរាងកាយ និងផ្លូវចិត្តរបស់សមាជិកគ្រួសារនៃជនរងគ្រោះផ្ទាល់ពីមន្ទីរស២១ និងប្រភេទនៃការប៉ះទង្គិចផ្លូវចិត្ត ដែលបណ្តាលមកពីការយល់ដឹងអំពីមរណភាពសាច់ញាតិនៅមន្ទីរស២១។[104] ក្នុងនោះរួមបញ្ចូលទាំងការកំណត់បង្ហាញពីការឈឺចាប់របស់ជនងគ្រោះ កំហុស ភាពមិនអាចជួយបាន និងស្ថានភាពវិកលចរិត ដូចជាជំងឺបាក់ស្បាត ជាដើម។

ក្នុងករណីនេះដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែធ្វើការបញ្ជាក់ និងដាក់ភស្តុតាងក្នុងការបង្ហាញពីការខូចខាត និងព្យសនកម្មផ្នែកសតិអារម្មណ៍មកលើខ្លួន។ ដូចនេះ ជនរងគ្រោះត្រូវតែបង្ហាញពីការខូចខាតចំពោះអំពើ របស់ជនល្មើសទៅតុលាការ ដើម្បីឱ្យតុលាការធ្វើការថ្លឹងថ្លែងពីភាពអនីត្យានុកូលនៃបទល្មើស។ ប៉ុន្តែចំពោះករណីខ្លះជនរងគ្រោះពុំអាចទាមទារសំណង់ជំងឺចិត្តផ្នែកសតិស្មារតីបាននោះ ដោយសារតែកម្រិតនៃការខូចខាត និងការវាយតម្លៃលើការខូចខាតមិនអាចយកជាការបាន។

---

[103] រឿងក្តីឌុចៈសាលក្រម អ.វ.ត.ក អ.ជ.ស.ដ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌទី៦៤១។ រឿងក្តីនួនជា អៀងសារី ខៀវសំផន និងអៀងធីរិទ្ធិៈបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងភាពអាចទទួលបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក អ.ប.ជ ២៤ មិថុនា ២០១១ កថាខណ្ឌ៤៣។ រឿងក្តីឌុចៈសាលដីកា អ.វ.ត.ក អ.ជ.ត.ក ២៤ មិថុនា ២០១១ កថាខណ្ឌ៨៣។

[104] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក), សាលក្រម អ.វ.ត.ក៖ ករណី កាំងហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១០ ទំព័រ៣៦៦ កំណត់សម្គាល់លេខ១០៧៣ .ប្រតិចារិក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩ ឈឹម សុធារ៉ា ទំព័រ៤១,៤២-៤៤,៤៦។

# ជំពូកទី៣
# បញ្ហាប្រឈមក្នុងការទទួលបានការជម្រះក្តីដោយយុត្តិធម៌ និងដំណោះស្រាយ

# ជំពូកទី៣

# បញ្ហាប្រឈមក្នុងការទទួលបានការជម្រះក្តីដោយយុត្តិធម៌ និងដំណោះស្រាយ

ទោះបីជាមានច្បាប់ការពារសិទ្ធិយ៉ាងណាក៏ដោយ ប៉ុន្តែបញ្ហាប្រឈមនៅតែកើតមានជារឿយៗ។ ជាពិសេសការអនុវត្តជាក់ស្តែងនឹងដោយផ្ទាល់។ បញ្ហាប្រឈមទាំងនេះរួមមាន៖ ការរំលោភសិទ្ធិជនជាប់ចោទដែលជានីតិជន និងអនីតិជន ការឃុំខ្លួនលើសការកំណត់ បញ្ហាការយល់ដឹងពីសិទ្ធិជនជាប់ចោទ កត្តាជីវភាពកង្វះខាតមេធាវី កង្វះខាតប្រព័ន្ធផ្សព្វផ្សាយជាអាទិ៍។ កត្តាទាំងនេះហើយដែលបណ្តាលឱ្យបុគ្គលទាំងអស់ពិបាកក្នុងការទទួលបានការជម្រះក្តីដោយយុត្តិធម៌។

## ៣.១ ការរំលោភសិទ្ធិជនជាប់ចោទដែលជានីតិជន និងអនីតិជន

នៅប្រទេសកម្ពុជា បញ្ហាយុត្តិធម៌ជាបញ្ហាចោទយ៉ាងខ្លាំង ដែលជះឥទ្ធិពលដល់ការទទួលបានការជម្រះក្តីដោយយុត្តិធម៌។ ការរំលោភសិទ្ធិភាគច្រើនត្រូវបានរកឃើញ ជាបន្តបន្ទាប់។ ក្នុងករណីមួយចំនួនដែលគ្មានភស្តុតាងគ្រប់គ្រាន់ ប៉ុន្តែការចាប់ខ្លួន ការឃុំខ្លួនត្រូវបានធ្វើឡើងដោយមន្ត្រីអនុវត្តច្បាប់។ បញ្ហាទាំងនេះជាបញ្ហាប្រឈម នាំឱ្យមានភាពមិនប្រក្រតី និងប្រតិសកម្មនៃច្បាប់ ក៏ដូចជាការធ្វេសប្រហែសរបស់មន្ត្រីអនុវត្តផ្ទុយនឹងបទប្បញ្ញត្តិច្បាប់។ ពោលពេលខ្លះ ពួកគាត់អនុវត្តលើសដែនកំណត់ ដែលបានកំណត់ដោយច្បាប់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ដោយឡែក ជនជាប់ចោទភាគច្រើនត្រូវបានសន្មតទុកជាមុនថាមានទោស ទោះបីជននោះជាជនសង្ស័យក៏ដោយ។ ដូច្នេះបើ ពួកគាត់ត្រូវបានគេសន្មតថាមានទោស គឺស្ថាប័នតុលាការបានរំលោភសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ ដែលច្បាប់បានកំណត់។

មុនពេលសវនកម្មច្បាប់ ការរំលោភបំពានកើតមានឡើយចំពោះជនជាប់ចោទ ឬជនរងគ្រោះ ប៉ុន្តែក្រោយកំណែទម្រង់ប្រព័ន្ធច្បាប់ ការរំលោភបំពានត្រូវបានរកឃើញថាមានការកាត់បន្ថយ។ ចំពោះខ្លឹមសារដែរយើងខ្ញុំលើកពីការរំលោទសិទ្ធិជនជាប់ចោទ មកបកស្រាយដោយឃើញពីភាពខ្វះចន្លោះនាពេលជម្រះក្តី។ ក្នុងចំណុចនេះ យើងនឹងបង្ហាញនូវការរំលោភនូវសិទ្ធិមួយចំនួនទៀត ក្នុងការឃុំខ្លួនលើការកំណត់ ការធ្វើទារុណកម្មឱ្យសារភាព និងបញ្ហាប្រឈមផ្សេងៗទៀតដែលតែងតែកើតមានកន្លងមក។

### ក. ការឃុំខ្លួនបណ្តោះអាសន្នលើសការកំណត់

ការឃុំខ្លួនបណ្តោះអាសន្នលើសការកំណត់ កើតឡើងដោយសារការប្រើអំណាចលើសដែនកំណត់របស់មន្ត្រីអនុវត្តច្បាប់ក្នុងដំណើរនីតិវិធី ហើយអាចធ្វើទៅបានចំពោះពលរដ្ឋដែលទន់ខ្សោយជាងខ្លួន។ ការជំនុំជម្រះជនជាប់ចោទត្រូវធ្វើឡើងក្នុងអំឡុងពេល ០៦ ខែ ចាប់តាំងពីពេលចាប់ខ្លួន[105]ប៉ុន្តែភាគច្រើនការឃុំខ្លួនលើសការ

[105]ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា២០៨, មាត្រា២០៩, មាត្រា២១៣ (២)

កំណត់តែងតែកើតឡើងចំពោះអនីតិជន ដោយសារការទទួលបានការពន្យល់ពីសិទ្ធក្នុងការ ឃុំខ្លួនរបស់អនីតិជន ពីសំណាក់មន្ត្រីនគរបាលនៅមានកម្រិត។ ក្នុងលក្ខខណ្ឌមួយចំនួន ជនជាប់ចោទភាគច្រើនត្រូវបានឃុំខ្លួនលើសការកំណត់ ដោយភាពមិនអើពើរបស់មន្ត្រីតុលាការដែល ហាក់ដូចជាមិនមានសកម្មភាពអ្វីពីសំណាក់ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ។

ការឃុំខ្លួនយូរលើសការកំណត់ ភាគច្រើនបណ្តាលមក ពីសមត្ថភាពមានកម្រិតរបស់ប្រព័ន្ធតុលាការ។ លើសពីនេះទៅទៀតអាជ្ញាធរ ឃុំជនត្រូវចោទខ្លះមុនសវនាការលើសរយៈពេលអតិបរិមាដែលកំណត់ដោយច្បាប់ ឬដោយគ្មានតំណាងផ្នែកច្បាប់។ ជាហេតុនាំឱ្យ មានការកក់ស្ទះសំណុំរឿង មិនទាន់ចាត់ការ និងការពន្យាពេលយូរក្នុងការទទួលបានសាលដីកា បណ្តាលឱ្យប៉ះពាល់ដល់សិទ្ធិក្នុងការធ្វើការតតាំងនៅក្នុងតុលាការប្រឆាំងនឹងមូលដ្ឋានច្បាប់ ឬលក្ខណៈធ្វើតាមតែទំនើងចិត្ត ដើម្បីឃុំខ្លួនបុគ្គលណាម្នាក់ ។

នៅក្នុងសំណុំរឿងរវាង រដ្ឋអាជ្ញា ទល់នឹងលោក តាំង ហ្គិចអៀវ ឬស្គាល់ថា ឌុច នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សាលាជំនុំជម្រះទទួលស្គាល់ថា ឌុច ត្រូវបានឃុំខ្លួនដោយខុសច្បាប់ដោយគ្មានការជំនុំជម្រះអស់រយៈពេល ៨ ឆ្នាំ លើសពីអាជ្ញាយុកាលកំណត់ មុននឹងត្រូវបានបញ្ជូនទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា [106]។ ដូច្នេះ នៅពេលផ្តន្ទាទោសជាប់ពន្ធនាគារអស់មួយជីវិតទៅលើ ឌុច សាលាជំនុំជម្រះបានបន្ថយទោស រយៈពេល ៥ ឆ្នាំជាសំណងដល់ការឃុំខ្លួន ឌុច ដោយខុសច្បាប់ និងការឃុំខ្លួនបណ្តោះអាសន្ន។ ប៉ុន្តែតុលាការកំពូលបានបដិសេធសេចក្តីសម្រេចនេះ ដោយមិនរាប់បញ្ចូលក្នុងការផ្តន្ទាទោសឡើយ។

**ខ. ការធ្វើទារុណកម្ម ឬបង្ខំឱ្យសារភាព**

ការវាយដំក្នុងពេលចាប់ខ្លួន និងពេលបញ្ជូនខ្លួន នៅក្នុងដំណាក់កាលមន្ត្រីនគរបាល លើជនជាប់ចោទ ឬជនសង្ស័យដែលជានីតិជន និងអនីតិជនតែងតែកើតមានឡើងជាហូរហែរ។ នគរបាលយុត្តិធម៌មួយចំនួនមិនបានយល់ច្បាស់អំពីនីតិវិធីច្បាប់ ហើយចូលចិត្តប្រើនូវទារុណកម្មដ៏កាចសាហាវក្នុងកំឡុងពេលឃុំខ្លួន។ ករណីខ្លះទៀតអាជ្ញាធរបង្ខំឱ្យសារភាព ដោយការវាយដំ ឬការគំរាមកំហែងលើជនជាប់ចោទដែលមិនចេះអក្សរ ជាញឹកញាប់ និងមិនបានប្រាប់ពីសេចក្តីនៅក្នុងចម្លើយសារភាពហើយបង្ខំឱ្យចុះហត្ថលេខា។ ហេតុនេះធ្វើឱ្យចម្លើយរបស់ជនជាប់ចោទជាចម្លើយត្រូវបានបំពានសិទ្ធិ ប្រសិនបើមេធាវីការពារសិទ្ធិជនជាប់ចោទគិតថាចំណុចនេះមិនមែនជាចំណុចសំខាន់។

*របាយការណ៍របស់អង្គការ លីកាដូ ៩០ ភាគរយ បានអះអាងថា វាកើតឡើងនៅក្នុងការឃុំឃាំងរបស់នគរបាល ដែលជាញឹកញាប់នៃការបំពាន គឺនៅក្នុងទម្រង់នៃការទាញយកការសារភាព។ អំពើប្រព្រឹត្តទៅលើអ្នក*

[106] សូមមើលព័ត៌មានទូទៅសង្ខេបនៃសំណុំរឿងលេខ ០០១ របស់អ.វ.ត.ក តាមរយៈ https://www.eccc.gov.kh/en/case/topic/1

*សង្ស័យនៅទីស្នាក់ការនគរបាលក្នុងប្រទេសកម្ពុជា គឺគួរឱ្យព្រួយបារម្ភ ពីព្រោះច្បាប់មិនបានអនុញ្ញាតជនសង្ស័យ ឱ្យនិយាយជាមួយ មេធាវី ឬសមាជិក គ្រួសារ ក្នុងអំឡុងពេល២៤ ម៉ោងដំបូង នៃការឃុំឃាំង ហើយអ្នកជាប់ឃុំឃាំកម្រនឹងទទួលបានការផ្តល់ព័ត៌មានអំពីសិទ្ធរបស់អ្នកទាំងនោះ នៅពេលដែលត្រូវបានចាប់ខ្លួន។ យោងតាមមាត្រា៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា ទាល់តែ "បន្ទាប់ពី រយៈពេល ២៤ម៉ោង ចាប់តាំងពីការចាប់ផ្តើមឃុំខ្លួនរបស់នគរបាលបានផុត ទើបអ្នកជាប់ឃុំឃាំងអាចស្នើសុំជួបនិយាយជាមួយមេធាវី ឬអ្នកឯទៀត។ បន្ថែមពីនេះទៀត ច្បាប់ទាក់ទងនឹងការឃុំខ្លួនអនីតិជន ក៏មិនបានបញ្ជាក់ពីរយៈពេល ជាក់លាក់សម្រាប់ជូនដំណឹងទៅដល់មាតាបិតា ឬ អាណាព្យាបាល បន្ទាប់ពីការចាប់ខ្លួននោះឡើយ។ ក្រោមច្បាប់នេះ ជនសង្ស័យអាចត្រូវបានឃុំឃាំង ដោយគ្មានមធ្យោបាយទាក់ទងសាច់ញាត្តិ រយៈពេលយ៉ាងតិច ២៤ម៉ោង ហើយអ្នកទាំងនោះជាធម្មតាត្រូវបានសួរចម្លើយដោយមិនមានវត្តមាននៃអ្នកតំណាងផ្នែកច្បាប់ ដោយពួកគាត់មិនបានទទួលព័ត៌មានអំពីសិទ្ធរបស់គាត់ក្នុងការរកមេធាវី ឬសិទ្ធរបស់គាត់ក្នុងការមិនឆ្លើយសំនួរនគរបាល ឡើយ។ នៅក្នុងកំឡុងពេលដំបូងនេះ ហើយដែលការសារភាពត្រូវបានទាញយកបាន ដែលជាញឹកញាប់នៅក្រោម ឬក្នុងការបង្ខិតបង្ខំ។*

ការបង្ខំឱ្យសារភាពមិនទាន់ត្រូវបានគោរពពេញលេញ ដោយសារតែជនជាប់ចោទមួយចំនួនទៀត រួមទាំងកុមារបានអះអាង ថាពួកគេបានទទួលរងអំពើហិង្សា ឬការធ្វើទារុណកម្ម ដើម្បីបង្ខិតបង្ខំឱ្យពួកគេឆ្លើយសារភាពអំពីបទល្មើស ដែលបានចោទប្រកាន់ (ជនជាប់ចោទចំនួន ៣ នាក់ ក្នុងចំណោម ១១៨ នាក់) នៅដំណាក់កាលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌។ អំពើហិង្សាលើកុមារមិនត្រូវបានអើពើ អនីតិជនបានរាយការណ៍ថាខ្លួនត្រូវរងអំពើហិង្សា ដោយមិនត្រូវបានអើពើនៅពេល ជាប់ឃុំ ឬដាក់ឱ្យឃុំខ្លួនបណ្តោះអាសន្នតាមផ្លូវតុលាការ។ អនីតិជន នៅអំឡុងពេលឃុំមិនទទួលបានការមើលថែ ឬយកចិត្តទុកដាក់ពីមន្ត្រីពន្ធនាគារ ប៉ុន្តែបែរជាត្រូវទទួលរងអំពើហិង្សាលើរូបរាង កាយ ដែលនាំឱ្យប៉ះទង្គិចបញ្ញាស្មារតី និងនីតិសម្បទារបស់អនីតិជន។

*"យោងតាមរបាយការណ៍ពីមជ្ឈមណ្ឌលសិទ្ធិមនុស្ស សិទ្ធិមិនត្រូវបានបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង នៅតែបន្តមិនទាន់ត្រូវ បានគោរពពេញលេញ។ នៅអំឡុងពេលធ្វើរបាយការណ៍នេះ មានចំនួន ២,៥% នៃជនជាប់ចោទទាំងអស់ នៃសំណុំរឿងដែលបានសង្កេត ពួកគេអះអាងថាទទួលរងអំពើហិង្សា ឬទារុណកម្មដើម្បីទទួលបានចម្លើយ សារភាពរបស់ពួកគេនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌។ អត្រានេះគឺទាបជាងរបាយការណ៍មុនៗ គឺ ចំនួន៦,៧% នៃជនជាប់ចោទនៅឆ្នាំ២០១៩/២០២០,ចំនួន៤,៣%នៃជនជាប់ចោទនៅឆ្នាំ២០១៨/ ២០១៩, ចំនួន ៧% នៃជនជាប់ចោទនៅឆ្នាំ២០១៧/២០១៨ និងឆ្នាំ២០១៦/២០១៧ និងចំនួន ៤% នៃជនជាប់ចោទនៅឆ្នាំ២០១៤/២០១៥ បានលើកឡើងបញ្ហានេះ ទោះបីជាអត្រាចុង*

*ក្រោយនេះគួរឱ្យ សាទរ ប៉ុន្តែការលើកឡើងអំពីអំពើហិង្សា ឬការធ្វើទារុណកម្មនៅតែជាបញ្ហា ហើយចាំបាច់ត្រូវមានការ ស៊ើបអង្កេតភ្លាមៗ និងហ្មត់ចត់ពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច។"* [107]

**គ. បញ្ហាការយល់ដឹងពីសិទ្ធិរបស់ជនជាប់ចោទ**

ជនជាប់ចោទភាគច្រើនមានបញ្ហាពាក់ព័ន្ធការយល់ដឹងពីសិទ្ធិ ជាពិសេសជនដែលរស់នៅតាមទីដាច់ស្រយោល ដោយសារការយល់ដឹងនៅមានកម្រិត ព្រោះមូលហេតុថា "ពួកគាត់ពុំសូវទទួលបានការសិក្សារៀនសូត្រឱ្យបានពេញលេញ" គួបផ្សំជាមួយនឹងស្ថានភាពរស់នៅប្រចាំថ្ងៃ។ ការផ្តល់ព័ត៌មានផ្នែកច្បាប់ ភាគច្រើនធ្វើឡើងតាមរយៈ ការអប់រំនៅតាមសាលារៀន ដែលវាមិនទាន់គ្រប់គ្រាន់នោះទេ។[108] ហើយពេលខ្លះទោះបីជាមានការយល់ដឹងតិចតួចអំពីសិទ្ធក៏ដោយក៏ពួកគាត់តែងតែមានការភ័យខ្លាច ចំពោះការគំហក សំឡុតពីសំណាក់នគរបាលដែរបានឃាត់ខ្លួន។ ដោយសារតែបញ្ហានេះហើយទើបធ្វើឱ្យពួកគាត់ខ្លាចមិនហ៊ានតវ៉ា ទោះបីជាដឹងថាមានការរំលោភលើសិទ្ធក៏ដោយ។ សម្រាប់ករណីដែលត្រូវបានចាប់ ឬឃាត់ខ្លួន បុគ្គលទាំងនោះក៏មិនត្រូវបានពន្យល់ក្បោះក្បាយពីសិទ្ធិរបស់ខ្លួនពីមន្ត្រីតុលាការ ដែលជាបញ្ហាចោទនាំឱ្យជននោះត្រូវទទួលរងនូវភាពអយុត្តិធម៌។ ដោយសារកម្រិតនៃការយល់ដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋនេះហើយ ទើបធ្វើឱ្យមន្ត្រីអនុវត្តច្បាប់អាចប្រើអំណាចលើសដែនកំណត់នៅក្នុងការចាប់ខ្លួនតែម្តងដោយគ្មានសំអាងហេតុត្រឹមត្រូវ និងនៅពេលដែលមន្ត្រីនគរបាលបានដាក់ការសង្ស័យលើជនណាម្នាក់ថាបានប្រព្រឹត្តបទល្មើស ដោយពុំមានដីកាស៊ើបអង្កេតត្រឹមត្រូវពីសំណាក់ព្រះរាជអាជ្ញា [109] ជាហេតុនាំឱ្យមានការរៀសចាក់ពីដែនសមត្ថកិច្ចរបស់ខ្លួន។ ការភ័យខ្លាចមិនហ៊ានរាយការណ៍ក្នុងការចាប់ខ្លួនពីសំណាក់មន្ត្រីនគរបាលយុត្តិធម៌ ដោយសារជនរងគ្រោះនៅតាមតំបន់ជនបទមានការពិបាកក្នុងការធ្វើដំណើរមកការិយាល័យរបស់អង្គការ ឬមានកង្វល់ពីសុវត្ថិភាពនៃគ្រួសាររបស់ខ្លួន។ ចំណែកអាជ្ញាធរ មិនបានចាត់វិធានដាក់ទណ្ឌកម្ម ឬវិធានការផ្លូវច្បាប់ប្រឆាំងនឹងអ្នកទទួលខុសត្រូវចំពោះការឃុំខ្លួនគេដោយខុសច្បាប់ទេ។

ក្នុងករណីមួយចំនួនដូចជាបទលហុ មន្ត្រីនគរបាលបានប្រើប្រាស់សិទ្ធិអំណាចលើសដែនកំណត់ ដោយធ្វើការចាប់ខ្លួន ជនសង្ស័យដោយពុំបានជូនដំណឹងទៅកាន់ព្រះរាជអាជ្ញា។ មូលហេតុមិនបានជូនដំណឹងទៅព្រះរាជអាជ្ញា ដែលមានសមត្ថកិច្ចក្នុងដែនដីហើយបទល្មើសនោះមិនមែនជាបទល្មើសជាក់ស្តែងដោយគ្មានដីកា

---

[107] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "*ការសង្កេតសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ*" ចេញផ្សាយថ្ងៃទី១២ មិថុនា ២០២៣, ទំព័រ៣

[108] បទសម្ភាស៍ក្នុងសន្និសិទស្តីពី "*បញ្ហាយុត្តិធម៌នៅកម្ពុជា*" ដោយលោក ពេជ្រ ពិសី នាយកកម្មវិធីអង្គការតម្លាភាពអន្តរជាតិកម្ពុជា, ១៧ កក្កដា ២០១៧

[109] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៩៦

ពោលគឺជាការចាប់ខ្លួនដោយរំលោភបំពានសិទ្ធិយ៉ាងធ្ងន់ធ្ងរ ដែលប៉ះពាល់ដល់កត្តិយស និងសេចក្តីថ្លៃថ្នូររបស់បុគ្គល។ ចំពោះនីតិវិធី ខ្លះៗដែលមន្ត្រីយុត្តិធម៌អនុវត្តនីតិវិធីផ្ទុយពីច្បាប់។

កត្តាចំណេះដឹងខាងលើក៏ជាបញ្ហាចោទ ដោយប្រជាពលរដ្ឋភាគច្រើនមិនបានដឹងពីនីតិវិធី និងការកំណត់អាជ្ញយុកាល ដើម្បីដាក់ពាក្យបណ្តឹងទាស់ ឬបណ្តឹងជំទាស់ ដែលនាំឱ្យខូចប្រយោជន៍របស់ពួកគាត់ ជាពិសេសគាត់មិនអាចបន្តនីតិវិធីក្នុងទាមទារ។ ការមិនអាចបន្តនីតិវិធីជាភាពរាំងស្ទះដែលជននោះត្រូវបានខកខានពេលវេលា ក្នុងសិទ្ធិទទួលបានការជម្រះក្តីដោយយុត្តិធម៌។

**ឃ. កត្តាជីវភាព**

កត្តាជីវភាពបានធ្វើឱ្យប្រជាពលរដ្ឋពុំមានលទ្ធភាពគ្រប់គ្រាន់ ដើម្បីរកមេធាវីការពារក្តីបាន។ ការទាក់ទងរកមេធាវីត្រូវការចំណាយថវិការផ្ទាល់ខ្លួនរបស់ពួកគេ។ ម្យ៉ាងវិញទៀតបើចង់ឱ្យរឿងក្តីដំណើរការបានលឿននិងមានសុពលភាពត្រូវប្រើថវិការច្រើន ពេលខ្លះលើសពីសមត្ថភាពពួកគេ។ ហើយមេធាវីដែលពូកែៗ ពួកគេមិនចង់ការពារក្តីឱ្យប្រជាពលរដ្ឋដែលក្រីក្រទេ ព្រោះថាទទួលបានសោហ៊ុយតិចមិនសម និងពេលវេលាដែលបានចំណាយ។ យើងឃើញថាទោះបី ជាវិជ្ជាជីវៈមេធាវីមានចំនួនកើនឡើងរាល់ឆ្នាំក៏ពិតមែន តែជំនួយមេធាវីការពារក្តីនៅតែត្រូវការប្រើប្រាស់ថវិកាទើបការការពារក្តីមានប្រសិទ្ធភាព។ ដោយហេតុថាមេធាវីជា វិជ្ជាជីវៈឯករាជ្យមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់អំណាចតុលាការ ដូច្នេះរាល់ការចំណាយជាបន្ទុករបស់កូនក្តីផ្ទាល់។ ប៉ុន្តែប្រសិនបើក្នុងករណីដែលមិនអាចរកមេធាវីបាន ពួកគេត្រូវចំណាយកាន់តែច្រើនជាងការចំណាយលើថ្លៃសេវាមេធាវីទៅទៀត។ ដោយហេតុថាពួកគេគ្មានជំនាញផ្នែកច្បាប់ និងការយល់ដឹងពីនីតិវិធីច្បាស់លាស់នាំឱ្យមានការចំណាយមិនត្រឹមត្រូវទៅលើការស៊ើបអង្កេត ការចំណាយលើអ្នកជំនាញមិនចំគោលដៅ ការរៀបចំដាក់ឯកសារមិនទាន់ពេលវេលា ឬការដាក់ឯកសារមិនត្រឹមត្រូវជាដើម។ ហើយទីបំផុតពួកគេក៏ត្រូវបរាជ័យក្នុងរឿងក្តី និងត្រូវទទួលទោសធ្ងន់ធ្ងរថែមទៀតផង។

**ង. កង្វះខាតមេធាវី**

ការទទួលបានជំនួយពីមេធាវីគឺនៅមានកម្រិត ដោយភាគច្រើនបណ្តាជនត្រូវចោទមិនបាន ដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការទទួលបានជំនួយពីមេធាវី ឬក៏មិនមានលទ្ធភាពក្នុងការជួលមេធាវី។ លើសពីនេះទៅទៀតសន្ទនារវាងមេធាវី និងកូនក្តី មានរយៈពេលខ្លះគឺវាខ្លីពេកដែលធ្វើឱ្យមេធាវីគ្មានពេលគ្រប់គ្រាន់ ដើម្បីធ្វើការពិភាក្សានឹងសិក្សារឿងក្តីឱ្យបានច្បាស់លាស់ដើម្បីជួយកូនក្តី។

តួយ៉ាង ពេលខ្លះទាល់តែដល់ថ្ងៃឡើងសវនាការហើយ ទើបបានមានការពិភាក្សារវាងចៅក្រម និងក្រឡាបញ្ជីដើម្បីរកមេធាវីការពារជននោះ ដែលទង្វើនេះហាក់ដូចជាគ្រាន់តែជាកាយវិការមួយឱ្យល្អមើល និងស្របតាមនីតិវិធីតែប៉ុណ្ណោះ។ ម្យ៉ាងមានការព្រួយបារម្ភផងដែលថា មេធាវីមិនត្រូវបានទទួលនូវសិទ្ធិ ឬក៏អំណាច

ស្មើគ្នារវាងព្រះរាជអាជ្ញាក្នុងការការពារ។ ជាក់ស្តែងភាពសមភាពចំពោះមធ្យោបាយការពារក្តី ក៏នៅមានកម្រិត។ លើសពីនេះទៅទៀត បញ្ហាកង្វះមេធាវី គឺមិនត្រឹមតែចំនួនមេធាវីមានតិចនោះទេ ប៉ុន្តែមេធាវីភាគច្រើន គឺនៅរាជធានីភ្នំពេញ ហេតុនេះបញ្ហាចោទនោះ គឺថានៅពេលដែលមានរឿងក្តីនៅតាមបណ្តាខេត្ត ឧទាហរណ៍ដូចជាខេត្តមណ្ឌលគិរី ក្រចេះជាដើម ដែលជាខេត្តដាច់ស្រយាល ចោទជាផលវិបាកក្នុងការស្វែងរកមេធាវី ។

ចំពោះរឿងក្តីរបស់អនីតិជន ប្រធានតុលាការស្នើសុំចាត់តាំងមេធាវីការពារក្តីមានលក្ខណៈឆាប់រហ័ស ហើយមិនបានទុកពេលវេលាមួយសមស្រប ដើម្បីឱ្យមេធាវីពិនិត្យមើលសំណុំរឿង មកពីមូលហេតុការបញ្ជូនសំណុំរឿង ពីតុលាការទៅឱ្យមេធាវីការពារជនជាប់ចោទ មានលក្ខណៈយឺតយ៉ាវ ព្រមទាំងការថតចម្លងឯកសារមិនគ្រប់ជ្រុងជ្រោយ។ ប្រសិនបើ មេធាវីដែលគ្មានបទពិសោធន៍ មិនអាចមានសមត្ថភាពគ្រប់គ្រាន់ក្នុងការវិភាគផ្នែកច្បាប់ និងមិនមានការយល់ដឹងពីរបៀបក្នុង ការប្រើប្រាស់ភស្តុតាងឱ្យមានប្រសិទ្ធិភាពក្នុងការការពារក្តី។ ប្រភេទនៃភស្តុតាងដែលមាន ភាពសាំញ៉ាំ ឬស្មុគស្មាញ នាំឱ្យមេធាវីមួយចំនួនយល់មិនបានស៊ីជម្រៅធ្វើឱ្យខាតប្រយោជន៍កូនក្តី ឬអាចធ្វើឱ្យកូនក្តីត្រូវផ្តន្ទាទោស។ ដូចគ្នាផងដែរ ចំពោះបញ្ហាជាក់ស្តែង ថ្វីត្បិតតែមេធាវីអាចជួបជនត្រូវចោទដែលជាកូនក្តីរបស់ខ្លួននៅក្នុងពន្ធនាគារបានក៏ដោយ ប៉ុន្តែគ្មានកន្លែងដែលមានលក្ខណៈជាសម្ងាត់ ឬឯកជនភាពសម្រាប់ពួកគេក្នុងការសន្ទនា ដូចជាមានការលួចស្តាប់ ឬថតសម្លេងនៅពេលសន្ទនាផងដែរ។ កត្តាទាំងនេះបណ្តាលឱ្យប៉ះពាល់ដល់ប្រយោជន៍របស់ជនជាប់ចោទយ៉ាងខ្លាំង ។

**ច. កង្វះខាតប្រព័ន្ធផ្សព្វផ្សាយ**

ការផ្សព្វផ្សាយពាក់ព័ន្ធនឹងបញ្ហាផ្នែកច្បាប់ ហាក់នៅជាបញ្ហាចោលដោយសារតែមានការគួបផ្សំពីកត្តាជីវភាព និងកត្តាចំណេះដឹងរបស់ប្រជាជននៅកម្ពុជា។ ការផ្សព្វផ្សាយពីច្បាប់នៅមានកម្រិត ដោយសារតែព័ត៌មានភាគច្រើនមិនត្រូវបានផ្សាយជូនដល់សាធារណៈជន ដូចនៅតាមទីជនបទ ឬទីដាច់ស្រយោលបានទូលំទូលាយដូចជានៅរាជធានីភ្នំពេញ ប៉ុន្តែប្រជាជនដែលរស់នៅតាមទីក្រុង ឬទីប្រជុំជនមិនប្រាកដថាបានទទួលព័ត៌មានពាក់ព័ន្ធនីតិវិធីច្បាប់បានទាំងមូលឡើយ។

ម្យ៉ាងវិញទៀត ការពន្យល់ទាក់ទងនឹងច្បាប់នៅតាមបណ្តាលប្រព័ន្ធផ្សព្វផ្សាយ ដូចជាទូរទស្សន៍ វិទ្យុ ឬប្រព័ន្ធអ៊ិនធឺណេត នៅមានកម្រិតរាល់ពេលដែលពួកគាត់មានចម្ងល់ទាក់ទងនឹងច្បាប់ គាត់ពុំអាចសាកសួរ ឬទទួលបានចម្លើយភ្លាមៗ អំពីនីតិវិធីឡើយ។ រាជរដ្ឋាភិបាលបានដាក់ឱ្យមានការផ្សព្វផ្សាយច្បាប់តាមរយៈប្រព័ន្ធអ៊ីនធឺណេត ប៉ុន្តែនៅតាមទីជនបទគ្មានសេវាអ៊ីនធឺណេតគ្រប់គ្រាន់ ដើម្បីប្រើប្រាស់ដែលនាំឱ្យមានភាពរអាក់រអួលក្នុងការទទួលបានព័ត៌មាន។ រីឯការផ្សព្វផ្សាយតាមរយៈការសែត ឬទស្សនាវដ្តី វិញរឹតតែពិបាកព្រោះប្រជាពលរដ្ឋក្នុងពេលបច្ចុប្បន្ននេះចូលចិត្តស្តាប់ ជាងការអាន ជាហេតុនាំឱ្យគាត់មិនយល់ពីបញ្ហាច្បាប់។ នេះជាបញ្ហាធ្វើឱ្យពលរដ្ឋជាច្រើននៅតែមិនយល់អំពីច្បាប់ និងរងនូវភាពអយុត្តិធម៌។

**ឆ. បញ្ហាប្រឈមផ្សេងៗ**

ក្នុងប្រព័ន្ធច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ចៅក្រមស៊ើបសួរត្រូវបានផ្ដល់ឆន្ទានុសិទ្ធក្នុងត្រួតពិនិត្យមើលម្ដងទៀតនូវកិច្ចការរបស់ព្រះរាជអាជ្ញា គឺពិនិត្យមើលទាំងស្ថានសម្រាលទោស និងស្ថានទម្ងន់ទោស។ ដែលពេលខ្លះវាបង្កើតជាការលំបាកដល់នីតិវិធី ពេលខ្លះទៀតព្រះរាជអាជ្ញា និងចៅក្រមស៊ើបមានទំនាស់ក្នុងនីតិវិធីដែលអាចបណ្ដោលឱ្យមានការរាំងស្ទះដល់ដំណើរការនីតិវិធី ឬអាចប្រើរយៈពេលយូរសម្រាប់រឿងក្ដីភាពខ្វែងគំនិតគ្នារបស់ចៅក្រម និងព្រះរាជអាជ្ញា អាចជះឥទ្ធិពលដល់ដំណើរការនីតិវិធី។[110]

**ការមិនបានបញ្ជូនអនីតិជនទៅជំនុំជម្រះទាន់ពេលវេលា** សិទ្ធិកុមារដែលទំនាស់នឹងច្បាប់បានទទួលរងការប៉ះពាល់ចាប់តាំងពីឆ្នាំ២០១៤ ហើយនៅតែបន្តកើតមាននៅអំឡុងពេលធ្វើរបាយការណ៍នេះ រួមទាំងសិទ្ធិរបស់កុមារអាយុក្រោម ១៤ ឆ្នាំ ដែលយោងតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ ពួកគេមិនត្រូវបានបញ្ជូនទៅជំនុំជម្រះនោះទេ។ កុមារស្ថិតក្នុងចំណោមក្រុមមនុស្ស ដែលងាយរងគ្រោះបំផុត និងត្រូវការការពារជាពិសេសនៅពេលប្រឈមមុខជាមួយប្រព័ន្ធយុត្តិធម៌។ ដូច្នេះ តុលាការគួរបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ពួកគេឱ្យបានពេញលេញ។

## ៣.២. ដំណោះស្រាយក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌

ក្រោយពីស្វែងយល់ពីបញ្ហាប្រឈម ដែលជនជាប់ចោទត្រូវបានរំលោភបំពានសិទ្ធិ យើងខ្ញុំក៏បានលើកឡើងពីដំណោះស្រាយមួយចំនួន ដើម្បីជាគុណវុឌ្ឍ គុណវិធី និងជាគំនិតក្នុងការទទួលបាននូវភាពយុត្តិធម៌។

**ក. ការពង្រឹងលើវិស័យយុត្តិធម៌គ្រប់ដំណាក់កាល**

ដោយសង្កេតឃើញពីភាពខ្វះចន្លោះក្នុងវិស័យយុត្តិធម៌នៅកម្ពុជា ក្នុងការស្វែងរកការពិត យុត្តិធម៌ ឬសំណងដែលសមស្របដែលជនរងគ្រោះ ឬជនជាប់ចោទគួរទទួលបាន ក្រោយពេលសវនាការត្រូវបានបញ្ចប់។ ក្នុងនោះដែលគ្រប់ដំណាក់កាលសវនាការ ប្រព័ន្ធតុលាការត្រូវតែគោរពលើគោលការណ៍គោរពសិទ្ធិមនុស្ស។ ការរឹតបន្តឹងក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ភាគច្រើននៅក្នុងដំណាក់កាលត្រូវបានរកឃើញថាបានប្រើប្រាស់អំពើហិង្សាលើជនសង្ស័យ ឬជនត្រូវចោទ និងបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធ។ ច្បាប់នៃកម្ពុជាគួរតែកត់សម្គាល់ និងផ្ដន្ទាទោសលើបុគ្គលដែលប្រព្រឹត្តលើសដែនកំណត់នៃច្បាប់។ ក្នុងនោះក៏មានការចូលរួមសហការណ៍ពីអង្គភាពប្រឆាំងអំពើពុករលួយ ដែលហៅកាត់ថា ACU ដើម្បីបញ្ចៀសការស៊ីសំណូក ឬការប្រព្រឹត្តអំពើផ្ទុយនឹងច្បាប់របស់មន្ត្រីតុលាការ។ តាមរយៈការចាត់វិធានការអប់រំ បង្ការ ទប់ស្កាត់ និងអនុវត្តច្បាប់បង្ក្រាបបទល្មើសពុករលួយដោយមានការចូលរួមពីសាធារណជន និងប្រតិបត្តិការ។

110 សំ សុខគង់, មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, បទសំភាន៍, ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២

ដូចនេះការពង្រឹងលើវិស័យយុត្តិធម៌ពិតជាដើរតួយ៉ាងសំខាន់ក្នុងការគោរពសិទ្ធិ ជាពិសេសយុត្តិធម៌គួរត្រូវបានផ្តល់ឱ្យបុគ្គលគ្រប់រូបរួមទាំងជនជាប់ចោទ និងជនរងគ្រោះ។ លើសពីនេះ ការចែងពីវិធានចាំបាច់ដើម្បីជៀសវាងការប្រើសិទ្ធិអំណាចលើសដែនសមត្ថកិច្ចរបស់មន្ត្រីតុលាការ ដែលជាកត្តានាំឱ្យមានការរំលោភបំពានសិទ្ធិជារឿងសំខាន់ដែលត្រូវធ្វើ។ យ៉ាងណា រដ្ឋត្រូវធានាឱ្យមានការស៊ើបអង្កេតយ៉ាងឆាប់រហ័ស ទៅលើការធ្វើទារុណកម្មលើជនជាប់ចោទ ឬជនត្រូវចោទដើម្បីបង្ខំឱ្យសារភាពពីពិរុទ្ធក្នុងបទល្មើសណាមួយដែលមានចែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដាក់ទោសអ្នកប្រព្រឹត្ត និងផ្តល់សិទ្ធិដល់ជនរងគ្រោះក្នុងការទទួលបាន សំណង។ ក្នុងនោះដែលរាល់អំពើដែលប៉ះពាល់ និងរំលោភបំពានលើសិទ្ធិរបស់ជនជាប់ចោទត្រូវបានគាំពារដោយច្បាប់។

**ខ. ការទទួលបានការការពារស្របច្បាប់ដោយច្បាប់ជាតិ និង សន្ធិសញ្ញាអន្តរជាតិនៃកម្ពុជា**

ច្បាប់ត្រូវធានារ៉ាប់រងការការពារ និងឈរលើគោលការណ៍អព្យាក្រឹត្យ ភាពសមស្រប និងគោរពគោលការណ៍កិច្ចការពារសិទ្ធិមនុស្ស ដែលរួមមានជនសង្ស័យ ជនជាប់ចោទដែលជានីតិជន ឬអនីតិជន និងជនរងគ្រោះ។ ច្បាប់នៃព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់ លិខិតបទដ្ឋានគតិយុត្តអន្តរជាតិ ជាផ្នែកមួយដ៏សំខាន់ ដើម្បីចូលរួមការពារសិទ្ធិរបស់បុគ្គលពីការរំលោភបំពាន សិទ្ធិ រូបរាងកាយ សតិអារម្មណ៍ឬបញ្ញាស្មារតី។ លើសពីនេះការទទួលបានកិច្ចការពារពីច្បាប់អាចផ្តល់ ឬស្វែងរកយុត្តិធម៌ ពោលគឺមនុស្សគ្រប់រូប មានសិទ្ធស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិទទួលការការពារពីច្បាប់។ ច្បាប់ជាតិ និងសន្ធិសញ្ញាអន្តរជាតិ ដើរតួជាសរសៃឈាម ឈានទៅរកការការពារសិទ្ធិពលរដ្ឋ ដោយផ្អែកតាមលក្ខខណ្ឌ យុត្តិធម៌ មិនលំអៀង ឬទំនោរទៅរកភាគីខាងណាម្នាក់ឡើយ។

**គ. ពង្រីកប្រព័ន្ធផ្សព្វផ្សាយ**

ដោយសារប្រទេសកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍ ការផ្សព្វផ្សាយស្តីពីសិទ្ធិទទួលបានការជម្រះក្តីដោយយុត្តិធម៌ នៅពុំទាន់មានលក្ខណៈជឿនលឿននឹងពេញលេញនៅឡើយទេ។ រដ្ឋាភិបាលគួរយកចិត្តទុកដាក់ ក្នុងផ្សព្វផ្សាយបន្ថែម ពីសិទ្ធិខាងលើឱ្យមានភាពទូលំទូលាយ ដោយបញ្ចូលឱ្យមានកម្មវិធីសិក្សាស្តីពីសិទ្ធិជាមូលដ្ឋានរបស់បុគ្គល ឬបង្កើនការគាំទ្រតាមរយៈការផ្សព្វផ្សាយតាមបណ្តាញសង្គមឌីជីថល វិទ្យុ ទស្សន្តវដី អាចជាមធ្យោបាយមួយដើម្បីឱ្យពលរដ្ឋយល់ដឹងពីច្បាប់។ ការបង្កើតជាវីដេអូអប់រំស្តីពីសិទ្ធិ ដូចជាការពិភាក្សាដេញដោលស្តីពីច្បាប់ព្រហ្មទណ្ឌ ព្រមទាំងការបង្កើតមាតិកាអប់រំផ្សេងៗទៀត តាមបណ្តាលសង្គមឌីជីថល ទូរទស្សន៍ ឬវិទ្យុ។

*ចំណែកអនុប្រធាន សាលាដំបូងរាជធានីភ្នំពេញ លោក តុប ឈុនហេង ថ្លែងថាការទទួលព័ត៌មានស្តីពីច្បាប់ និងការបង្រៀននីតិសាស្ត្រគួរដើរទន្ទឹមគ្នា។ លោក សំដៅលើអ្នកដែលបង្រៀនច្បាប់ត្រូវដឹងពីការវិវឌ្ឍន៍ ចុងក្រោយ នៃស្ថានភាពច្បាប់មាន ចំណេះដឹងគ្រប់គ្រាន់ដើម្បីជៀសវាងការបង្រៀនមេរៀនខុស។*

ដូច្នេះ ប្រព័ន្ធផ្សព្វផ្សាយបានដើរតួយ៉ាងសំខាន់ក្នុងការចែកចាយព័ត៌មាន យ៉ាងទូលំទូលាយទៅកាន់ប្រជាពលរដ្ឋជាផ្នែកមួយ ដែលពួកគាត់ទទួលដឹងអំពីការអប់រំផ្នែកច្បាប់ និងវិធីសាស្ត្រការពារសិទ្ធិរបស់ខ្លួនទាន់ពេលវេលា។

**ឃ. ជំនួយផ្នែកច្បាប់ពីគណៈមេធាវី**

ដោយសារតែជនក្រីក្រ ពួកគាត់ខ្វះលទ្ធភាព ពុំសូវមានចំណេះដឹងផ្នែកច្បាប់ មានភាពទន់ខ្សោយ ដូច្នេះពួកគាត់ត្រូវការជំនួយទាំងនេះខ្លាំងណាស់។ ដោយសម្លឹងឃើញ ពីកត្តាជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋកម្ពុជា គណៈមេធាវីបានសន្យាថា នឹងពង្រីកវិសាលភាពការពារក្តី ឱ្យជនក្រីក្រដោយឥតគិតថ្លៃ និងអំពាវនាវឱ្យមេធាវីនៅទូទាំងប្រទេសជួយការពារក្តីដើម្បីទទួលបានភាពយុត្តិធម៌ ក្នុងសង្គមដើម្បីកាត់បន្ថយផលប៉ះពាល់នៃភាពក្រីក្ររបស់ប្រជាជន។[111] ដើម្បីជាផ្លូវជួយជនរងគ្រោះ ឧក្រិដ្ឋកម្ម ឬ បទមជ្ឈិម ដែលមិនមានមធ្យោបាយ ឬលទ្ធភាពទទួលបានការតំណាងផ្នែកច្បាប់ដូចជា កម្មករកាត់ដេរ ស្ត្រី និងកុមារ ត្រូវបានលើកទឹកចិត្តផងដែរដើម្បីស្វែងរកជំនួយ។ មេធាវីស្ម័គ្រចិត្ត ចំនួន ៤៣៨ នាក់ ក្នុងនោះមេធាវី ២៤៩ នាក់ ស្ម័គ្រចិត្តផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ដោយឥតគិតថ្លៃ និង មេធាវី ១៨៩ នាក់ ស្ម័គ្រចិត្តផ្តល់ដំបូន្មានផ្នែកច្បាប់ និងការពារជនក្រីក្រដោយឥតគិតថ្លៃ។[112] ប្រជាពលរដ្ឋ អាចទាក់ទងមេធាវីស្ម័គ្រចិត្តដែលមានកាតព្វកិច្ច គ្រប់ពេលវេលាក្នុងម៉ោងធ្វើការធម្មតានៅទូទាំងប្រទេស។ គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជាថ្មីៗនេះបានចុះ អនុស្សរណៈយោគយល់គ្នាជាមួយក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រីដើម្បីពង្រីកសេវាកម្មផ្នែកច្បាប់ ដល់ក្មេងស្រី នឹងស្ត្រីដែលរងគ្រោះដោយអំពើហឹង្សា និងបណ្តុះបណ្តាល មន្ត្រីក្នុងច្បាប់ពាក់ព័ន្ធ។

លោក **កើត រិទ្ធ** បានលើកឡើងថា ការចាត់តាំងមេធាវីឱ្យការពារក្តីជូនជនក្រីក្រ គឺជាកាតព្វកិច្ចរបស់គណៈមេធាវីដែលមានចែងក្នុងច្បាប់។ ដោយឱ្យមេធាវីទាំងអស់ មានកាតព្វកិច្ចជួយការពារជនក្រីក្រតាមបែបបទនៃបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

បន្ថែមលោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានស្នើសុំដល់ គណៈមេធាវីកម្ពុជាជួយពង្រាយមេធាវីទៅតាមបណ្តាខេត្ត និងទីជនបទដើម្បីជួយការពារក្តីដល់ប្រជាពលរដ្ឋដែលមាន ជីវភាពក្រីក្រមិនមានលទ្ធភាព ជួលមេធាវីការពារ ឬមិនសូវយល់ពីបញ្ហាផ្លូវច្បាប់។ ប្រជាពលរដ្ឋក្រីក្រ ដែលមិនមានលទ្ធភាពជួលមេធាវី អាចស្នើទៅគណៈមេធាវី ដើម្បីសុំឱ្យផ្តល់មេធាវីជួយការពារក្តីដោយមិនគិតថ្លៃ។ ក្នុងករណីខ្លះ ប្រធានតុលាការជាអ្នកស្នើទៅ

---

[111] សម្តេចក្រឡាហោម ស ខេង អនុញ្ញាតឲ្យក្រុមប្រឹក្សាគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម ថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០២១ https://interior.gov.kh/news/detail/2220

[112] យោងតាមរបាយការណ៍ស្តីពី *"វឌ្ឍនភាពរយៈពេល ១ ឆ្នាំរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អាណត្តិទី១៣"* ខែតុលា ឆ្នាំ ២០២០ ដល់ខែកញ្ញា ឆ្នាំ ២០២១ ដោយលោកមេធាវី អាន សុវឌ្ឍនា។

គណៈមេធាវី ដើម្បីសុំឱ្យចាត់តាំងមេធាវី ជួយការពារក្តីជូនជនណាម្នាក់។ រដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងយុត្តិធម៌បានរួមដៃសហការ និងចិត្តទុកដាក់ជាអាទិភាពលើគោលនយោបាយ ផ្តល់សេវាជំនួយផ្នែកច្បាប់ជូនជនក្រីក្រ។ ក្រោមគោលការណ៍ខាងលើ យើងឃើញថា ប្រជាជនភាគច្រើន បានទទួលជំនួយតំណាងផ្នែកច្បាប់ ដែលរួមចំណែកពីភាពស្វាហាប់របស់រដ្ឋាភិបាល ដែលខិតខំកែសម្រួលឱ្យប្រជាពលរដ្ឋគ្រប់រូបទទួលបានជំនុំជម្រះប្រកបដោយភាពយុត្តិធម៌។

**ង. ការរួមចំណែកពីអង្គការមិនមែនរដ្ឋាភិបាល**

ការរួមចំណែកពីបណ្តោលអង្គការនានា ក៏ជាមធ្យោបាយមួយដែលជួយពន្លឿននីតិវិធីសវនាការ ដោយផ្តល់ជំនួយ ក្នុងការប្រឹក្សាផ្នែកច្បាប់ ឬអ្នកជំនួយការដើម្បីពន្យល់ពីសិទ្ធិរបស់ពលរដ្ឋ ការចុះផ្សព្វផ្សាយនៅតាមបណ្តាលខេត្ត-ក្រុង ជាពិសេសនៅតាមទីដាច់ស្រយោល ឬតាមរយៈការបង្កើតឱ្យមានសិក្ខាសាលា ឬវេទិកាស្តីពីសិទ្ធិ។ ការចុះផ្សព្វផ្សាយនៅតាមបណ្តាលខេត្ត-ក្រុង ជាពិសេសនៅតាមទីដាច់ស្រយោល។

ឧទាហរណ៍៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សនៅកម្ពុជា បានបើកកម្មវិធីបំពាក់បំប៉ន "ស្តីពីសិទ្ធិទទួលបានការជម្រះក្តីដោយយុត្តិធម៌" ជាមួយនិងការចូលរួមសង្កេតសវនាការដោយផ្ទាល់ វគ្គបណ្តុះបណ្តាលស្តីពីជំនាញជជែកដេញដោល និងសិទ្ធិទទួលព័ត៌មាន ដោយតម្លាភាពកម្ពុជា នាំឱ្យសិស្សនិស្សិត ទទួលបាននូវចំណេះដឹងបន្ថែម និងយល់ដឹងពីសិទ្ធិរបស់ខ្លួននៅពេលមានករណីព្រហ្មទណ្ឌកើតមានឡើង។

ការរួមសហការណ៍ពីបណ្តាលអង្គការក្រៅរដ្ឋាភិបាល ដូចជាអង្គការសហប្រជាជាតិ (NGO) អង្គការលីកាដូ (LICADHO) អង្គការយូនីស្កូត (UNICO) ឬអង្គការយូនីសេហ្វ (UNICEF) ក្នុងការការពារសិទ្ធិពលរដ្ឋនៅកម្ពុជាក៏ដូចនៅតាមបណ្តាប្រទេសផ្សេងៗទៀតផងដែរ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

នៅក្នុងចំណុចនេះយើងនឹងលើកមកដោយសង្ខេបអំពីប្រធានបទ “សិទ្ធិទទួលបានការជម្រះក្តីដោយយុត្តិធម៌” នៅក្នុងច្បាប់ និងការអនុវត្តនៅកម្ពុជាដល់អ្នកអាន ដែលបានលើកឡើងពីច្បាប់ជាតិ នឹងច្បាប់អន្តរជាតិ នៅក្នុងសន្ធិសញ្ញា និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ នេះជាទិដ្ឋភាពមូលដ្ឋាននៃការលើកកម្ពស់ពីនីតិរដ្ឋដែលជនត្រូវចោទទាំងអស់មានសិទ្ធិ ទទួលបានការជនុំជម្រះដោយស្មើភាព និងយុត្តិធម៌ ដោយមិនគិតពីស្ថានទម្ងន់ទោសនៃបទល្មើស ឬពីឋានៈនៃបុគ្គល។ រដ្ឋធម្មនុញ្ញនៃកម្ពុជា និងក្រមនីតិវិធីព្រហ្មទណ្ឌ ជាតួអង្គសំខាន់នៅក្នុងការគាំពារជនជាប់ចោទក្នុងនីតិវិធីគ្រប់ដំណាក់កាលនៃការជម្រះក្តី រួមទាំងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយផងដែរ ដោយការចូលរួមដើម្បីឱ្យការជម្រះក្តីដោយយុត្តិធម៌កាន់តែមានប្រសិទ្ធភាព។ ទោះបីជា បុគ្គលណាម្នាក់មានឋានៈជាជនជាប់ចោទក៏ដោយក៏ច្បាប់នៅតែផ្តល់ សិទ្ធិសន្មតទុកជាមុនថាជនគ្រប់រូបគ្មានទោសរហូតដល់តុលាការធ្វើការប្រកាសជាស្ថាពរ។ ការគោរព សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវប្រកាន់ខ្ជាប់ទៅនឹងវិធាននីតិ និងការអនុវត្តដ៏ស្មុគស្មាញដើម្បីស្វែងរកការពិត។ ទោះបីជាសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ត្រូវបានការពារជាទូទៅ នៅកម្ពុជាប៉ុន្តែមានភាពមិនគ្រប់គ្រាន់ នៅក្នុងការអនុវត្តច្បាប់ទាំងនោះ ជាក់ស្តែង គឺនៅតែមានការរំលោភលើសិទ្ធរបស់រូវន្តបុគ្គលកើតចេញពីការប្រើអំណាចហួសដែនសមត្ថកិច្ចដែលច្បាប់បានកំណត់ បណ្តាលមកពីការយល់ដឹងពីច្បាប់ ក៏ដូចជាសិទ្ធិរបស់ប្រជាពលរដ្ឋនៅមានកម្រិត កត្តាជីវភាពដែលគ្មានលទ្ធភាពក្នុងការជួលមេធាវីការពារក្តីដែលនាំឱ្យមានការពិបាកក្នុងការទទួលបាននូវការជម្រះក្តីដោយយុត្តិធម៌។ ការទទួលបានសំណងដែលមានប្រសិទ្ធភាពនៅពេលដែលមានការរំលោភសិទ្ធិ ក្រៅពីតាមរយៈការលើកលែងទោសដល់ជនល្មើស គឺគ្មានអ្វីផ្សេងទៀតឡើយទាំងនៅក្នុងច្បាប់ និងនៅក្នុងការអនុវត្ត។ ប៉ុន្តែគ្រប់បញ្ញត្តិច្បាប់ គឺជាច្រកក្នុងការស្វែងរកដំណោះស្រាយ ដោយធ្វើការពង្រឹងទៅលើវិស័យយុត្តិធម៌នៅគ្រប់ដំណាក់កាល ពង្រីកប្រព័ន្ធផ្សព្វផ្សាយឱ្យទូលាយជាងមុន។ ក្នុងនោះរដ្ឋាភិបាល បានស្នើសុំដល់គណៈមេធាវីកម្ពុជា ជួយពង្រាយមេធាវីទៅតាមបណ្តាលខេត្ត និងទីជនបទដើម្បីជួយការពារក្តី ដល់ប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រមិនមានលទ្ធភាព ជួលមេធាវី នឹងពុំសូវយល់ដឹងពីបញ្ហាផ្លូវច្បាប់ផងដែរ។ ជារួមមកយើងឃើញថា សិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌ពិតជាមានសារៈសំខាន់ណាស់សម្រាប់ប្រជាពលរដ្ឋក្នុងការការពារសិទ្ធិ ក្នុងនាមជនជាប់ចោទ និងផ្តល់នូវភាពទុកចិត្តរបស់ប្រជាពលរដ្ឋមកលើប្រព័ន្ធតុលាការកម្ពុជា ដើម្បីប្រែក្លាយមុខមាត់ប្រទេសកម្ពុជាយើងក្លាយជានីតិរដ្ឋពោរពេញដោយការគោរព សិទ្ធិមនុស្ស និងមានប្រព័ន្ធរដ្ឋបាលយុត្តិធម៌ល្អ ពោលគឺ ផ្តល់សេវាយុត្តិធម៌ដោយចីរភាព។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើការស្រាវជ្រាវទៅលើប្រធានបទ "សិទ្ធិទទួលបានការជម្រះក្តីដោយយុត្តិធម៌នៅកម្ពុជា" រួចមកយើងខ្ញុំសង្កេតឃើញថាមានចំណុចមួយចំនួនគប្បីគួរកែលម្អ ដើម្បីជួយក្នុងការអនុវត្តក្នុងច្បាប់ និងការគោរពសិទ្ធជនជាប់ចោទមានលក្ខណៈល្អ ប្រសើរ។ យើងខ្ញុំសូមលើកយកនូវអនុសាសន៍មួយចំនួនដូចជា៖

- ត្រូវបន្តការផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីច្បាប់ជាតិគឺ រដ្ឋធម្មនុញ្ញ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ និងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដើម្បីឱ្យប្រជាពលរដ្ឋបាន យល់ដឹងកាន់តែប្រសើរ។
- ត្រូវលើកទឹកចិត្តដល់ប្រជាពលរដ្ឋឱ្យចូលរួមក្នុងការសហការណ៍ក៏ដូចជាការផ្តល់នូវការពិតចំពោះអ្វី ដែលពួកគាត់បានឃើញ ដឹង និងពាក់ព័ន្ធនឹងការពិតនៃសំណុំរឿង ត្រូវបន្តរក្សាឱ្យបាននូវភាពកក់ក្តៅ និងសុវត្ថិភាពជូនដល់សាក្សីដែលបានចូលរួមក្នុងការបំភ្លឺការពិតនៅក្នុងសំណុំរឿង ត្រូវអនុវត្តឱ្យបានហ្មត់ចត់ និងគោរពបទប្បញ្ញត្តិច្បាប់ឱ្យបានខ្ជាប់ខ្ជួនក្នុងនាមជា អ្នកស្វែងរកភាពយុត្តិធម៌ជូនប្រជាពលរដ្ឋ។
- ត្រូវផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋឱ្យបាន លឿនរហ័ស ត្រឹមត្រូវ យុត្តិធម៌ និងមិនពុករលួយ
- ក្រសួងយុត្តិធម៌ និងស្ថាប័នពាក់ព័ន្ធគួរតែសហការដើម្បីផ្តល់វគ្គអប់រំ និងបណ្តុះបណ្តាល ដល់អ្នកដែលពាក់ព័ន្ធនឹងការសួរចម្លើយ ពោលគឺអ្នកអនុវត្តច្បាប់ដែលបម្រើផលប្រយោជន៍ ដល់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។
- ក្រសួងមហាផ្ទៃ រួមជាមួយក្រសួងយុត្តិធម៌ និងស្ថាប័ន ឬអង្គការពាក់ព័ន្ធ គួរបើកសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលខ្លីៗ ដល់មន្ត្រីនគរបាលយុត្តិធម៌ និងមន្ត្រីអនុវត្តច្បាប់បន្ថែមទៀត ដើម្បីធ្វើយ៉ាងណាឱ្យមាន ការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវតាមមុខងាររបស់ខ្លួន។
- តុលាការគួរតែផ្តល់ព័ត៌មានឱ្យបានច្បាស់អំពី កាលបរិច្ឆេទសវនាការ ពោលគួរតែមាន ជាតារាងបិទនៅខាងមុខ តុលាការដើម្បីអាចឱ្យប្រជាពលរដ្ឋអាចតាមដាន និងដឹងពីថ្ងៃសវនាការ។ លើសពីនេះទៅទៀត សាលក្រម ឬសាលដីកាទាំងអស់ គួរត្រូវបានចងក្រង ឬបោះពុម្ពផ្សាយ ឬក៏ដាក់បញ្ចូលទៅក្នុងគេហទំព័រ ដែលអាចឱ្យប្រជាជនទូទៅ ជាពិសេសនិស្សិតច្បាប់អាចទទួលបានសំរាប់ជាការសិក្សា ស្វែងយល់ និងផ្តល់ជាតម្លាភាពផងដែរ។

យើងសង្ឃឹមថានៅកម្ពុជា និងមានការដោះស្រាយបញ្ហានេះដោយត្រួតពិនិត្យ ក្រមនីតិវិធីព្រហ្មទណ្ឌ និងគិតគូរពីការអនុម័ត ឬបន្ថែមបទបញ្ញត្តិចាំបាច់ ក្នុងការធានាការទទួល បានសំណងដែលមានប្រសិទ្ធភាព។

# ឯកសារយោង

# ឯកសារយោង

## ១. ឋានានុក្រមនៃលិខិតបទដ្ឋានគតិយុត្ត

### ក.រដ្ឋធម្មនុញ្ញ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣

### ខ. ក្រម

- ព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ។
- ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌ
- ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើក្រមនីតិវីធីរដ្ឋប្បវេណី

### គ. សន្ធិសញ្ញាអន្តរជាតិ

- សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស អនុម័តនិងប្រកាសដោយសេចក្ដីសម្រេចនៃមហាសន្និបាតលេខ ២១៧ A(III) នៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ១៩៤៨
- កតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦
- អនុសញ្ញាស្ដីពីសិទ្ធិកុមារ អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩
- អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោឃៅអមនុស្សធម៌ ឬបន្ថោកបន្ទា បអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤
- ច្បាប់លក្ខន្តិកៈទីក្រុងរូមស្ដីពីតុលាកាព្រហ្មទណ្ឌអន្តរជាតិ

### ឃ. ច្បាប់

- ព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ ប្រកាស់ឱ្យប្រើច្បាប់ស្ដីពីយុត្តិធម៌អនីតិជន
- ព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥ ប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី

- ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ច្បាប់ស្តីពីពន្ធនាគារ
- ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និង ព្រះរាជអាជ្ញា។
- ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- ព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៥ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

### ខ. ព្រះរាជក្រឹត្យ

- ព្រះរាជក្រឹត្យលេខ នស/រកត/០១២១/០៣០ ស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស

## ២. ឯកសារផ្សេងៗ និងវិធីអប់រំមេរៀន

- អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា https://www.eccc.gov.kh/km/case/topic/119
- អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាកការកម្ពុជា (អ.វ.ត.ក) សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងប្រកាសនៅថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១០ សំណុំរឿង ០០១ កាំង ហ្កេកអ៊ាវ ហៅឌុច។
- អង្គការលើកលែងទោសអន្តរជាតិ, "សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានជម្រះក្តីដោយយុត្តិធម៌" (ឆ្នាំ២០១៤) ទំព័រ១២៩, https://sithi.org/tmp/publication/view/2014-04-10-fair-trial-manual-published-by-amnesty-international។
- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា"ព្រឹត្តិបត្រព័ត៌មានស្តីពីសិទ្ធិទទួលបានការជម្រះក្តីដោយយុត្តិធម៌៖សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង" លេខ១១ (ឆ្នាំ២០២០) https://cchrcambodia.org/admin/media/newsletter/newsletter/khmer/CCHR%20Fair%20Trial%20Rights%20Newsletter%20on%20the%20right%20not%20to%20be%20compelled%20to%20confess%20guilt%20or%20to%20testify%20against%20oneself_KH.pdf ។
- អង្គការមណ្ឌលពត៌មានស្ត្រីកម្ពុជា *អត្ថបទស្រាវជ្រាវ៖ហេតុអ្វី LICADHO ចាត់ទុកការឃុំខ្លួនបណ្តោះអាសន្នលើអនីតិជនជារឿងមិនចាំបាច់?* ចូលមើលថ្ងៃទី២ មិថុនា ២០២៣។
- សន្និសិទស្តីពី "សមិទ្ធផលសម្រេចរយៈពេល ៥ឆ្នាំ របស់ក្រសួងយុត្តិធម៌" https://www.youtube.com/live/JahMLEjPbCw?feature=share

# ឧបសម្ព័ន្ធ

## បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ ឯកសារមេធាវីការពារក្តី ក្នុងសំណុំរឿងព្រហ្មទណ្ឌ

ឧបសម្ព័ន្ធទី២៖ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

ឧបសម្ព័ន្ធទី៣៖ ដីកាកោះហៅដើមបណ្តឹងរដ្ឋប្បវេណីឱ្យចូលរួមសវនាការ

ឧបសម្ព័ន្ធទី៤៖ កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ

ឧបសម្ព័ន្ធទី៥៖ ដីកាសម្រេចដាក់ជនត្រូវចោទឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ឧបសម្ព័ន្ធទី៦៖ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន

ឧបសម្ព័ន្ធទី៧៖ ដីកាតម្កល់រឿងទុកឥតចាត់ការ

ឧបសម្ព័ន្ធទី៨៖ ដីកាដំណោះស្រាយ

ឧបសម្ព័ន្ធទី៩៖ សាលក្រម និងសាលដីកា

ឧបសម្ព័ន្ធទី១០៖ រូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់អនីតិជន

ឧបសម្ព័ន្ធទី១១៖ព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស

ឧបសម្ព័ន្ធទី១២៖ព្រះរាជក្រឹត្យស្តីពី ការបង្កើតគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម

ឧបសម្ព័ន្ធទី១៣៖សេចក្តីជូនដំណឹង ស្តីពីបញ្ជីឈ្មោះមេធាវីស្ម័គ្រចិត្ត ផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ និងការពារក្តីជូនជនក្រីក្រ ដោយឥតគិតកម្រៃ

ឧបសម្ព័ន្ធទី១៤៖ សេចក្តីថ្លែងការណ៍របាយការណ៍ប្រចាំឆ្នាំពីការសង្កេតសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ

ឧបសម្ព័ន្ធទី១៥៖ សេចក្តីថ្លែងការណ៍របស់សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

**ឧបសម្ព័ន្ធទី១**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យការពារក្តី**

ខ្ញុំមេធាវី.............................អត្តលេខ.................ស្នាក់ការ ការិយាល័យ...................................ដែលមានអាសយដ្ឋានផ្ទះលេខ..........ផ្លូវលេខ......... ភូមិ................ឃុំ/សង្កាត់.........ស្រុក/ខណ្ឌ..............ខេត្ត/រាជធានី.......................ជាមេធាវីការពារសិទ្ធិ ឱ្យឈ្មោះ.......................................។

**សូមគោរពជូន**

……………………………………………………………………….

**សូមទានជ្រាប:**

**កម្មវត្ថុ:** ការចូលការពារក្តីក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ.....................ចុះថ្ងៃទី...........ខែ.......... ឆ្នាំ...........នៅ...................................................................។

**យោង:** - ពាក្យសុំពឹងពាក់មេធាវីរបស់ឈ្មោះ.........................ចុះថ្ងៃទី.........ខែ............. ឆ្នាំ.................

- មាត្រា២ និងមាត្រា៣នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
- មាត្រា៩៨ និងមាត្រា២៤៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០/០៨/២០០៧

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូន........................................ មេត្តាជ្រាបថា: ខ្ញុំត្រូវបានឈ្មោះ............................... សុំពឹងពាក់ឱ្យការពារក្តីក្នុងសំណុំរឿងខាងលើ តាមនីតិវិធី ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម........................................មេត្តាជ្រាបតាមការគួរ។

សូម........................................មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

**ជូនភ្ជាប់ជាមួយ:** ធ្វើនៅ.............., ថ្ងៃទី........ខែ............. ឆ្នាំ............

ហត្ថលេខា និងត្រា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្តឹងទាស់

ខ្ញុំមេធាវី............................អត្តលេខៈ..................សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវីការពារឲ្យឈ្មោះ............................ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ.........................ចុះថ្ងៃទី...........ខែ...............ឆ្នាំ................

## សូមគោរពជូន

.........................................................................

**កម្មវត្ថុ:**ប្តឹងទាស់នឹងសាលក្រម/សាលដីកាលេខ.........................ចុះថ្ងៃទី...........ខែ...............ឆ្នាំ................

របស់................................................។

**យោងៈ** - មាត្រា ៣៦៥, ៣៦៦,៣៦៧, ៣៦៨, ៣៦៩, ៣៧០ និងមាត្រា៣៧២ នៃក្រមនីតិវិធី ព្រហ្មទណ្ឌ ចុះថ្ងៃទី១០/០៨/២០០៧

- សាលក្រម/ សាលដីកាកំបាំងមុខលេខ........................ចុះថ្ងៃទី...........ខែ...............ឆ្នាំ................
- លិខិតជូនដំណឹងស្តីពីសាលក្រម/សាលដីកាកំបាំងមុខលេខ...........ចុះថ្ងៃទី......ខែ...........ឆ្នាំ..........
- លិខិតប្រគល់សិទ្ធិប្តឹងទាស់ចុះថ្ងៃទី............ខែ..............ឆ្នាំ...................

សេចក្តីដូចបានជម្រាបជូនតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន...................មេត្តាជ្រាបៈ ដោយកូនក្តីខ្ញុំឈ្មោះ.....................................មិនសុខចិត្តនឹងសាលក្រម/សាលដីកាកំបាំងមុខខាងលើ ត្រង់ចំណុច..................................................................នៃសាលក្រម/ សាលដីកាកំបាំងមុខ។

អាស្រ័យហេតុនេះសូម...................................................មេត្តាទទួល និងចាត់ការលើបណ្តឹងទាស់តាមនីតិវិធីនៃច្បាប់ដោយក្តីអនុគ្រោះ។

ធ្វើនៅ.......................ចុះថ្ងៃទី..........ខែ...............ឆ្នាំ................

**ហត្ថលេខា និងត្រា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្ដឹងឧទ្ធរណ៍

ខ្ញុំមេធាវី............................អត្តលេខៈ..................សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវីការពារឲ្យឈ្មោះ...........................................ត្រូវជា............................ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ............................ចុះថ្ងៃទី............ខែ...................ឆ្នាំ................។

## សូមគោរពជូន

.........................................................................................

**កម្មវត្ថុៈ** ប្ដឹងឧទ្ធរណ៍លើសាលក្រមលេខ............................ចុះថ្ងៃទី............ខែ...................ឆ្នាំ................

របស់....................................................។

**យោងៈ** - មាត្រា៣៧៥ មាត្រា៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី១០/០៨/២០០៧

-លិខិតប្រគល់សិទ្ធិប្ដឹងឧទ្ធរណ៍ចុះថ្ងៃទី............ខែ...................ឆ្នាំ................

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន......................មេត្តាជ្រាបថាៈដោយហេតុថា កូនក្ដីរបស់ខ្ញុំ ឈ្មោះ.............................................មិនសុខចិត្តចំពោះការសម្រេចសេចក្ដីតាម សាលក្រមលេខ............ចុះថ្ងៃទី............ខែ...................ឆ្នាំ...............របស់....................................។ ខ្ញុំជាមេធាវីសុំប្ដឹងឧទ្ធរណ៍នឹងសេចក្ដីសម្រេចត្រង់ចំណុច....................................។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើសូម...............................មេត្តាទទួលតាមនីតិវិធីនៃច្បាប់។

សូមលោក...........................មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

ធ្វើនៅ.......................ចុះថ្ងៃទី......ខែ................ឆ្នាំ................

**ហត្ថលេខា និងត្រា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>ពាក្យបណ្តឹងជំទាស់ចៅក្រម(ក្មួនក្តី)</u>

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................អាយុ..........ឆ្នាំ សញ្ជាតិ............ជនជាតិ................ មុខរបរ..............................................មានទីលំនៅបច្ចុប្បន្នផ្ទះលេខ..........ផ្លូវ..........ក្រុម......... ភូមិ………………………….. ឃុំ/សង្កាត់……………………….. ស្រុក/ខណ្ឌ……………………….. ខេត្ត/រាជធានី……………………ត្រូវជា…………………………….ក្នុងសំណុំរឿងព្រហ្មទណ្ឌ លេខ……………ចុះថ្ងៃទី………ខែ…………ឆ្នាំ…………….របស់សាលា ដំបូង………………………………………………..។

## <u>សូមគោរពជូន</u>

............................................................

**<u>កម្មវត្ថុ:</u>** សុំប្តឹងជំទាស់ចៅក្រមលោកចៅក្រម/ប្រធានសាលាដំបូង................................ដើម្បីប្តូរពីការ កាន់សំណុំរឿងព្រហ្មទណ្ឌលេខ................ចុះថ្ងៃទី...............ខែ................ឆ្នាំ................។

**<u>យោង:</u>** - មាត្រា៥៥៦, មាត្រា៥៥៧, មាត្រា៥៥៨, មាត្រា៥៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០/០៨/ ២០០៧

- លោកចៅក្រមកាន់រឿងក្តីមានចំណុចពាក់ព័ន្ធមាត្រា ៥៥៦ ដែលត្រូវជាមួយភាគីក្នុងរឿងក្តីនេះ។

សេចក្តីដូចបានជម្រាបតាមកម្មវត្ថុ និងយោងខាងលើខ្ញុំបាទ/នាងខ្ញុំ សូមជម្រាបជូន ……………………… ……………មេត្តាជ្រាបថាដោយលោកចៅក្រម.............................នៃសាលាដំបូង................................ ត្រូវជា......................................ហើយករណីនេះមានបញ្ញត្តិតាម មាត្រា ៥៥៦នៃច្បាប់ ខ្ញុំបាទ/នាងខ្ញុំ សូមធ្វើការប្តឹងជំទាស់ពីលោកចៅក្រមរូបនេះ និងសូមឯកឧត្តម/លោក................................សម្រេចប្តូរលោកចៅក្រមរូបនេះចេញពីសំណុំរឿងព្រហ្មទណ្ឌលេខ..........................ចុះថ្ងៃទី...........ខែ............ ឆ្នាំ……………ហើយប្តូរជំនួសដោយចៅក្រមថ្មីដោយអនុគ្រោះ។

អាស្រ័យហេតុនេះ សូមឯកឧត្តម/លោក..............................មេត្តាសម្រេចតាមភស្តុតាង និងតាមច្បាប់ដោយក្តីអនុគ្រោះ។

សូមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

ធ្វើនៅ..................ចុះថ្ងៃទី.......ខែ...........ឆ្នាំ...........

**ឧបសម្ព័ន្ធទី២**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ ..................
ចុះថ្ងៃទី ............ ខែ ............ ឆ្នាំ ..............
លេខ : .................................. អ.យ

## ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

យើង ........................................ តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ

បញ្ជាឱ្យចូលទៅបង្ហាញខ្លួននៅសវនាការ :

១- នាម-គោត្តនាម ............................................................ ហៅ .................................... ភេទ □ប្រុស-□ស្រី អាយុ .............. ឆ្នាំ
ជាតិ ........................................... របររកស៊ី ...............................................................................................................................
ទីកន្លែងកំណើត ............................ ឃុំ-សង្កាត់ ............................ ស្រុក-ខណ្ឌ ............................ ខេត្ត-ក្រុង ............................
ទីលំនៅបច្ចុប្បន្ន .............................................................................................................................................................
ទោសពីមុន .................... ឪពុកឈ្មោះ ..................................... "□រ-□ស" ម្ដាយឈ្មោះ ..................................... "□រ-□ស"
ប្ដី ឬ ប្រពន្ធឈ្មោះ .................................... "□រ-□ស" មានកូន ..................... ឬ □នៅលីវ - □អនីតិជន ឬ □នីតិជន ។

២- នាម-គោត្តនាម ............................................................ ហៅ .................................... ភេទ □ប្រុស-□ស្រី អាយុ .............. ឆ្នាំ
ជាតិ ........................................... របររកស៊ី ...............................................................................................................................
ទីកន្លែងកំណើត ............................ ឃុំ-សង្កាត់ ............................ ស្រុក-ខណ្ឌ ............................ ខេត្ត-ក្រុង ............................
ទីលំនៅបច្ចុប្បន្ន .............................................................................................................................................................
ទោសពីមុន .................... ឪពុកឈ្មោះ ..................................... "□រ-□ស" ម្ដាយឈ្មោះ ..................................... "□រ-□ស"
ប្ដី ឬ ប្រពន្ធឈ្មោះ .................................... "□រ-□ស" មានកូន ..................... ឬ □នៅលីវ - □អនីតិជន ឬ □នីតិជន ។

អ្នកត្រូវបានចោទប្រកាន់ពីអង្គហេតុ[១] :

.......................................................................................................................................................................................
.......................................................................................................................................................................................
.......................................................................................................................................................................................
.......................................................................................................................................................................................
.......................................................................................................................................................................................
-មានលោក [redacted] **សុនិច** ជាមេធាវីការពារសិទ្ធិជនជាប់ចោទ។

**ដើមបណ្តឹងរដ្ឋប្បវេណី:**

-ឈ្មោះ [redacted] **យឿន** ភេទស្រី អាយុ៤៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ [redacted] រម្យទម ស្រុករវៀង ខេត្តព្រះវិហារ។

**ជនរងគ្រោះ៖**

-ឈ្មោះ[redacted] **សុខឃៀន** ភេទស្រី អាយុ ១៤ ឆ្នាំជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីល[redacted] ឃុំមេទម ស្រុករវៀង ខេត្តព្រះវិហារ។

## ១.អំពីអង្គហេតុ

កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ១៥ និង០០នាទី មានករណី **រំលោភសេពសន្ថវៈ(មានស្ថានទម្ងន់ទោសទាក់ទងនឹងអាយុជនរងគ្រោះ)** មួយកើតឡើង ស្ថិតនៅភូមិដំណាក់ចិន ឃុំរស្មី ស្រុករវៀង ខេត្តព្រះវិហារ ដែលបង្កឡើងដោយជនល្មើសឈ្មោះ[redacted] គីមរ៉ុង ភេទប្រុស អាយុ៣៦ឆ្នាំ បានធ្វើសកម្មភាពចាប់រំលោភទៅលើជនរងគ្រោះឈ្មោះ[redacted] សុខឃៀន ភេទស្រី អាយុ១៤ឆ្នាំ នៅផ្ទះរបស់ជនត្រូវចោទផ្ទាល់រាល់ពេលដែលប្រពន្ធមិននៅផ្ទះ។

## ២.អំពីសេចក្ដីសម្រេចរបស់សាលាដំបូងខេត្តព្រះវិហារ

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៥០(ច) ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តព្រះវិហារ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១.ផ្ដន្ទាទោសលើឈ្មោះ[redacted] គីមរ៉ុង ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ១០(ដប់)ឆ្នាំ ពីបទៈ **រំលោភសេពសន្ថវៈ(ស្ថានទម្ងន់ទោសទាក់ទងនឹងអាយុជនរងគ្រោះ)** ប្រព្រឹត្តនៅភូមិដំណាក់ចិន ឃុំរស្មី ស្រុករវៀង ខេត្តព្រះវិហារ កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្ដន្ទាទោសមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted] គីមរ៉ុង និងចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ[redacted] ឃៀន។

បើកផ្លូវប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញ សេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍លេខៈ ០៩ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២ របស់មហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ប្ដឹងឧទ្ធរណ៍ នឹងសាលក្រមព្រហ្មទណ្ឌលេខ ៥០ (ច) ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តព្រះវិហារ ត្រង់ សេចក្ដីសម្រេចទាំងមូល នៃសាលក្រម ។

-បានឃើញ របាយការណ៍រឿង ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ត្បូងឃ្មុំ។

-បានឃើញ សេចក្ដីសន្និដ្ឋាន ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ។

## ៣.អំពីកិច្ចពិភាក្សាដេញដោល

- ចៅក្រមរបាយការណ៍ អានរបាយការណ៍រឿង។
- តំណាងមហាអយ្យការធ្វើការកត់សម្គាល់។

-ជនជាប់ចោទឈ្មោះ[redacted] គីមរ៉ុង បានឆ្លើយថា៖ ខ្លួនមិនព្រមទទួលយកសាលក្រមនៅសាលដំបូងនេះទេ។ បានជាខ្លួនមិនព្រមទទួលយកសេចក្ដីសម្រេចសាលាដំបូង ព្រោះសាលាដំបូងអនុវត្តលើសលុបពេករហូតដល់១០ឆ្នាំ។ ខ្លួនគ្រាន់តែបាន អោបថើបនៅលើជនរងគ្រោះតែប៉ុណ្ណោះ មិនបានរួមភេទទេ។ បានអោបថើបតិចទៅក៏លេងមានចំណង់ទៅលើជនរងគ្រោះនោះវិញ មូលហេតុបានជាឈប់ចំណង់រួមភេទ ព្រោះខ្លួនអាណិតជនរងគ្រោះដែរ។ ខ្លួនស្គាប់អត់លីតាំងពីខែ៩ ឆ្នាំ ២០២០ មុនពេលកើតហេតុ។ ពេលចាប់ជនរងគ្រោះគឺជនរងគ្រោះបានរើបម្រាសបន្តិចបន្តួចដែរ ខ្លួនបានស្ដាប់ការអង្វររបស់ជនរងគ្រោះដែរ ខ្លួនអាណិតជនរងគ្រោះដោយសារអង្វរខ្លួន ក៏បានផ្អាក់ដែរ។ ខ្លួនស្គាល់ពីរបៀបរួមភេទតែមិនបានអនុវត្តជាមួយជនរងគ្រោះទេ ស្ថានភាពមានអោបថើបបន្តិចបន្តួច។ ទីកន្លែងដែលប្រព្រឹត្តនៅក្រោយផ្ទះ នៅក្នុងចំការ ខ្លួនស្គាល់ជនរងគ្រោះយូរហើយ គាត់ជាប្អូនថ្លៃរបស់ខ្លួន។ មុនពេលចាប់នឹងគឺខ្លួនមិនបានសាសងវាចាជាមួយជនរងគ្រោះដែរខ្លួននិយាយប្រាប់ថាខ្លួនស្រលាញ់ប្អូនឯង។ សកម្មភាពដែលខ្លួនអោបថើបនឹងខ្លួនគ្រាន់តែអោបថើបផ្លូលទៅដី។ ពេលខ្លួនលែង

ជនរងគ្រោះវិញ ជនរងគ្រោះដើរចេញធម្មតា។ ជនរងគ្រោះមានអាយុប្រហែល ១៦ ទៅ ១៧ឆ្នាំ ខ្លួនគិតតាមអាយុកូនស្រីខ្លួន គាត់មានអាយុ១៨ឆ្នាំ ខ្លួនស្មានតាមអាយុកូនស្រី។ ខ្លួនបានធ្វើសកម្មភាព៦ដង ខ្លួនឈប់ធ្វើសកម្មភាព ទាំង៧ដង ព្រោះអាណិតជនរងគ្រោះ។ ពេលនោះខ្លួនទប់អត់ជាប់ ខ្លួនបានស្រាតខោតែអត់បានដោះអាវទេ។ ខ្លួនបានស្រាតខោ តែមិនបានលូកលែងប្រដាប់ភេទប្អូនថ្លៃទេ បានតែស្ទាបបន្តិចបន្តួចប៉ុណ្ណោះ ពេលដែលខ្លួនធ្វើសកម្មភាព គឺខ្លួនមិនបានគំរាមកំហែងលើជនរងគ្រោះទេ។ សកម្មភាពដែលខ្លួនចាប់ទាំង៦លើក គឺខុសកន្លែងគ្នា។ កត្តាដែលធ្វើឲ្យចិត្តជំរុញដល់ការចាប់រំលោភ ព្រោះចំណង់តណ្ហា របស់ខ្លួនទប់មិនជាប់។ បានជាខ្លួនឈប់ធ្វើសកម្មភាពចាប់រំលោភ ព្រោះខ្លួនអាណិតស្រលាញ់ប្អូនថ្លៃ។ ពេលធ្វើសកម្មភាព ខ្លួនមិនបានជក់គ្រឿងញៀន ឬផឹកស្រាទេ។ ខ្លួនចាប់ទាំង ៦លើក មិនបាននិយាយអីជាមួយជនរងគ្រោះទេ។ ខ្លួនស្តាប់មិនបាន ដើមឡើយខ្លួនជាជាងផ្សារដែក មានជម្ងឺឡើងឈាម ហើយក៏ស្តាប់មិនបាន។ ប្អូនថ្លៃខ្លួនរស់នៅជាមួយតាំងពីអាយុ៧ឆ្នាំ។

-ជនរងគ្រោះឈ្មោះ [redacted] សុខឃឿន បានឆ្លើយថា៖ ខ្លួនមានអាយុ១៥ឆ្នាំ រៀនថ្នាក់ទី ២ ខ្លួននៅជាមួយបងស្រីនៅតាំងពីតូចម្ល៉េះ។ បានជាខ្លួននៅជាមួយបងស្រី ពេលនោះម៉ែខ្លួនទៅម៉ាឡេ។ ខ្លួនឈប់រៀនយូរហើយ នៅជាមួយបងស្រី។ ទំនាក់ទំនងបងប្អូនធម្មតា។ ពេលនោះខ្លួនអត់ទាន់ប្រាប់ទេ អត់ហ៊ាន គាត់ថាកុំអោយប្រាប់ចែ។ គាត់ប្រព្រឹត្តអំពើមកលើខ្លួនចំនួន ០៧ដង រហូតបានរួមភេទជាមួយខ្លួន លើកទី១ លើកទី៥ និងលើកទី៧។ គាត់បានខ្ទប់មាត់ហើយអូសទៅតែម្តង។ រាល់សកម្មភាពដែលគាត់ចាប់ខ្លួនគាត់មិនបានគំរាមកំហែងទេ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឃឿន បានឆ្លើយថា៖ កូនស្រីខ្លួនបានខលទូរស័ព្ទប្រាប់ខ្លួនថា បងថ្លៃបានចាប់រំលោភខ្លួន។ ខ្លួនមិនចាំពេលខលប្រាប់នោះឡើយ។ ពេលនោះ ខ្លួនធ្វើការនៅប្រទេសម៉ាឡេ។ កូនស្រីខ្លួនមិនបានប្រាប់ថាបងថ្លៃចាប់រំលោភបានប៉ុន្មានដងឡើយ។ ចំពោះទោសដែលសាលាដំបូងបានដាក់គឺសមល្មមហើយ។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] នាត នៅដំណាក់កាលចៅក្រមស៊ើបសួរ នាពេលសវនាការបានឆ្លើយប្រហាក់ប្រហែលគ្នាថា៖ កាលពីថ្ងៃខែមិនចាំឆ្នាំ២០២១ ខ្លួនកំពុងដកស្ទូងស្រូវនៅភូមិអូរគ្រលោក ខ្ទង់ម៉ោងប្រហែល ១២ថ្ងៃត្រង់ ម្តាយជនរងគ្រោះឈ្មោះ [redacted] ឃឿន បានខលទូរស័ព្ទតាមឆាត ពីម៉ាឡេ ឲ្យខ្លួនសួរក្មេងស្រីជនរងគ្រោះ ពីរឿងត្រូវប្តីងបងថ្លៃចាប់រំលោភ។ ពេលដឹងរឿងនេះភ្លាមខ្លួនបានខលទៅសួរជនរងគ្រោះ នាងបានប្រាប់ថាឈ្មោះ [redacted] គីមរ៉ុង បានចាប់រំលោភបាន០៧ ដង តែមិនបានបញ្ជាក់ថា សម្រេចប៉ុន្មានដងនោះទេ។ លុះស្អែកឡើងខ្លួនបានឲ្យប្អូនស្រីមករករឿង និងបានសួរនាំម្តងទៀត នាងនៅតែបញ្ជាក់ថាឈ្មោះ គីមរ៉ុង ត្រូវជាបងថ្លៃរំលោភពិតមែន។ ក្រោយមកក្នុងថ្ងៃដដែលខ្លួនបាននាំជនរងគ្រោះទៅដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍ប៉ូលីសតែម្តង។ ដោយសារម្តាយជនរងគ្រោះ នៅឆ្ងាយ (ម៉ាឡេស៊ី) គាត់បានឲ្យខ្លួនធ្វើជាដើមបណ្តឹងទាមទារសំណង ពិតមែន តាមការពិភាក្សាគ្នា តាមឆាតជាមួយគាត់។ ក្នុងនាមខ្លួនជាដើមបណ្តឹង ស្នើសុំទាមទារសំណងពីជនត្រូវចោទចំនួន ៣,០០០$ (បីពាន់)ដុល្លារ និងឲ្យតុលាការផ្តន្ទាទោសតាមច្បាប់។

- តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] សុខឃីម ភេទស្រី អាយុ ៣១ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិដំណាក់ចិន ឃុំរស្មី ស្រុករវៀង ខេត្តព្រះវិហារ នាពេលសវនាការបានឆ្លើយប្រហាក់ប្រហែលគ្នាថា៖ ខ្លួនត្រូវជាប្រពន្ធរបស់ជនជាប់ចោទ។ នៅក្នុងរឿងហេតុ ខ្លួនពុំបានដឹងច្បាស់ឡើយ ហើយពុំបានចាប់អារម្មណ៍ដែរ។ ជារៀងរាល់ថ្ងៃ ខ្លួនចេញទៅលក់ដូរ(លក់នំកូនក្មេង) ខាងក្រៅ ខ្លួនចូលផ្ទះតែពេលម៉ោងបាយថ្ងៃតែប៉ុណ្ណោះ ក្រោយហូបបាយរួច ខ្លួនចេញទៅលក់ដូរទៀតហើយ។ ខ្លួនទើបដឹងរឿងលើកចុងក្រោយនេះ លើកទី០៧ ដោយប្អូនស្រីបានប្រាប់ខ្លួន ថាប្តីខ្លួនរកចាប់រំលោភលើរូបគាត់។ ភ្លាមៗនោះខ្លួនខឹង បន្ទាប់ពីបានដឹងរឿងភ្លាម ខ្លួនបានសួរទៅប្តីខ្លួនថា(ម្តេចបានធ្វើចឹង) ប្តីខ្លួនតប(ខ្លួនពិតជាបានធ្វើបែបនេះមែន ប៉ុន្តែមិនបានស៊ីជម្រៅឡើយ (រួមភេទ) គ្រាន់តែអោបថើប។ មូលហេតុដែលខ្លួនប្អូនស្រីប្រាប់ខ្លួននោះ ដោយនៅថ្ងៃនោះ ខ្លួនឃើញប្អូនស្រីខ្លួនមុខមាត់ស្លេកស្លាំង អាវប្រលាក់ដី ខាងខ្នង រួចបានខ្លួនសួរគាត់ ទើបដឹងរឿងហេតុនេះ។

-សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា៖ ក្រោយពីបានស្តាប់ការសួរដេញដោល និងក្រោយពីបានពិនិត្យភស្តុតាងផ្សេងៗ តំណាងមហាអយ្យការ យល់ឃើញថាជនជាប់ចោទបានឆ្លើយថា មិនបានរំលោភលើជនរងគ្រោះនោះទេ គឺគ្រាន់តែបានចាប់អោបថើប និងបានស្ទាបបន្តិចបន្តួច តែប៉ុណ្ណោះ ហើយក៏បានផ្តួលជនរងគ្រោះ ទៅលើដីផងដែរ បើតាម

ការឆ្លើយរបស់ជនរងគ្រោះ ដែលជនជាប់ចោទបានចាប់ចំនួន៧ដង ដែល៧ដងនេះ បានចាប់រំលោកទៅលើជនរងគ្រោះ ចំនួន៣ដង គឺលើកទី១ ទី៥ និងទី៧ នៅន្លែងខុសៗគ្នា ឃើញថាចម្លើយរបស់ជនជាប់ចោទ មិនងាយធ្វើឲ្យតំណាងអយ្យការជឿបានទេ ដោយសារតែតាមចម្លើយរបស់ជនរងគ្រោះ ដែលបានឆ្លើយយ៉ាងច្បាស់លាស់ ទាំងលទ្ធផលកោសលវិច្ឆ័យ ដែលបញ្ជាក់ថា មានការដាច់ព្រហ្មចារីធំ ឃើញថាចម្លើយជនរងគ្រោះ និងការធ្វើកោសលវិច្ឆ័យមានការស៊ីសង្វាក់គ្នា ជាតុពិតបានរំលោភទៅលើជនរងគ្រោះពិតប្រាកដមែន។ ហេតុដូច្នេះតំណាងមហាអយ្យការយល់ឃើញថាការផ្តន្ទាទោសរបស់សាលាដំបូងមានលក្ខណៈធ្ងន់ធ្ងរពេក ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះពិចារណា និងសម្រេចទៅតាមច្បាប់។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ[redacted]គឹមរ៉ុង ៖ ខ្ញុំបាទសូមធ្វើការសេចក្តីសន្និដ្ឋាន ក្នុងការសួរដេញដោល ខ្ញុំបាទឃើញថាកូនក្តីខ្ញុំ បានប្រព្រឹត្តសកម្មភាព ស្ទាបអង្អែលទៅលើជនរងគ្រោះ ដោយសកម្មភាពកូនក្តីខ្ញុំកើតចេញពីចំណង់ កូនក្តីខ្ញុំបាទ។ ណាមួយកូនក្តីខ្ញុំបាទគឺជាជនដែលមិនសូវមានចំណេះដឹង ការប្រព្រឹត្តរបស់គាត់មិនបានគិតវែងឆ្ងាយទេ ធ្វើអ្វីៗទៅតាមចំណង់របស់គាត់ ដូច្នេះ ខ្ញុំបាទមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ សុំធ្វើការស្នើសុំប្រធានក្រុមប្រឹក្សាជួយសម្រាលទោសឲ្យកូនក្តីខ្ញុំបាទផង។

-ជនជាប់ចោទ[redacted] គឹមរ៉ុង និយាយសំដីចុងក្រោយ៖ សំណូមពរឲ្យតុលាការជួយបន្ធូរបន្ថយទោស និងលើកលែងទោសឲ្យខ្លួនផង។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់ចម្លើយរបស់ជនរងគ្រោះ

ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធ

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់

## ៤.សំអាងហេតុ

៤.១- បណ្តឹងឧទ្ធរណ៍លេខៈ ០៩ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២ របស់មហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ប្តឹងឧទ្ធរណ៍ នឹងសាលក្រមព្រហ្មទណ្ឌលេខ ៥០ (ច) ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តព្រះវិហារ គ្រង់ សេចក្តីសម្រេចទាំងមូល នៃសាលក្រម បានធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ ដែលសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ អាចទទួលជំនុំជម្រះបាន តាមបញ្ញត្តិមាត្រា ៣៧៥, មាត្រា ៣៧៦ ក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៣៨២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៤៧ មាត្រា ៣៦៨ មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៤.២- ឆ្លងតាមការសាកសួរដេញដោលនៃសាលាឧទ្ធរណ៍ ពិចារណាឃើញអង្គហេតុថាៈ កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ ២០២១ វេលាម៉ោង ១៥ និង០០នាទី ពិតជាមានករណី រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹង) (អាយុជនរងគ្រោះ ស្ថិតនៅភូមិដំណាក់ចិន ឃុំស្មើ ស្រុករវៀង ខេត្តព្រះវិហារ ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ[redacted] គឹមរ៉ុង ភេទប្រុស អាយុ៣៦ឆ្នាំ បានធ្វើសកម្មភាពចាប់រំលោភទៅលើជនរងគ្រោះឈ្មោះ[redacted]ុខ យៀន ភេទស្រី អាយុ១៤ឆ្នាំ នៅផ្ទះរបស់ជនជាប់ចោទផ្ទាល់រាល់ពេលដែលប្រពន្ធមិននៅផ្ទះ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted] គឹមរ៉ុង បានឆ្លើយថា៖ ខ្លួនមិនព្រមទទួលយកសាលក្រមនៅសាលាដំបូងនេះទេ។ បានជាខ្លួនមិនព្រមទទួលយកសេចក្តីសម្រេចសាលាដំបូង ព្រោះសាលាដំបូងអនុវត្តខុសលើសលុបពេករហូតដល់១០ឆ្នាំ។ ខ្លួនគ្រាន់តែបាន អោបថើបនៅលើជនរងគ្រោះតែប៉ុណ្ណោះ មិនបានរួមភេទទេ។ បានអោប

បើបតិចទៅក៏លេងមានចំណង់ទៅលើជនរងគ្រោះនោះវិញ មូលហេតុបានជាឈប់ចំណង់រួមភេទ ព្រោះខ្លួនអាណិតជនរងគ្រោះដែរ។ គឺខ្លួនគ្រាន់តែបានស្រាតខោ តែមិនបានលូកលេងប្រដាប់ភេទប្អូនថ្លៃខ្លួនទេ បានតែស្ទាបបន្តិចបន្តួចប៉ុណ្ណោះ ពេលដែលខ្លួនធ្វើសកម្មភាព គឺខ្លួនមិនបានគំរាមកំហែងលើជនរងគ្រោះទេ។

-ចំពោះចម្លើយជនជាប់ចោទថា ខ្លួនគ្រាន់តែអោបថើប និងស្ទាបបន្តិចបន្តួចលើជនរងគ្រោះតែប៉ុណ្ណោះ តែពេលធ្វើសកម្មភាពក៏មិនមានការគំរាមកំហែលទៅលើជនរងគ្រោះដែរ នេះមិនមែនជាមូលហេតុនៃការទទួលខុសត្រូវព្រហ្មទណ្ឌទេ ប៉ុន្តែបើពិនិត្យទៅលើអំពើរបស់ជនជាប់ចោទ ដោយផ្អែកទៅឯកសារពិនិត្យការរំលោភផ្លូវភេទលេខ១០/២១ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១ ឃើញថា ជនជាប់ចោទពុំបានប្រព្រឹត្តអំពើហិង្សាលើជនរងគ្រោះ ដែលមានលក្ខណៈសាហាវឃោរឃៅនោះទេ។

៤.៣- ក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍ ពិចារណាឃើញថា៖ ពិតជាមានធាតុផ្សំបទល្មើសរំលោភសេពសន្ថវៈកើតឡើងពិតប្រាកដមែន។ ប៉ុន្តែអំពើរបស់ជនជាប់ចោទឈ្មោះ [redacted]គីមរ៉ុង ជាអំពើមួយដែលកើតចេញពីចំណង់ផ្លូវភេទ ដែលមិនបានគិតពិចារណាឲ្យបានច្បាស់លាស់មុនពេលដែលប្រព្រឹត្តទៅលើជនរងគ្រោះ។ មួយវិញទៀតជនជាប់ចោទជាបុគ្គលម្នាក់មិនមានចំណេះដឹងឡើយ ដោយមិនដឹងថាអំពើដែលប្រ ព្រឹត្តជាអំពើខុសច្បាប់នោះទេ។

៤.៤- សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ឃើញថាសាលាដំបូងផ្តន្ទាទោសមានលក្ខណៈធ្ងន់ធ្ងរពេក ក្រុមប្រឹក្សាជំនុំជម្រះនឹងពិចារណា។

៤.៥- សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ និងសំណូមពរចុងក្រោយរបស់ជនជាប់ចោទ ក្រុមប្រឹក្សាជំនុំជម្រះបានយកមកពិចារណារួចហើយ។

៤.៦- សាលក្រមព្រហ្មទណ្ឌលេខ ៥០(ច) ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តព្រះវិហារ បានសម្រេចត្រឹមត្រូវហើយ លើកលែងតែចំណុចទី១ ដែលផ្តន្ទាទោសជនជាប់ចោទក្រុមប្រឹក្សាពិនិត្យឃើញថាមានលក្ខណៈធ្ងន់ធ្ងរ គប្បីក្រុមប្រឹក្សាជំនុំជម្រះសម្រេចសារជាថ្មី។

## ៥.ហេតុដូច្នេះ សម្រេច

៥.១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ១០១ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២១ របស់មហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ទុកត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់។

៥.២- តម្កល់សាលក្រមលេខ ៥០(ច) ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តព្រះវិហារ ទុកជាបានការដដែលលើកលែងតែចំណុចទី១ ត្រូវកែប្រែ និងសម្រេចសារជាថ្មីដូចខាងក្រោម៖

៥.២.១-ផ្តន្ទាទោសជនជាប់ចោទឈ្[redacted]គីមរ៉ុង ភេទប្រុស អាយុ៣៦ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ៨(ប្រាំបី)ឆ្នាំ។

ពីបទ៖ រំលោភសេពសន្ថវៈ(ស្ថានភាពទម្ងន់ទោសទាក់ទងនឹងអាយុជនរងគ្រោះ) ប្រព្រឹត្តនៅភូមិដំណាក់ចិន ឃុំរស្មី ស្រុករវៀង ខេត្តព្រះវិហារ កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ។

៥.៣- សាលដីកានេះបានជំនុំជម្រះជាអសាធារណៈនៅថ្ងៃច័ន្ទ ៣រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័កព.ស២៥៦៦ ត្រូវនឹងថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២២ និងប្រកាសជាអសាធារណៈ នៅព្រឹក ថ្ងៃអង្គារ ៤កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦ ត្រូវនឹងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]គីមរ៉ុង និង ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]យឿន។

ទុកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|---|

**ឧបសម្ព័ន្ធទី១០**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងយុត្តិធម៌**

រាជធានីភ្នំពេញ,ថ្ងៃទី២៣ខែ មករា ឆ្នាំ២០១៤

លេខ ៖ ០២០ កសណ.ដរ./១៤

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ជំរាបជូន**

**ឯកឧត្តម លោក ប្រធានសាលាដំបូងរាជធានី ខេត្ត**

**ឯកឧត្តម លោក លោកស្រី ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត**

**កម្មវត្ថុ ៖** ការដាក់ឲ្យប្រើរូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ។

តាមកម្មវត្ថុខាងលើ ខ្ញុំសូមជំរាបជូន ឯកឧត្តម លោក លោកស្រី ប្រធានសាលាដំបូងរាជធានី ខេត្ត ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត ថាកន្លងមកក្រសួងយុត្តិធម៌បានផ្តល់នូវរូបមន្តនៃដីកាសំរេចឃុំខ្លួនបណ្តោះអាសន្នប្រើប្រាស់សាកល្បង ឃើញថានៅមានការខ្វះចន្លោះដែលមិនអាចធានាបាននូវការជឿជាក់ពីសំណាក់សាធារណៈជន។ ដូច្នេះក្រសួងយុត្តិធម៌បានបង្កើតរូបមន្តថ្មីដែលអាចបង្ហាញពីតម្លាភាព និងគណនេយ្យភាពក្នុងការធ្វើសេចក្តីសម្រេច ដែលអាចពង្រឹងនូវការជឿទុកចិត្តរបស់សាធារណៈជនលើប្រព័ន្ធតុលាការ។

ក្រសួងយុត្តិធម៌សូមធ្វើការណែនាំសម្រាប់ការបំពេញតាមចំណុចមួយចំនួន ដែលមាននៅក្នុងរូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នតាមគំរូថ្មីនេះដូចតទៅ ៖

- នៅផ្នែកខាងដើមនៃរូបមន្តពុំមានអ្វីផ្លាស់ប្តូរច្រើននោះឡើយ ហើយក៏ពុំមានអ្វីដែលពិបាកយល់ក្នុងការបំពេញនោះទេ។

នៅផ្នែកនេះ ចៅក្រមស៊ើបសួរត្រូវព្យាយាមសួរព័ត៌មានឲ្យបានច្រើនពាក់ព័ន្ធនឹងស្ថានភាពរស់នៅរបស់ជនត្រូវចោទ ដើម្បីជាមូលដ្ឋានក្នុងការសម្រេច ឃុំខ្លួ ឬ មិនឃុំខ្លួន ដូចជាជនត្រូវចោទ ជាអនីតិជន ជាស្ត្រីមានផ្ទៃពោះ ជាស្ត្រីមានកូនតូចៗនៅជាមួយ ដោយគ្មានអ្នកណាផ្សេងទៀតជួយមើលថែរក្សាកូនតូចៗទាំងនោះ ឬ ជនត្រូវចោទ ជាចាសជរា។ល។ ក្នុងស្ថានភាពបែបនេះ បើអាចជៀសវាងបាន មិនគួរគប្បីសម្រេចឃុំខ្លួននោះឡើយ។

ដើម្បីធានាបានករណីខាងលើនេះ នៅក្នុងនីតិវិធីសួរដេញដោលចំពោះមុខគប្បីមានការចូលរួមពីតំណាងអយ្យការ ជនត្រូវចោទ និង ឬ មេធាវីជនត្រូវចោទ ដើម្បីបង្ហាញអំពីការអះអាងរបស់ពួកគេរៀងៗខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីគាំទ្រ ឬ ប្រឆាំងនឹងការសម្រេចឃុំខ្លួន។ នៅពេលបញ្ចប់ការសួរដេញដោលនេះ ចៅក្រមស៊ើបសួរត្រូវធ្វើការសម្រេចពីការឃុំខ្លួនបណ្តោះអាសន្ន ឬ មិនឃុំខ្លួនបណ្តោះអាសន្ន។ ប្រសិនបើសំរេចថាត្រូវឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមត្រូវចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នដោយប្រើគំរូតាមរូបមន្តថ្មីនេះ។

ក. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនអាចបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី - តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងប្រព្រឹត្តបទល្មើស ដែលខ្លួនត្រូវចោទឬទេ? តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចបន្តប្រព្រឹត្តបទល្មើស ឬប្រព្រឹត្តបទល្មើសនោះជាថ្មីឬទេ?

ខ. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនអាចរារាំងដល់ការគាបសង្កត់សាក្សី ឬជនរងគ្រោះ ឬរាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងជនសមគំនិត - តើមានហេតុផលសមរម្យ ដើម្បីជឿជាក់ថា ជនត្រូវចោទអាចគាបសង្កត់សាក្សី ឬជនរងគ្រោះដែរឬទេ? តើជនសមគំនិតនៅតែមានសេរីភាពឬទេ (មិនបារម្ភពីការត្រូវរ៉ូវគ្នាទេ ប្រសិនបើពួកគេត្រូវបានឃុំខ្លួន)?

គ. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចរាំងជនត្រូវចោទពីការធ្វើអោយខូចភស្តុតាង ឬ តម្រុយជាសម្ភារៈ - តើនៅតែមានភស្តុតាង ឬ តម្រុយជាសម្ភារៈ ដែលនគរបាលមិនទាន់មានដែរឬ ទេ? តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងរត់គេចខ្លួន ឬ បំផ្លាញភស្តុតាង ឬតម្រុយជាសម្ភារៈ ឧ: អាវុធពាក់ព័ន្ធនឹងបទល្មើសជាដើម?

ឃ. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចធានារក្សាវត្តមានជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី - តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងរត់គេចខ្លួន ឬភៀសខ្លួនទៅក្រៅប្រទេសដែរឬទេ?

ង. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចការពារសន្តិសុខឲ្យជនត្រូវចោទ - តើមានយោបល់ណាមួយដែលថាជនរងគ្រោះ ឬជនផ្សេងទៀតអាចចង់បង្កគ្រោះថ្នាក់ដល់ជនត្រូវចោទ ដែរឬទេ?

ច. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនជនត្រូវចោទ អាចរក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឲ្យមានភាពច្របូកច្របល់ណាមួយដែលបណ្តាលមកពីបទល្មើសនេះ។

ឆ. ចៅក្រមស៊ើបសួរក៏គួរពិចារណាពីធាតុផ្សំ/ហានិភ័យជាសក្តានុពលដើម្បីជាយុត្តិកម្មដល់ការដាក់នរណាម្នាក់ក្នុងការឃុំជាបណ្តោះអាសន្ន ហើយក៏ពិចារណាផងដែរពីធាតុផ្សំដែលអាចបំបាត់ហានិភ័យនេះ ឧទាហរណ៍: ការងារជាប់លាប់នៅក្នុងសហគមន៍ ចំណងគ្រួសារជាដើម។ល។

នៅក្នុងផ្នែកចុងក្រោយនេះ ចៅក្រមស៊ើបសួរត្រូវធ្វើការសន្និដ្ឋានដោយកំណត់ឲ្យច្បាស់ នូវមូលហេតុមួយ ឬច្រើន ក្នុងចំណោមមូលហេតុទាំង៦ ដែលមានចែងក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនេះ ដើម្បីយកមកអនុវត្តចំពោះរឿងក្តីនេះ និងដើម្បីធ្វើយុត្តិកម្មដល់ការសំរេចរបស់ខ្លួនក្នុងការឃុំខ្លួន។ ក្នុងផ្នែកនេះ ចៅក្រមស៊ើបសួរត្រូវកំណត់ផងដែរ នូវមាត្រានៃក្រមនីតិវិធីព្រហ្មទណ្ឌដែលចែងអំពីថិរវេលាអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងករណីនេះ។ ថិរវេលានេះ អាស្រ័យលើចរិតលក្ខណៈនៃបទល្មើស និងអាយុរបស់ជនត្រូវចោទ (សូមពិនិត្យមើលតារាងខាងក្រោម)។ នៅទីបញ្ចប់ យោងតាមមាត្រា២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលចែងថា ជនត្រូវចោទត្រូវមានសេរីភាពនោះ ចៅក្រមត្រូវបង្ហាញថាគ្មានការដាក់កាតព្វកិច្ចណាមួយតាមរយៈការដាក់ឲ្យស្ថិតនៅ

ការប្រើនីតិវិធីសួរដេញដោលបែបនេះ អាចឲ្យចៅក្រមស៊ើបសួរទទួលបាននូវអំណះអំណាងគ្រប់ជ្រុងជ្រោយក្នុងការសម្រេច ប្រកបដោយតម្លាភាព និងគណនេយ្យភាព ។

I. **ស្ថានភាពអង្គហេតុ និងអង្គច្បាប់**

1. ចំណុចលេខ១តួចនេះ: ចៅក្រមស៊ើបសួរត្រូវដាក់បញ្ចូលឈ្មោះបទល្មើសដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ។

2. ចំណុចលេខ២តួចនេះ: ចៅក្រមស៊ើបសួរត្រូវសរសេរសង្ខេបពីអង្គហេតុនៃរឿងក្តី។

3. ចំណុចលេខ៣តួចនេះ: ចៅក្រមស៊ើបសួរត្រូវសង្ខេបពីសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ២ឬ៣ បន្ទាត់ដាក់បញ្ចូល។ តើតំណាងអយ្យការមានសំអាងអ្វីខ្លះ ដែលស្នើសុំឲ្យឃុំខ្លួន ឬ មិនឲ្យឃុំខ្លួន ធ្វើយ៉ាងនេះដើម្បីបង្ហាញថា ចៅក្រមស៊ើបសួរបានពិចារណាទៅលើមូលហេតុដែលតំណាង អយ្យការបានលើកឡើង។

4. ចំណុចលេខ៤តួចនេះ: ចៅក្រមស៊ើបសួរត្រូវធ្វើសេចក្តីសង្ខេបពីការកត់សម្គាល់ ឬ ការអះអាង របស់ជនត្រូវចោទ ឬ មេធាវីរបស់ជនត្រូវចោទ២ឬ៣ បន្ទាត់។

II. **សំអាងហេតុសេចក្តីសម្រេច ៖**

5. ចំណុចលេខ៥តួចនេះ: ចៅក្រមស៊ើបសួរត្រូវតែប្រាកដថាជនត្រូវចោទ ជាប់ចោទពីបទឧក្រិដ្ឋ ឬ មជ្ឈិម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬ លើសពី១ឆ្នាំ (យោងតាមមាត្រា២០៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ អាស្រ័យហេតុនេះ: ចៅក្រមស៊ើបសួរត្រូវពិនិត្យមើលថាប្រសិនបើរកឃើញពិរុទ្ធភាព ក្រោយពេលសវនាការជនត្រូវចោទអាចទទួលទោសជាប់ពន្ធនាគារស្មើ ឬ លើសពី១ឆ្នាំ ឬ អត់។

6. ចំណុចលេខ៦តួច ចៅក្រមស៊ើបសួរ ត្រូវសរសេរនូវការយល់ឃើញរបស់ខ្លួនឆ្លើយតបទៅនឹងសំអាងហេតុនានា ដែលបានលើកឡើងដោយភាគីដូចជា តំណាងអយ្យការ ជនត្រូវចោទ ឬ មេធាវីរបស់ជនត្រូវចោទ។

ទន្ទឹមនេះ: នៅក្នុងចំណុចនេះដែរ ចៅក្រមស៊ើបសួរត្រូវបង្ហាញអំពីមូលហេតុនៃការឃុំខ្លួនចំនួនមួយ ឬ ច្រើនដែលមានចែងនៅក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយពន្យល់បង្ហាញពីសំអាងហេតុសំរាប់គាំទ្រទៅនឹងមូលហេតុនីមួយៗ ដែលចៅក្រមស៊ើបសួរលើកឡើង ឬ មិនត្រូវយកមកអនុវត្ត ដែលមានជាអាទិ៍ដូចខាងក្រោម៖

ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ អាចនឹងមានលក្ខណៈតឹងរឹងគ្រប់គ្រាន់ ដើម្បីសម្រេចបាន គោលដៅនានា ដូចបានកំណត់នៅក្នុងផ្នែកខាងដើមនោះឡើយ។

ចៅក្រមស៊ើបសួរត្រូវសម្រេចផងដែរ ពីរយៈពេលអតិបរមានៃការឃុំខ្លួនបណ្ដោះអាសន្ន ក្នុងករណីនេះ។ តារាងខាងក្រោមបង្ហាញពីថិរវេលាអតិបរមានៃការឃុំខ្លួនបណ្ដោះអាសន្ន សំរាប់ ប្រភេទនីមួយៗនៃរឿងក្ដី។

| ប្រភេទនៃបទល្មើស និង មាត្រានៃក្រមនីតិវិធីព្រហ្មទណ្ឌពាក់ព័ន្ធ | អាយុជនត្រូវចោទ | ថិរវេលាអតិបរមាដំបូងនៃការឃុំខ្លួន | ការពន្យារថិរវេលាឃុំខ្លួនតាមរយៈដីកាឃុំខ្លួនមួយទៀត |
|---|---|---|---|
| បទឧក្រិដ្ឋ - មាត្រា២០៨ | ១៨ឆ្នាំ ឬចាស់ជាងនេះ | ៦ខែ | ៦ខែ + ៦ខែ |
| បទមជ្ឈិម - មាត្រា២០៩ | ១៨ឆ្នាំ ឬចាស់ជាងនេះ | ៤ខែ | ២ខែ - ថិរវេលាសរុបមិនត្រូវលើសពីពាក់កណ្ដាលអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ |
| បទឧក្រិដ្ឋ -មាត្រា២១៣ | ១៤ - ១៦ឆ្នាំ | ៤ខែ | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |
| បទមជ្ឈិម - មាត្រា២១៤ | ១៤ - ១៦ ឆ្នាំ | ២ខែ ឬ ១/២ នៃអប្បបរមានៃ ទោសដែលច្បាប់បានកំណត់សំរាប់ អនីតិជន (ថិរវេលាមួយណាក៏បាន ដែលជាថិរវេលាខ្លីបំផុតរវាងថិរវេលាទាំង២នេះ) | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |
| បទឧក្រិដ្ឋ -មាត្រា២១៣ | ១៦ - ១៨ឆ្នាំ | ៦ខែ | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |
| បទមជ្ឈិម - មាត្រា២១៤ | ១៦ - ១៨ឆ្នាំ | ៤ខែ ឬ ១/២ នៃ អប្បបរមានៃទោសដែលច្បាប់បានកំណត់សំរាប់ អនីតិជន (ថិរវេលាមួយណាក៏បាន ដែលជាថិរវេលាខ្លីបំផុតរវាងថិរវេលាទាំង២នេះ) | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |

ចៅក្រមស៊ើបសួរគួរធ្វើការកត់សំគាល់ថា ក្នុងករណីបទមជ្ឈឹម អប្បបរមានៃទោសត្រូវបន្ថយមកត្រឹមពាក់កណ្ដាល ប្រសិនបើជនត្រូវចោទជាអនីតិជន នៅពេលប្រព្រឹត្តបទល្មើស (មាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ)។

ចៅក្រមស៊ើបសួរត្រូវចុះហត្ថលេខា និងចុះកាលបរិច្ឆេទលើដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន។

ផ្នែកបញ្ចប់នៃរូបមន្តនេះ គឺជាបង្កាន់ដៃដែលបញ្ជាក់ថាបានប្រគល់ - បុគ្គលដែលបញ្ជូនដីកានេះត្រូវតែចុះហត្ថលេខាលើដីកានេះ ដើម្បីបញ្ជាក់ថាដីកានេះត្រូវបានបញ្ជូនហើយ។ អ្នកទទួលត្រូវចុះហត្ថលេខាលើដីកានេះផងដែរ បន្ទាប់ពីបានទទួល។ ជនត្រូវចោទត្រូវបានគេប្រាប់ឲ្យដឹងអំពីសិទ្ធិប្ដឹងឧទ្ធរណ៍របស់គេ និងពេលកំណត់ប្ដឹងឧទ្ធរណ៍។

ទទួលបានការណែនាំនេះ សូមឯកឧត្តម លោក លោកស្រី ប្រធានសាលាដំបូង ព្រះរាជអាជ្ញាអមសាកាដំបូងរាជធានី ខេត្ត ចាត់វិធានការអនុវត្តឲ្យមានប្រសិទ្ធភាព។

សូមឯកឧត្តម លោក លោកស្រី ប្រធានសាលាដំបូង ព្រះរាជអាជ្ញាអមសាកាដំបូងរាជធានី ខេត្ត ទទួលនូវការរាប់អានអំពីខ្ញុំ ។/

**រដ្ឋមន្ត្រី**

អង្គ វង្សវឌ្ឍានា

ជូនភ្ជាប់ :

- គំរូរូបមន្តដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ០១ច្បាប់

ចម្លងជូន :

- តុលាការកំពូល
- មហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍
- មហាអយ្យការអមសាលាឧទ្ធរណ៍

"ដើម្បីជូនជ្រាប"

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ២៩៤ កយប.រប/១៤

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ កុម្ភៈ ឆ្នាំ ២០១៤

**រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌**

**សូមជំរាបជូន**

**ឯកឧត្តម លោក ប្រធានសាលាដំបូងរាជធានី-ខេត្ត**

**ឯកឧត្តម លោក លោកស្រី ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី-ខេត្ត**

**កម្មវត្ថុ ៖** ស្នើសុំកែសម្រួលលិខិតលេខ ១២០ កយប.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ ២០១៤ របស់ក្រសួងយុត្តិធម៌ ។

តាមកម្មវត្ថុខាងលើ ខ្ញុំសូមជំរាបជូន ឯកឧត្តម លោក លោកស្រី ប្រធានសាលាដំបូងរាជធានី-ខេត្ត និងព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី-ខេត្ត ថា ក្រសួងយុត្តិធម៌បានចេញលេខិតលេខ ១២០ កយប.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ណែនាំឱ្យអនុវត្តរូបមន្តថ្មីនៃដីកាសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្នមានចំណុចខ្វះខាត ដែលក្រសួងសូមធ្វើការកែសម្រួលដូចខាងក្រោម ៖

១-នៅក្នុងលិខិតណែនាំដូចជំរាបជូនខាងលើនេះ នៅបន្ទាត់ទី ៩ រាប់ពីក្រោមឡើងលើនៃទំព័រចុងក្រោយបានសរសេរថា " ចៅក្រមស៊ើបសួរត្រូវចុះហត្ថលេខា និងចុះកាលបរិច្ឆេទលើដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន " ឃ្លានេះសូមកែតម្រូវដោយដាក់ថា " ចៅក្រម និងក្រឡាបញ្ជីត្រូវចុះហត្ថលេខា និងចុះកាលបរិច្ឆេទ លើដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន " ។

២-នៅលើគំរូរូបមន្ត ដែលបានជូនភ្ជាប់ជាមួយលិខិតខាងលើនេះ ក៏ពុំមានដាក់ឱ្យក្រឡាបញ្ជី ចុះហត្ថលេខាដែរហើយក៏មានចំណុចខ្វះខាតមួយចំនួនទៀតផងដែរ ។ ដូច្នេះ ក្រសួងសូមជូនភ្ជាប់គំរូរូបមន្តថ្មី ជាមួយនឹងលិខិតនេះ ដើម្បីប្រើប្រាស់ជាផ្លូវការជំនួសវិញ ។

សូម ឯកឧត្តម លោក លោកស្រី ប្រធានសាលាដំបូង និងព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី-ខេត្ត ជួយចាត់វិធានការឱ្យមានប្រសិទ្ធភាព តាមការគួរ ។

សូម ឯកឧត្តម លោក លោកស្រី ទទួលនូវការរាប់អាន អំពីខ្ញុំ ។

**រដ្ឋមន្ត្រី**

**អង្គ វង្សវឌ្ឍានា**

<u>ចម្លងជូន ៖</u>

-តុលាការកំពូល
-មហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍
-អយ្យការអមសាលាឧទ្ធរណ៍

" ដើម្បីជូនជ្រាប "



CS Scanned with CamScanner

**ឧបសម្ព័ន្ធទី១១**

ច្បាប់ចម្លង

## ព្រះរាជក្រឹត្យ

## ស្ដីពី

នស/រកត/០១២១/០៣០

## ការបន្ធូរបន្ថយទោស និងការលើកលែងទោស

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពី ការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែល ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែល ប្រកាសឱ្យប្រើច្បាប់ស្ដីពីពន្ធនាគារ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែល ប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែល ប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**ត្រាស់បង្គាប់**
**ជំពូកទី១**
**បទប្បញ្ញត្តិទូទៅ**

ការបន្ធូរបន្ថយទោស និងការលើកលែងទោស អាចអនុវត្តបានតែចំពោះទណ្ឌិតដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារដោយសាលក្រម ឬសាលដីកាស្ថាពរប៉ុណ្ណោះ។

មាត្រា៥.-

ការបន្ធូរបន្ថយទោស និងការលើកលែងទោស អាចអនុវត្តចំពោះទណ្ឌិតដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ប្តាក់លើកខិតខំកែប្រែគំនិតមារយាទឱ្យក្លាយជាពលរដ្ឋសុចរិត ដើម្បីធ្វើសមាហរណកម្មចូលរួមរស់ក្នុងសង្គមវិញ
- គោរពប្រតិបត្តិបានយ៉ាងហ្មត់ចត់ និងត្រឹមត្រូវ តាមបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ និងជាគំរូល្អដល់ទណ្ឌិត និងជនជាប់ឃុំដទៃទៀត
- ចូលរួមអនុវត្តយ៉ាងសកម្ម និងទៀងទាត់នូវកម្មវិធីអប់រំកែប្រែ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្មវិធីសមាហរណកម្ម
- គោរពប្រតិបត្តិបានយ៉ាងហ្មត់ចត់ និងត្រឹមត្រូវ តាមសេចក្តីណែនាំផ្សេងទៀតរបស់ពន្ធនាគារ។

ប្រធានពន្ធនាគារត្រូវធ្វើការវាយតម្លៃ និងបញ្ជាក់អំពីការបំពេញលក្ខខណ្ឌខាងលើរបស់ទណ្ឌិតដែលត្រូវបញ្ចូលឈ្មោះក្នុងបញ្ជីទណ្ឌិតដែលត្រូវស្នើសុំទៅគណៈកម្មការរាជធានី ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិត។

មាត្រា៦.-

ការបន្ធូរបន្ថយទោស និងការលើកលែងទោស អាចអនុវត្តផងដែរក្នុងហេតុផលមនុស្សធម៌ចំពោះទណ្ឌិតដែលមានវ័យចាស់ជរា ជាស្ត្រីមានគភ៌ ឬមានជំងឺរ៉ាំរ៉ៃធ្ងន់ធ្ងរ វិបល្លាសស្មារតី ឬពិការភាព ដោយមានលិខិតបញ្ជាក់ពីគ្រូពេទ្យដែលទទួលស្គាល់ដោយក្រសួងមានសមត្ថកិច្ច។

ប្រធានពន្ធនាគារត្រូវធ្វើការបញ្ជាក់អំពីការបំពេញលក្ខខណ្ឌតាមស្ថានភាពនីមួយៗរបស់ទណ្ឌិតដូចមានចែងក្នុងកថាខណ្ឌខាងលើ ដើម្បីរៀបចំបញ្ជីឈ្មោះទណ្ឌិតដែលត្រូវស្នើសុំទៅគណៈកម្មការរាជធានី ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ។

## ជំពូកទី២
## លក្ខខណ្ឌដោយឡែកនៃការបន្ធូរបន្ថយទោស

មាត្រា៧.-

ទណ្ឌិតដែលបានបំពេញលក្ខខណ្ឌតាមបញ្ញត្តិនៃមាត្រា៥ នៃព្រះរាជក្រឹត្យនេះ អាចទទួលការបន្ធូរបន្ថយទោសបាន លុះត្រាតែទណ្ឌិតនោះបានទទួលរងទោស ១/៣ (មួយភាគបី) នៃទោសដាក់ពន្ធនាគារដែលតុលាការបានកំណត់។

ចំពោះទោសដាក់ពន្ធនាគារមួយជីវិត ទណ្ឌិតត្រូវទទួលរងទោស ១០ (ដប់) ឆ្នាំជាមុនសិន។

រយៈពេលនៃការបន្ធូរបន្ថយទោសត្រូវកំណត់ ដូចខាងក្រោម៖

១-ទោសដាក់ពន្ធនាគារកំណត់ពី ១ (មួយ) ឆ្នាំ ដល់ក្រោម ៥ (ប្រាំ) ឆ្នាំ អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន ៣ (បី) ខែ។

# ឧបសម្ព័ន្ធទី១២

ព្រះរាជក្រឹត្យ

នស/រកត/០៨១៧/២១៧

ស្តីពី

**ការបង្កើតគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម**
**អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម**

---

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០២ ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃពិធីសារបន្ថែម នៃអនុសញ្ញាស្តីពីការប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.**_

ព្រះរាជក្រឹត្យនេះ មានគោលបំណងបង្កើតគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម ហៅកាត់ថា "គ.ជ.ប.ទ"។

**មាត្រា ២.**_

ព្រះរាជក្រឹត្យនេះ មានគោលដៅបង្ការ និងប្រឆាំងរាល់ការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម ដើម្បីពង្រឹងកិច្ចការពារជនទាំងឡាយ ដែលត្រូវបានដកហូត សេរីភាពឲ្យរួចផុតពីការធ្វើទារុណកម្ម។

**មាត្រា ៣.**_

សកម្មភាពរបស់ "គ.ជ.ប.ទ" មានវិសាលភាពអនុវត្តនៅគ្រប់កន្លែងឃុំឃាំងជនទាំងឡាយ ដែលត្រូវបានដកហូតសេរីភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អាជ្ញាធរមានសមត្ថកិច្ច ត្រូវអនុញ្ញាតឲ្យ "គ.ជ.ប.ទ" ទៅត្រួតពិនិត្យមើលកន្លែងណាដែលស្ថិតក្នុងដែនសមត្ថកិច្ចនិងការគ្រប់គ្រងរបស់ខ្លួនចំពោះជនទាំងឡាយដែលត្រូវបានឬអាចត្រូវបានដកហូតសេរីភាព។

**មាត្រា ៤.**_

- ទារុណកម្មមានន័យថា អំពើទាំងឡាយណាដែលនាំឲ្យមានការឈឺចាប់ ឬរងទុក្ខយ៉ាងខ្លាំង ទោះផ្លូវកាយ ឬផ្លូវចិត្ត ដែលបានបង្ករឡើងដោយចេតនាទៅលើជនណាម្នាក់ ក្នុងគោលបំណងទាំងឡាយដូចជាការទាញយកព័ត៌មាន ឬចម្លើយសារភាពពីជននោះ។ មិនមែនរាល់ការឈឺចាប់ ឬការរងទុក្ខសុទ្ធតែត្រូវបានចាត់ទុកថាជាការធ្វើទារុណកម្មនោះទេ គឺត្រូវឲ្យមានធាតុផ្សំសំខាន់ៗមួយចំនួនដូចខាងក្រោម ៖
  - ការឈឺចាប់ ឬការរងទុក្ខបង្ករឡើងដោយចេតនា ឬជាប្រព័ន្ធមិនមែន ដោយសារតែឧប្បត្តិហេតុ និងបណ្តាលមកពីការដាក់ទណ្ឌកម្មតាមផ្លូវច្បាប់ឡើយ
  - ការឈឺចាប់ ឬការរងទុក្ខត្រូវបានបង្ករឡើងដោយមន្ត្រីសាធារណៈណាម្នាក់ដូចជា មន្ត្រីនគរបាលមន្ត្រីពន្ធនាគារ ឬមន្ត្រីយោធា ឬដោយមានការព្រមព្រៀង ឬតាមការញុះញង់ពីមន្ត្រីទាំងនោះ
  - ការឈឺចាប់ ឬការរងទុក្ខ ដែលបង្កឡើងដើម្បីទាញយកព័ត៌មាន ឬការបង្ខំឲ្យឆ្លើយសារភាពធ្វើទណ្ឌកម្ម បំភិតបំភ័យបង្ខិតបង្ខំ ឬដើម្បីហេតុផលណាមួយ ដោយផ្អែកលើការរើសអើងណាមួយ
- ការដកហូតសេរីភាពមានន័យថា រាល់ទម្រង់ នៃការឃុំខ្លួន ឬការដាក់ពន្ធនាគារ ឬការដាក់ជនណាម្នាក់នៅក្នុងកន្លែងឃុំឃាំងដែលគេមិនអនុញ្ញាតឲ្យជននោះចាកចេញតាមចិត្ត ដោយធ្វើតាមបញ្ជារបស់អាជ្ញាធររដ្ឋបាល អាជ្ញាធរតុលាការ ឬអាជ្ញាធរដទៃទៀត។

# ជំពូកទី ២
## អំពីសមាសភាព

**មាត្រា ៥.**_

សមាសភាព "គ.ជ.ប.ទ" ត្រូវជាឥស្សរជនទាំងពីរភេទ ដែលមានសមត្ថភាពជំនាញវិជ្ជាជីវៈណាមួយដូចខាងក្រោម ៖

- មានបទពិសោធន៍ ផ្នែកសិទ្ធិមនុស្សជាតិ ឬអន្តរជាតិ
- មានជំនាញផ្នែកច្បាប់ ពិសេសក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ឧបសម្ព័ន្ធទី១៣


គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
THE BAR ASSOCIATION OF THE KINGDOM OF CAMBODIA


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា


ប្រធានគណៈមេធាវី

មេធាវី លី ចន្ទតុលា

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី កុយ នាម
២-មេធាវី ទេព បុផល
៣-មេធាវី ពេជ្រ សុរិយា
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ប៉ា ខូនគា
៦-មេធាវី ចេង ប៉េងហាប់
៧-មេធាវី យុង ផានិត
៨-មេធាវី ចៅ ប៊ុនហួន
៩-មេធាវី រស់ មុនិន្ទ:
១០-មេធាវី តែ ចំណាន
១១-មេធាវី ខុច ចន្ថា
១២-មេធាវី ហុង គីមសួន
១៣-មេធាវី ឱុយ សុខសុលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង សុម៉ារតន៍
១៦-មេធាវី ពិន វណ្ណៈ
១៧-មេធាវី ច័ន្ទ វិចិត្រ
១៨-មេធាវី ព្រហ្ម វិចិត្រសុតា
១៩-មេធាវី ណារុប គុណាថុល
២០-មេធាវី យឹម ថាវី
២១-មេធាវី ឌឹម ចៅសេង
២២-មេធាវី លី សុខឡាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុគ័ន្ធក្រ្ត
២៧-មេធាវី គាន តារា
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ទ្រី សំរស់
៣២-មេធាវី នួន ផានិត
៣៣-មេធាវី យុត កែវសុត្ថា


លេខ ៤៤១ /គម/២១

ថ្ងៃ សុក្រ ៦ កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១

## សេចក្តីជូនដំណឹង
## ស្តីអំពីបញ្ជីឈ្មោះមេធាវីស្ម័គ្រចិត្តផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ និងការការពារក្តីជូនជនក្រីក្រ ដោយឥតគិតកម្រៃ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សូមជូនដំណឹងដល់សមាជិក-សមាជិកា គណៈមេធាវី និងសាធារណៈជនទាំងអស់ជ្រាបថាៈ បន្ទាប់ពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើការអំពាវនាវតាមរយៈលិខិតលេខ ១៨៦/គម/២១ ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២១ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ទទួលបានមេធាវីស្ម័គ្រចិត្តចូលរួមផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ និងការពារក្តីជូនជនក្រីក្រដោយឥតគិតកម្រៃ យ៉ាងផុសផុល។

គិតត្រឹមថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ទទួលបានមេធាវីស្ម័គ្រចិត្តចូលរួមចំនួន **៣២៩រូប (ដូចមានបញ្ជីឈ្មោះភ្ជាប់ជូន)** ដែលក្នុងនោះ មានមេធាវីចំនួន **១៨៣រូប** ស្ម័គ្រចិត្តផ្តល់ការពិគ្រោះយោបល់ដោយឥតគិតកម្រៃ និងមាន មេធាវីចំនួន **១៤៦រូប** ស្ម័គ្រចិត្តការពារក្តីដោយឥតគិតកម្រៃ។

បន្ទាប់ពីមានការជូនដំណឹងតាមរយៈលិខិតលេខ ៣៤១/គម/២១ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ ស្តីពីបញ្ជីឈ្មោះមេធាវីស្ម័គ្រចិត្ត រហូតមកដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ ២០២១ មានមេធាវីស្ម័គ្រចិត្តចូលរួមបន្ថែមចំនួន **១០៩រូប (ដូចមានបញ្ជីឈ្មោះភ្ជាប់ជូន)** ដោយក្នុងនោះមានមេធាវីចំនួន **៦៦រូប** ស្ម័គ្រចិត្តផ្តល់ការពិគ្រោះយោបល់ដោយឥតគិតកម្រៃ និងមានមេធាវីចំនួន **៤៣រូប** ស្ម័គ្រចិត្តការពារក្តីដោយឥតគិតកម្រៃ។

| កាលបរិច្ឆេទ | មេធាវីស្ម័គ្រចិត្តផ្តល់ការពិគ្រោះយោបល់ | មេធាវីស្ម័គ្រចិត្តការពារក្តី | សរុប |
|---|---|---|---|
| គិតត្រឹមថ្ងៃទី ២៥/កុម្ភៈ/២០២១ | ១៣៧រូប | ៨៥រូប | ២២២រូប |
| គិតត្រឹមថ្ងៃទី ០៣/មីនា/២០២១ | ៤៦រូប | ៦១រូប | ១០៧រូប |

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
THE BAR ASSOCIATION OF THE KINGDOM OF CAMBODIA

| | | | |
|---|---|---|---|
| គិតត្រឹមថ្ងៃទី ១៨/មីនា/២០២១ | ៦៦រូប | ៤៣រូប | ១០៩រូប |
| សរុបរួមគិតត្រឹមថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០២១ | | | ៤៣៨រូប |

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះសមាជិក-សមាជិកាដែលជាមេធាវីស្ម័គ្រចិត្តចូលរួមចំនួន **៤៣៨រូប** ។

សាធារណៈជនដែលមានបំណងពិគ្រោះយោបល់ផ្នែកច្បាប់ សូមអញ្ជើញទៅទទួលសេវានេះ ដោយឥតគិតកម្រៃ តាមតារាងពេលវេលា និងអាស័យដ្ឋានដែលភ្ជាប់ជូនជាមួយនេះ ។

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សូមបន្តអំពាវនាវដល់សមាជិក-សមាជិកាទាំងអស់ មេត្តាបន្តចូលរួមធ្វើជាមេធាវីស្ម័គ្រចិត្តក្នុងការផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ និងការពារក្តីជូនជនក្រីក្រដោយឥតគិតកម្រៃ ឱ្យបានកាន់តែច្រើនបន្ថែមទៀត ដើម្បីចូលរួមបម្រើវិស័យយុត្តិធម៌សង្គមឱ្យកាន់តែប្រសើរឡើង ក៏ដូចជាដើម្បីលើកស្ទួយឧត្តមភាព និងកិត្យានុភាពនៃវិជ្ជាជីវៈមេធាវី ។

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា នឹងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមេធាវីស្ម័គ្រចិត្ត ជាបន្តបន្ទាប់តាមពេលវេលាសមរម្យ ហើយនឹងធ្វើការជូនដំណឹងជាថ្មីជូនដល់សមាជិក-សមាជិកា និងសាធារណៈជនជ្រាប ។

សូមសមាជិក-សមាជិកាទាំងអស់ និងសាធារណៈជនទទួលនូវការរាប់អានដោយស្មោះស្ម័គ្រអំពីខ្ញុំ ។/

**ប្រធានគណៈមេធាវី**

មេធាវី លី_ច័ន្ទតុលា

# ឧបសម្ព័ន្ធទី១៤

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

## សេចក្តីថ្លែងការណ៍

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ចេញផ្សាយរបាយការណ៍ប្រចាំឆ្នាំដែលបង្ហាញពីរបកគំហើញសំខាន់ៗពីការសង្កេតសវនាការរបស់ខ្លួននៅសាលាឧទ្ធរណ៍ភ្នំពេញ

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣

ថ្ងៃនេះ គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៃ ម.ស.ម.ក ចេញផ្សាយរបាយការណ៍ប្រចាំឆ្នាំស្តីពី *"សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា៖ ការសង្កេតសវនាការនៅសាលាឧទ្ធរណ៍"* ដែលធ្វើឡើងចាប់ពីថ្ងៃទី១ ខែមករា រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។ របាយការណ៍នេះវិភាគលើទិន្នន័យ ដែលប្រមូលបានតាមរយៈការសង្កេតសវនាការប្រចាំថ្ងៃលើសំណុំរឿងព្រហ្មទណ្ឌចំនួន ៨៥ ដោយមិនបានកំណត់ជាក់លាក់លើសំណុំរឿងណាមួយនៅសាលាឧទ្ធរណ៍ភ្នំពេញ និងបានប្រើប្រាស់តារាងសង្កេតការណ៍សវនាការ ដែលបានរៀបចំយ៉ាងច្បាស់លាស់ក្នុងគោលបំណងវាយតម្លៃលើការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដូចដែលបានកំណត់នៅក្នុងច្បាប់ជាតិ និងអន្តរជាតិ។

របាយការណ៍នេះរកឃើញថា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់មួយចំនួន ត្រូវបានធានានៅចំពោះមុខតុលាការ រួមមាន៖ សិទ្ធិក្នុងការជួបនិយាយជាមួយមេធាវីមុនការជំនុំជម្រះ និងសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី, សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ, ការហាមឃាត់ការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ និងការការពារពីការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែល។

យ៉ាងណាក៏ដោយ ការសង្កេតសវនាការក៏បានរកឃើញថាការអនុលោមតាមបទដ្ឋាននៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាមូលដ្ឋានមួយចំនួនមិនទាន់បានពេញលេញ ដូចខាងក្រោម៖

- សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព និងផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងត្រូវបានចាត់ទុកថាមិនទាន់ត្រូវបានគោរពពេញលេញដោយសារតែជនជាប់ចោទមួយចំនួនទៀត រួមទាំងកុមារបានអះអាងថាពួកគេបានទទួលរងអំពើហិង្សា ឬការធ្វើទារុណកម្មដើម្បីបង្ខិតបង្ខំឱ្យពួកគេឆ្លើយសារភាពអំពីបទល្មើសដែលបានចោទប្រកាន់ (ជនជាប់ចោទចំនួន ៣ នាក់ ក្នុងចំណោម ១១៨ នាក់) នៅដំណាក់កាលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌។
- សិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះជាសាធារណៈ មិនទាន់ត្រូវបានគោរពពេញលេញដោយសារមានសវនាការចំនួន ១៧ ក្នុងចំណោម ៨៥ សំណុំរឿង ដែល ម.ស.ម.ក បានសង្កេតមិនមានការបិទ

កាលវិភាគសវនាការនៅលើក្ដារខៀនព័ត៌មាននៅខាងក្រៅបន្ទប់សវនាការ ឬតាមបណ្ដាញអនឡាញនោះទេ។

- សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់នៅតែបន្តចាត់ទុកថាមិនទាន់ត្រូវបានគោរពពេញលេញដោយហេតុថា ៩,៤% នៃសំណុំរឿងដែលបានសង្កេត ជនជាប់ចោទមិនត្រូវបានប្រាប់អំពីបទចោទប្រកាន់ទាំងអស់ប្រឆាំងនឹងពួកគេ ហើយ ១,១៨% នៃសំណុំរឿងដែលបានសង្កេត ពួកគេមិនត្រូវបានប្រាប់អំពីបទចោទប្រកាន់ទាល់តែសោះប្រឆាំងនឹងពួកគេ។
- សិទ្ធិមានមេធាវីតែងតែមិនទាន់ត្រូវបានគោរពពេញលេញនោះទេ ដោយមាន ២៥% នៃជនជាប់ចោទពីបទមជ្ឈិមមិនមានមេធាវីការពារនោះទេ ហើយមាន ៨ សំណុំរឿងក្នុងចំណោម ៨៥ ដែល ម.ស.ម.ក បានសង្កេតបង្ហាញថា ចៅក្រមខកខានក្នុងការប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីសិទ្ធិមានមេធាវីទេ ហើយចំនួន ៩ សំណុំរឿងផ្សេងទៀតបង្ហាញថា ចៅក្រមត្រឹមតែប្រាប់ជនជាប់ចោទដោយមិនបានពន្យល់ពីសិទ្ធិជាមូលដ្ឋាននោះទេ។
- ការសន្មតទុកជាមុនថាគ្មានទោសនៅតែមិនទាន់ត្រូវបានគោរពពេញលេញ ពីព្រោះថាចៅក្រមមិនបានប្រាប់ និងពន្យល់ដល់ជនជាប់ចោទមានចំនួន ១៨,៨% នៃជនជាប់ចោទទាំងអស់អំពីសិទ្ធិមិនឆ្លើយរបស់ពួកគេ ហើយមានជនជាប់ចោទចំនួន ១៩,៥% បង្ហាញខ្លួនចំពោះតុលាការក្នុងឯកសណ្ឋានពន្ធនាគារដូចគ្នាទៅនឹងទណ្ឌិតដែរ។
- សិទ្ធិមានសេរីភាព និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល មិនទាន់ត្រូវបានគោរពពេញលេញនោះទេ ពីព្រោះមានជនជាប់ចោទចំនួន ៨៩ នាក់ ក្នុងចំណោម ១១៨ នាក់ ត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន ។
- សិទ្ធិរបស់កុមារដែលទំនាស់នឹងច្បាប់ រួមមានសិទ្ធិទទួលបានការការពារពិសេសតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់កម្ពុជា នៅតែបន្តទទួលរងការប៉ះពាល់ ពីព្រោះមិនមានវិធានការដាក់លាក់ណាមួយត្រូវបានដាក់ចេញដើម្បីការពារឯកជនភាព រួមទាំងកុមារអាយុក្រោម ១៤ ឆ្នាំ។

ការប្រៀបធៀបទិន្នន័យនៃរបាយការណ៍ឆ្នាំ២០២១នេះជាមួយនឹងទិន្នន័យនៃរបាយការណ៍មុនៗ ដើម្បីកំណត់ពីនិន្នាការ និងវិភាគពីការវិវឌ្ឍនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឃើញថាភាគច្រើននៃរបកគំហើញមានលក្ខណៈស្រដៀងគ្នា ប៉ុន្តែក៏មានចំណុចសំខាន់ចំនួនបីគួរកត់សម្គាល់៖

- ទីមួយ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ទោះបីជាត្រូវបានចាត់ទុកថាមិនទាន់ត្រូវបានគោរពចាប់តាំងពីឆ្នាំ២០១៦ តែមានភាពល្អប្រសើរឡើងគួរឱ្យកត់សម្គាល់ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ដោយ

# ឧបសម្ព័ន្ធទី១៥

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

LICADHO

CAMBODIAN LEAGUE FOR THE PROMOTION AND DEFENSE OF HUMAN RIGHTS

ទំព័រដើម | បណ្ណាល័យយើង | កម្មវិធី | អំពីយើង | ទំនាក់ទំនងយើង

ប្រភេទប្រព័ន្ធផ្សព្វផ្សាយ: របាយការណ៍ របាយការណ៍សង្ខេប លិខិត • សេចក្តីថ្លែងការណ៍ • កម្រងរូបភាព • វីដេអូ និងវីដេអូខ្លីៗ • មណ្ឌលសោតទស្សន៍ • អត្ថបទព័ត៌មាន

ឌី ខន ៧០ឆ្នាំ

សកម្មជនដីធ្លីត្រូវបានជាប់ពន្ធនាគារ ២៩ថ្ងៃ ចាប់ពី ខែតុលា ឆ្នាំ២០២២

## សេចក្តីថ្លែងការណ៍ | សូមបញ្ឈប់ការឃុំខ្លួនដែលមិនចាំបាច់ លើកុមារនៅក្នុងពន្ធនាគារដ៏ចង្អៀតណែន

### ចំនួនអនីតិជនដែលជាប់ឃុំ*

